ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Sep-2015, 09:14
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៣២២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ត្រាវីស ហ្វារ
*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេា ជុនធី

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការដាក់បង្ហាញឯកសារគន្លឹះសំខាន់ៗ ពាក់ព័ន្ធជាមួយនឹងអង្គហេតុការដ្ឋានការងារចំនួនបី ការដ្ឋានការងារទំនប់១មករា ការដ្ឋានការងារព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានការងារទំនប់ត្រពាំងថ្ម ដែលអង្គជំនុំជម្រះបានធ្វើសក្ខីកម្មស្តាប់ -- ធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សាក្សីរួចហើយ។

ហើយជាបន្តទៅនេះ លោក ឯម ហ៊័យ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

បាទ សូមគោរពលោកប្រធាន សម្រាប់សវនាការស្តីពីការដាក់បង្ហាញឯកសារគន្លឹះនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និង

ដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥។

[០៩:០៣:៤០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះ វិលមុខ ហើយសម្ពាធឈាមឡើងបន្តិច និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការដាក់បង្ហាញឯកសារគន្លឹះសំខាន់ៗរបស់ខ្លួន បន្តពីកិច្ចការដែលខ្លួនបានធ្វើកាលពីថ្ងៃមុន។

សូមអញ្ជើញបាទ!

[០៩:០៥:០០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ សូមគោរពសាធារណជន។ ថ្ងៃនេះ ខ្ញុំនឹងត្រឡប់មកបង្ហាញឯកសារគន្លឹះពាក់ព័ន្ធទៅនឹងទំនប់១មករា ឡើងវិញ។ កាលពីសប្តាហ៍មុនយើងបានចាប់ផ្តើមខ្លះរួចមកហើយ។ មុននឹងត្រឡប់មកនិយាយអំពីកំណត់ហេតុមួយចំនួនពាក់ព័ន្ធទៅនឹងទំនប់នេះ ខ្ញុំសូមបញ្ជាក់ថា ពាក់ព័ន្ធនឹងវីដេអូលេខ E3/3048R នៅវគ្គមួយនោះ យើងឃើញមានក្មេងៗ ឬក៏មនុស្សជំទង់ៗនៅក្នុងវីដេអូនោះ។ ភាគច្រើន

យើងមិនឃើញមុខច្បាស់នៅជិតៗទេ ក៏ប៉ុន្តែនៅវគ្គខ្លះហ្នឹង យើងឃើញមានយុវជនធ្វើការនៅទំនប់១មករានោះ។ ហើយនៅវគ្គមួយនោះ គឺមានលេខ ០១:១៦វិនាទី ហើយនិងវគ្គទី២ គឺមាន០០:២៩វិនាទីទៅដល់០០:៣០វិនាទី។ ហើយនៅចុងក្រោយនោះ គឺមាននៅម៉ោងបី នាទីទី០៣:៤៦វិនាទី ទៅដល់០៣:៤៧វិនាទី និងជាចុងក្រោយគឺនៅនាទីទី៣ ហើយនិងវិនាទីទី៥៨ ទៅដល់នាទីទី០៤:០១ហ្នឹង យើងឃើញក្មេងៗចាក់ដីនៅទំនប់នោះ។

សូមបញ្ជាក់ជូនដល់មេធាវីការពារក្តីលោក នួន ជា ឯកសារវីស៊ូដែលបញ្ជាក់អំពីមរណភាពរបស់ អៀង ឆាំ ដែលខ្ញុំបានដកស្រង់យ៉ាងច្រើនកាលពីលើកមុននោះគឺឯកសារ E29/468។

[០៩:០៧:១១]

ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីកំណត់ហេតុមួយផ្សេងទៀតដែលមាននៅក្នុងបញ្ជីរបស់មេធាវីការពារក្តី ខៀវ សំផន ផងដែរគឺឈ្មោះ កែ ពេជ្រវណ្ណៈ ហៅ វណ្ណៈ ហៅ ថា ហៅ យុទ្ធ ជាកូនប្រុសរបស់ កែ ពក គឺឯកសារ E3/35។ គាត់ស្លាប់បាត់ទៅហើយ បើតាមឯកសារ E144/1.1។ គាត់ក៏មានវត្តមានជាមួយនឹង អៀង ឆាំ និង មាស សុខា នៅសាលាបច្ចេកទេសឫស្សីកែវអស់រយៈពេល៦ខែ។ ពាក់ព័ន្ធទៅនឹងទំនប់នោះ ព័ត៌មានសំខាន់ៗមួយចំនួនដែលគាត់បានផ្តល់ជូនមានដូចតទៅ ជាភាសាបារាំងគឺ 00367721, ជាភាសាអង់គ្លេសគឺ 00346149 ទៅដល់ 50, ជាភាសាខ្មែរគឺ 00340563។ ខ្ញុំសូមដកស្រង់៖ “សំណួរ៖ ក្រោយពីលោករៀនចប់តើគេឲ្យលោកធ្វើអ្វី? លោក កែ ពេជ្រវណ្ណៈ បានឆ្លើយថា៖ ខ្ញុំត្រឡប់ទៅកំពង់ចាមវិញ។ ខ្ញុំទៅតាមឪពុកខ្ញុំ ដើម្បីរៀបចំការដ្ឋានសាងសង់ទំនប់១មករា។ គម្រោងសាងសង់ទំនប់នេះ បានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ១៩៧៦។ គណៈភូមិភាគមជ្ឈិមជាអ្នកទទួលខុសត្រូវទូទៅ មានដូចជា ឪពុកខ្ញុំ, ពូស្រេច, ពូតុល, និង ពូចន ដែលជាប្រធានតំបន់៤១, ៤២ និង ៤៣។ បើតាមផែនការ តំបន់នីមួយៗត្រូវផ្គត់ផ្គង់មនុស្ស១០.០០០នាក់ទៅឲ្យការដ្ឋាន។” នៅទំព័រដដែលនោះ គាត់ក៏បានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “មានអ្នកបច្ចេកទេសតែពីរនាក់ទេ ទី១ ឈ្មោះ ឆាំ មួយទៀតឈ្មោះ សុខា។ ឆាំ ជាប្រធានក្រុម ជាអ្នកបញ្ជាក្រុម ហើយគាត់ក៏ជាប្រធានមន្ទីរសាធារណការដែរ។” សូមបញ្ចប់ការដកស្រង់។

ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌរស់នៅរបស់ពលករនៅទំនប់១មករា កែ ពេជ្រវណ្ណៈ បានឆ្លើយដូចតទៅ គឺនៅទំព័រដដែលជាភាសាបារាំង និងអង់គ្លេស ជាភាសាខ្មែរគឺ 00340563 ទៅដល់ 64។ ខ្ញុំសូមដកស្រង់៖ “ខ្ញុំបានចុះទៅតាមរោងវែងៗរបស់កងចល័ត ប៉ុន្តែមិនដែលឃើញ និងមិនដែលឮថា មាន

ការចាប់មនុស្សយកទៅសម្លាប់ទេ ប៉ុន្តែមានការត្អូញអំពីការខ្វះខាតម្ហូបអាហារ។ មានបញ្ហាពីគណៈកម្មការឲ្យរៀបចំចុងភៅ និងរកម្ហូប។ ជាក់ស្តែងគឺមានការខ្វះខាតមែន ខ្ញុំបានឃើញអ្នកឈឺនៅតាមរោងនីមួយៗ ពេលនោះគេឆ្លើយថាមិនមានថ្នាំលេបទេ។ ហេតុការណ៍នេះ ខ្ញុំបានប្រាប់ទៅឪពុករបស់ខ្ញុំ ហើយគាត់ក៏មានការបញ្ជាទៅតាមតំបន់ឲ្យពេទ្យតាមតំបន់នីមួយៗចុះពិនិត្យ និងជួយព្យាបាលអ្នកជំងឺនៅតាមរោងនីមួយៗ ប៉ុន្តែពេទ្យខាងតំបន់ឆ្លើយថាខ្វះថ្នាំពេទ្យ។ នៅពេលលើកទំនប់នោះ ខ្ញុំដឹងថាមានអ្នកស្លាប់ដោយសារជំងឺបណ្តាលមកពីខ្វះថ្នាំពេទ្យ។” សូមបញ្ចប់ការដកស្រង់។

[០៩:១១:០៦]

ជាចុងក្រោយពាក់ព័ន្ធទៅនឹងទស្សនកិច្ចរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅការដ្ឋានទំនប់១មករា ដែលបង្ហាញអំពីសារៈសំខាន់នៃការដ្ឋាននេះ នៅក្នុងក្រសែភ្នែករបស់មជ្ឈិមបក្ស។ កែ ពេជ្រវណ្ណៈ បាននិយាយនៅទំព័រជាភាសាបារាំង 00367722, ជាភាសាអង់គ្លេសគឺ 00346151, ជាភាសាខ្មែរ 00340564។ ខ្ញុំសូមដកស្រង់៖ “គណៈប្រតិភូខ្មែរដែលដឹកនាំដោយ អ៊ំប៉ុល ពត បានទៅទស្សនកិច្ចជាផ្លូវការពីរដង ក៏ប៉ុន្តែទៅទស្សនកិច្ចច្រើនដងនោះគឺលក្ខណៈក្រៅផ្លូវការ។” សូមបញ្ចប់ការដកស្រង់។ នៅទំព័រដដែលនោះ គាត់និយាយអំពីទស្សនកិច្ចរបស់ អៀង សារី ជាមួយនិង ប៉ុល ពត ដើម្បីសម្ពោធការដ្ឋាន។ ហើយគាត់ក៏និយាយអំពីទស្សកិច្ចរបស់ ឆឹង យឹងគួយ និងទស្សនកិច្ចរបស់គណៈប្រតិភូស្ត្រីឡាវ និងគណៈប្រតិភូកូរ៉េខាងជើង។

ឯកសារ E3/5264 ជាកំណត់ហេតុស្តាប់ចម្លើយមួយទៀតរបស់សមាជិកគ្រួសារ កែ ពក ដែរ ដែលគាត់បានស្លាប់បាត់ទៅហើយគឺឈ្មោះ កែ អ៊ុន ហៅ ឌិក។ លិខិតមរណភាពរបស់គាត់មានដាក់នៅក្នុងឯកសារ E29/471។ គាត់ជាក្មួយ និងជាអ្នកបើកបរឲ្យ កែ ពក ហើយគាត់មកការដ្ឋានហ្នឹងជាញឹកញាប់។ សក្ខីកម្មរបស់គាត់មានសារៈសំខាន់ និងភាពពាក់ព័ន្ធ ពីព្រោះថាគាត់ជាអ្នកសង្កេតការណ៍ខាងក្រៅនៃស្ថានភាពដែលកើតមាននៅទំនប់។ នៅឯកសារ E3/5264 គាត់និយាយនៅទំព័រ៤ ជាភាសាបារាំង, ទំព័រ៥ ជាភាសាអង់គ្លេស និងទំព័រ៥, ៦ ជាភាសាខ្មែរ។ ខ្ញុំសូមដកស្រង់៖ “កែ ពក បានទៅមើលទំនប់ស្ទើរតែជារៀងរាល់ថ្ងៃ ខ្ញុំឃើញសកម្មភាពប្រចាំថ្ងៃនៅការដ្ឋាន។” សូមបញ្ចប់ការដកស្រង់។

ចុះក្រោមមកទៀត គាត់បានបញ្ជាក់ថាមន្ទីររបស់ កែ ពក មានចម្ងាយ៦ ឬ៧គីឡូម៉ែត្រពីទំនប់។ ហើយនៅទំព័រ៥ ជាភាសាបារាំង, ទំព័រ៦ ជាភាសាអង់គ្លេស និងទំព័រ៧ ជាភាសាខ្មែរ គាត់បាននិយាយថា៖ “មនុស្សគ្រប់គ្នាខ្លាចឡានរបស់ កែ ពក ណាស់គឺខ្លាចគេនាំយកទៅសម្លាប់ចោល។ គេសម្លាប់

អ្នកណាដែលគ្រាន់តែលួចដកដំឡូងតែមួយ ក៏គេសម្លាប់ដែរ មិនចាំបាច់និយាយដល់អ្នកដែលប៉ានមកជជែកជាមួយខ្ញុំដែលជាមនុស្សនៅជិតស្និទ្ធនឹងអ្នកធំទេ។ គេសួរ៖ តើពេលហ្នឹងលោកដឹងថា មានគេសម្លាប់ប្រជាជនដែរឬទេ? គាត់ឆ្លើយថា៖ បាទ ខ្ញុំដឹង ខ្ញុំដឹងតាំងពីដំបូងមកម្ល៉េះ។ គេចាប់ពួកក្បត់ផ្ទៃក្នុង ហើយយកទៅសម្លាប់ចោល។"

[០៩:១៤:៤៣]

សូមរំឭកផងដែរថា កែ អ៊ុន គាត់បាននិយាយអំពីអនាម័យនៅទំនប់១មករាគឺ ទំព័រ៤ ជាភាសាបារាំង, ៥ ជាភាសាអង់គ្លេស និង៥-៦ ជាភាសាខ្មែរ។ ខ្ញុំសូមដកស្រង់៖ "នៅពេលនោះ មានមនុស្សរាប់ពាន់នាក់ធ្វើការនៅទីនោះ។ ពួកគេធ្វើការយ៉ាងវេទនា ជាពិសេសស្រីៗនៅពេលដែលមានរដូវ គ្មានទឹកសម្អាតខ្លួនទេ។ អ្នកខ្លះមានរុយរោមគូទ។ នៅការដ្ឋានមានរុយច្រើនណាស់ ដូចឃ្មុំយ៉ាងអ៊ីចឹង។ នៅពេលដែលខ្ញុំជូន កែ ពក ទៅការដ្ឋានលើកទំនប់ មានអ្នកទៅតាម កែ ពក ដែរគឺឈ្មោះ អឿន ជាអ្នកមានឋានៈបន្ទាប់ពី កែ ពក។" សូមបញ្ចប់ការដកស្រង់។

កំណត់ហេតុពីរផ្សេងទៀតដែលខ្ញុំចង់បង្ហាញជូននោះ គឺកំណត់ហេតុលេខ E3/9349 នេះគឺជាសាក្សីមួយរូបដែលបានធ្វើការអស់រយៈពេល២សប្តាហ៍នៅការដ្ឋាន១មករា ក្នុងឋានៈជាអនុប្រធានកងចល័តភូមិដូង បន្ទាប់មកគាត់ជាប្រធានកងការពារស្ពាន។ នៅទំព័រ៤ ជាភាសាបារាំង, ៣-៤ ជាភាសាខ្មែរ និង៣ ជាភាសាអង់គ្លេស គាត់បានឆ្លើយដូចតទៅពាក់ព័ន្ធទៅនឹងការដ្ឋាននៅទំនប់នោះ។ ខ្ញុំសូមដកស្រង់៖ "ពេលធ្វើការ គេមិនឲ្យទាក់ទងគ្នាទេ ព្រោះខ្លាចមិនចប់ផែនការរបស់គេ។ សួរ៖ តើអ្នកណាជាអ្នកប្រាប់ថា មិនឲ្យយើងទាក់ទងគ្នា? ឆ្លើយ៖ ថ្នាក់លើ គឺប្រធានសង្កាត់ ហើយពួកគេបានបញ្ជាមកប្រធានភូមិ រួចប្រធានភូមិបញ្ជាមកប្រធានកងចល័ត។" សូមបញ្ចប់ការដកស្រង់។

[០៩:១៦:៥២]

នៅទំព័រ៥ ជាភាសាបារាំង, ៥ ជាភាសាខ្មែរ និងទំព័រ៤ ជាភាសាអង់គ្លេស គេសួរគាត់ដូចតទៅ៖ "ក្នុងឋានៈជាអនុប្រធានកងចល័ត តើគេឲ្យលោកតាមដានអ្នកផ្សេងទេ? ឆ្លើយ៖ បាទគេបានប្រាប់ខ្ញុំឲ្យតាមដាន និងរាយការណ៍។ អ្នកដែលប្រាប់ខ្ញុំនោះគឺមេភូមិ។" ជាចុងក្រោយពាក់ព័ន្ធនឹងការចាប់ខ្លួននៅក្នុងកងចល័ត គឺនៅទំព័រ៥ ជាភាសាបារាំង, ទំព័រ៥ ជាភាសាខ្មែរ, ទំព័រ៤, ៥ ជាភាសាអង់គ្លេស គាត់បានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់ គេសួរគាត់ថា៖ "តើលោកបានឃើញគេចាប់មនុស្សយកទៅសម្លាប់ដែរឬទេ? ឆ្លើយ៖ ខ្ញុំបានឃើញគេលួងលោមមនុស្សយកទៅសម្លាប់ តែមិនបានឃើញគេសម្លាប់

ផ្ទាល់ភ្នែកទេ។ បើតាមការកត់សម្គាល់របស់ខ្ញុំ គឺប្រធានកងចល័តជាអ្នកមកបញ្ចុះបញ្ចូលហៅយកទៅ។ ខ្ញុំឃើញប្រធានកងចល័តមកប្រាប់ថា ល្ងាចនេះ យកគ្នាប្រាំនាក់ទៅជញ្ជូនខ្សាច់ដាក់ឡាន។ អ្នកទាំងនោះភាគច្រើន គឺពួក១៧មេសា ឬពួកប្រជាជនថ្មី។" រំលងមកបន្តិច គាត់បានបញ្ជាក់ថា៖ "ខ្ញុំឃើញគេបណ្តើរមនុស្សយកមកកាន់វត្តបារាយណ៍ជាន់ដែក។" សូមបញ្ចប់ការដកស្រង់។

កំណត់ហេតុចុងក្រោយដែលខ្ញុំចង់បង្ហាញជូន គឺកំណត់ហេតុលេខ 5287 គឺជាឪពុកមារបស់សាក្សីមុននេះ។ សក្ខីកម្មរបស់គាត់មានសារៈសំខាន់ណាស់ ពីព្រោះវានិយាយពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួនមនុស្សនៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក នៅក្នុងភូមិត្រស់ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ដែលមានការបញ្ជាក់នៅក្នុងដីកាដំណោះស្រាយថា វាមានការពាក់ព័ន្ធទៅនឹងការដ្ឋានសាងសង់ទំនប់១មករាដែរ។ ខ្ញុំមើលទៅ ដូចជាខ្ញុំបាត់ ERN និងបាត់លេខទំព័រ តែខ្ញុំនឹងផ្តល់ជូននៅពេលក្រោយ។ គេសួរគាត់ថា៖ "តើលោកដឹងអំពីទំនាក់ទំនងរវាងមន្ទីរសន្តិសុខនៅវត្តបារាយណ៍ជាន់ដែក និងទំនប់១មករាដែរឬទេ? សាក្សីពេលនោះបានឆ្លើយថា៖ "ខ្ញុំមិនបានដឹងពីទំនាក់ទំនងនោះទេ ពីព្រោះខ្ញុំមិនត្រូវបានគេអនុញ្ញាតឲ្យនិយាយទៅកាន់អ្នកណាម្នាក់ទេ។ ប៉ុន្តែក្រោយពីការដ្ឋានបានចាប់ផ្តើម ចំនួនអ្នកទោសដែលគេដឹកតាមឡាន និងរទេះសេះបានកើនឡើងផងដែរ។ ពីមុនមក ឡានដឹកអ្នកទោសមកពីរបីថ្ងៃម្តង។ នៅឆ្នាំ១៩៧៨ ឡាន និងរទេះសេះចូលមកច្រើនជាងមុន។ ហើយនៅឆ្នាំ១៩៧៨ដដែរ គឺជាឆ្នាំដែលពួកនិរតីមកកាន់កាប់គុកនោះ។" សូមបញ្ចប់ការដកស្រង់។

[០៩:២០:៣០]

ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទទី៣ ដែលខ្ញុំចង់បង្ហាញជូននៅក្នុងសវនាការនេះ គឺជាឯកសារដែលបង្ហាញអំពីការបោសសម្អាតដែលបានកើតឡើងនៅក្នុងភូមិភាគ និងនៅក្នុងតំបន់នោះ។ គឺការបោសសម្អាតនោះ ទោះបីជាយ៉ាងណាដ៏ដោយ វាមិនប៉ះពាល់ទៅដល់ការសាងសង់ទំនប់នោះទេ។ ឯកសារនោះគឺធ្វើឡើងចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៧ គឺពេលចាប់ផ្តើមសាងសង់ទំនប់ ហើយនិងរយៈពេលដែលសាងសង់បន្តបន្ទាប់ទៀត។ គឺការបោសសម្អាតនេះ គឺដឹកនាំដោយកម្មាភិ -- គឺការបោសសម្អាតកម្មាភិបាលភូមិភាគនៅក្នុងតំបន់៤១, ៤២ និង៤៣ ជាពិសេសគឺស្រុកដែលនៅជិតទំនប់ គឺស្រុកសន្ទុក និងស្រុកបារាយណ៍។

ឯកសារទី១ ដែលខ្ញុំចង់ដកស្រង់នោះគឺ ឯកសារលេខ E3/2782 គឺជាកិច្ចសម្ភាសន៍មួយដែលមានចំណងជើងថា "ប្រវត្តិរូបរបស់ កែ ពក" ចុះឆ្នាំ១៩៨៦។ តើ កែ ពក គាត់បាននិយាយអ្វីខ្លះនៅក្នុង

ឯកសារនេះ? ជាដំបូងគឺនៅទំព័រជាភាសាបារាំង 00596210, ជាភាសាអង់គ្លេសគឺ 00089713, ជាភាសាខ្មែរគឺ 00164130។ គាត់និយាយអំពីដើមឆ្នាំ១៩៧៧ និយាយអំពីតំបន់ដែលនៅក្នុងភូមិភាគ និងមន្ទីរ ក៏ដូចជាក្រសួងនានាដែលស្ថិតនៅក្នុងភូមិភាគរបស់គាត់។ កែ ពក បាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់៖ “ដល់ទៅភ្នំពេញ ខ្ញុំទៅជួប ប៉ុល ពត, បងនួន ជា។ ប៉ុល ពត, បងនួន ជា ក៏បង្ហាញឯកសាររបស់តំបន់ គ្រប់តំបន់ គ្រប់ក្រសួង ហើយចម្លើយវាច្បាស់ណាស់ រកកែមិនរួច”។ រំលងបានបន្តិច៖ “ដល់ខែកុម្ភៈ ៧៧ ឡានសន្តិសុខពីភ្នំពេញ មកចាប់ប្រធានក្រសួង និងប្រធានចម្ការកៅស៊ូ។” នៅទីនេះនៅជាភាសាបារាំងនិយាយអំពីក្រសួង ក៏ប៉ុន្តែបើតាមខ្ញុំគិតទៅគឺប្រហែលជាមន្ទីរនៅតំបន់ទេ។ ខ្ញុំសូមបន្តចម្លើយរបស់ កែ ពក តទៅទៀត៖ “ក្នុងឆ្នាំ៧៧ដដែល ឡានសន្តិសុខពីភ្នំពេញ មកចាប់គណៈតំបន់៤១ ប្រាំប្រាំមួយនាក់ ចាប់គណៈតំបន់៤២ ប្រាំប្រាំមួយនាក់, ចាប់គណៈតំបន់៤៣ ប្រាំប្រាំមួយនាក់។ ចាប់គណៈតំបន់អស់ហើយ ក៏ចាប់មេៗក្រសួងរបស់តំបន់ទៀត។”

[០៩:២៣:៥៩]

នៅទំព័របន្ទាប់មកទៀតជាភាសាបារាំងគឺ 00596211, ជាភាសាអង់គ្លេស 00089713 រហូតទៅដល់ 14 និងជាភាសាខ្មែរ 00164131 ទៅដល់ 33។ កែ ពក បានបន្តទៅទៀត៖ “បន្តិចក្រោយមកគឺក្នុងឆ្នាំ៧៧ រវាងខែ៥ ឡានសន្តិសុខពីភ្នំពេញមកចាប់គណៈស្រុកទៀត ចាប់គ្រប់ស្រុកទាំងអស់ មួយស្រុកពីរបីនាក់ ហើយចាប់ប្រធានឃុំខ្លះ មិនគ្រប់ឃុំទាំងអស់ទេ។ សរុបកម្មាភិបាលតំបន់ ក្រសួងដែលត្រូវចាប់នោះមានចំនួន៥០-៦០នាក់។ ដល់ខែមិថុនា ឆ្នាំ១៩៧៧ ចប់ការចាប់មួយវគ្គដំបូងហើយ ពេលនោះនៅសល់តែខ្ញុំ។ ពេលនោះធ្វើការពិនិត្យនៅភូមិភាគកណ្តាលអស់កម្មាភិបាល ខាងលើក៏សម្រេចយកកម្មាភិបាលពីនិរតីមកដាក់។ ខាងលើហៅកម្មាភិបាលពីនិរតីមក២០០នាក់ជាង។ នៅពេលនោះ គឺខាងលើនោះគឺមាន កង ចាប ជាបុគ្គលទី១ ធ្វើការនៅពហុកីឡដ្ឋាន។ ពេលនោះ សរុបទៅគឺប្តូកទាំងតំបន់៤៥ ភូមិភាគកណ្តាលទៅជាតំបន់ភូមិភាគថ្មី។”

បញ្ជីអ្នកទោស ស-២១ បញ្ជាក់ពីអ្វីដែល កែ ពក បានលើកឡើង លើកលែងតែចំនួនកម្មាភិបាលដែលត្រូវបានបោសសម្អាតនោះ គឺថាមានច្រើនជាងអ្វីដែលបាន កែ ពក បានលើកឡើង។ ជាដំបូងគឺឯកសារ E3/2956 គឺជាបញ្ជីអ្នកទោស ស-២១ នៃភូមិភាគឧត្តរ ចុះថ្ងៃទី០១ ខែកុម្ភៈ ទៅដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៧។--

**ប្រធានអង្គជំនុំ៖**

បាទផ្អាកសិន! សូមអញ្ជើញលោកមេធាវី គង់ សំអុន ម៉េចទៅ?

[០៩:២៦:៤២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ចំពោះការឆ្លើយបញ្ជាក់របស់សហព្រះរាជអាជ្ញាមុននេះអំមិញ ទាក់ទងនឹងពាក្យថា "ក្រសួង" ហើយគាត់ថាប្រហែលជាច្រឡំការបកប្រែជាភាសាបារាំង។ ការពិតខ្ញុំឃើញជាភាសាខ្មែរ គឺប្រើពាក្យថា "ក្រសួង" អ៊ីចឹងដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញទៀត!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្តទៅទៀត។ អម្បាញ់មិញនេះ ខ្ញុំនិយាយអំពីឯកសារ E3/2956 ជាបញ្ជីអ្នកទោស ស-២១ នៅភូមិភាគឧត្តរពីថ្ងៃទី០១ ខែកុម្ភៈ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៧។ បញ្ជីនេះមានឈ្មោះអ្នកទោស៩៤នាក់ ដែលជាកម្មាភិបាលនៃភូមិភាគឧត្តរមកពីភូមិភាគ។ ជាពិសេស គឺមកពីមន្ទីរ និងក្រសួងពាណិជ្ជកម្ម ខាងឧស្សាហកម្ម សិប្បកម្ម កសិកម្ម ហើយនិងសាធារណការ។ ក្នុងនោះ យើងឃើញមានឈ្មោះប្រធានសាធារណការ គឺជាប្រធានទី១ គឺឈ្មោះ យ៉ឹក ហុង ហៅ ខឹម គឺលេខរៀងទី១០ គាត់ត្រូវបានចាប់នៅថ្ងៃទី១៨ កុម្ភៈ ១៩៧៧។ អនុប្រធានរបស់គាត់គឺនៅលេខរៀងទី១១។ មានកម្មាភិបាលដែលមកពីកងពល១១៧ ពីចម្ការកៅស៊ូ ពីតំបន់៤១, ៤២, ៤៣ និងមកពីស្រុកផ្សេងៗ ដែលក្នុងនោះមានស្រុកបារាយណ៍ និងស្រុកសន្ទុក ដែលជាស្រុកនៅជិតនឹងការដ្ឋានទំនប់នោះ។ ក្នុងនោះ យើងឃើញមានលេខា និងអនុលេខានៃស្រុកទាំងអស់នោះ មាននៅលេខរៀងទី៦៦, ៦៧, ៨១ និង៨២ នៅក្នុងបញ្ជីនេះ។

[០៩:២៩:០១]

យើងមានឯកសារមួយទៀតគឺ E3/3861 ជាបញ្ជីសម្លាប់មនុស្សនៅ ស-២១ ដែលមានចំណងជើងថា "បញ្ជីអ្នកទោសភូមិភាគឧត្តរ កម្ទេចនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៧៧"។ បញ្ជីនោះមានរៀបរាប់ឈ្មោះ មុខងារ ថ្ងៃចូលស-២១ របស់កម្មាភិបាល១៧៣នាក់មកពីភូមិភាគឧត្តរចាស់ ដែលចូលមកមន្ទីរស-២១ ក្នុងចន្លោះខែកុម្ភៈ និងខែមិថុនា ឆ្នាំ១៩៧៧។

សម្រាប់ជាប្រតិចារឹក ខ្ញុំសូមលើកឡើងនូវបញ្ជីមួយចំនួនទៀត គឺនៅឆ្នាំ១៩៧៧ ពីព្រោះថានៅពេលនោះ គឺមានការបោសសម្អាតជាបន្តបន្ទាប់។ នៅក្នុងបញ្ជីនោះគឺបញ្ជីមួយដែលមានលេខ E3/2166 យើងឃើញមានឈ្មោះប្រធានទី២ នៃការដ្ឋានទំនប់១មករា គឺជាប្រធានសាធារណការនៃភូមិភាគដែលហៅថា សោ ឈ្មោះថា សោ ឬក៏ឈ្មោះ យ៉ាប់ យ៉ន ហៅ សោ។ ចម្លើយសារភាពរបស់គាត់ត្រូវបានលើកឡើងតាំងពីមុនរួចមកហើយ គឺលេខ E3/7414។ នៅក្នុងបញ្ជី E3/2166 ឈ្មោះគាត់គឺស្ថិតនៅលេខរៀងទី៦ គេបញ្ជាក់ថាគាត់បានចូល ស-២១ នៅថ្ងៃ២០ កញ្ញា ១៩៧៧ គឺគាត់នេះហើយដែលអៀង ផាន់ បានជំនួសនៅការដ្ឋានទំនប់១មករា។ ចុងក្រោយគឺមានបញ្ជីមួយទៀតគឺ E3/2165 ជាបញ្ជីអ្នកទោស ស-២១ ចុះខែវិច្ឆិកា ឆ្នាំ១៩៧៧ បញ្ជីនេះក៏មានឈ្មោះកម្មាភិបាលជាច្រើនដែលមកពីភូមិភាគឧត្តរ។

[០៩:៣១:១៧]

ខ្ញុំនឹងបញ្ចប់ការបង្ហាញរបស់ខ្ញុំ ដោយលើកឡើងអំពីទស្សនកិច្ចរបស់គណៈប្រតិភូបរទេសនៅទំនប់១មករា។ ជាដំបូងគឺខ្ញុំសូមបង្ហាញនូវឯកសារលេខ E3/2410 ជាអត្ថបទដែលមានចំណងជើងថា “កញ្ចក់មុខពីរ” ដែលបានចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានស្តីពីកម្ពុជា ចុះខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៨។ អ្នកនិពន្ធគឺប្រហែលជា ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ ក៏ប៉ុន្តែអត្ថបទនេះមិនមានហត្ថលេខារបស់គាត់ទេ។ នៅទំព័រ ១៩ ជាភាសាបារាំង, ២៨ ជាភាសាអង់គ្លេស និង៤០ ជាភាសាខ្មែរ គាត់បានសរសេរដូចតទៅ ពាក់ព័ន្ធទៅគណៈប្រតិភូបរទេស។ ខ្ញុំសូមដកស្រង់ “កម្មវិធីនៃដំណើរទស្សនកិច្ចដែលរៀបចំចំពោះគណៈប្រតិភូទាំងអស់នេះ សឹងតែមានលក្ខណៈដូចគ្នាទាំងស្រុង ពោលគឺក្រោយពីបានធ្វើការទស្សនារោងចក្រមួយ ឬពីរនៅជាយក្រុងភ្នំពេញមក គណៈប្រតិភូត្រូវអញ្ជើញទៅទស្សនកិច្ចនៅខេត្តតាកែវ ដោយទស្សនាសហករណ៍អង្គខ្នុរ និងសហករណ៍នៅលាយបូរ”។

ខ្ញុំរំលងកន្លែងមួយចំនួន ខ្ញុំចូលទៅបន្តទៀត៖ “បន្ទាប់មកទៀត គណៈប្រតិភូវិលត្រឡប់មកទីក្រុងភ្នំពេញវិញ ហើយធ្វើដំណើរឆ្ពោះទៅក្រុងអង្គរ ដោយឆ្លងកាត់តាមបាត់ដំបង និងស៊ីសុផុនតាមរយៈរថភ្លើង ឬរថយន្ត។” រំលងបន្តិច ខ្ញុំសូមដកស្រង់បន្តទៀត៖ “នៅតាមផ្លូវវិលត្រឡប់មកវិញ គណៈប្រតិភូត្រូវបញ្ឈប់ដំណើរដើម្បីទៅទស្សនាទំនប់១មករា និងទំនប់៦មករា ស្ថិតនៅក្នុងស្រុកបារាយណ៍ ហើយទស្សនារោងចក្រចម្រាញ់ជ័រកៅស៊ូនៅចម្ការអណ្តូង។ មុននឹងអញ្ជើញទៅធ្វើដំណើរទស្សនកិច្ចគណៈប្រតិភូត្រូវបានទទួលស្វាគមន៍យ៉ាងឱឡារិកពីសំណាក់នាយករដ្ឋមន្ត្រី ប៉ុល ពត។” ដូច្នេះទំនប់

១មករា និង៦មករានេះ គឺស្ថិតនៅក្នុងសមិទ្ធិផលរបស់របបនោះ ដែលត្រូវបានបង្ហាញជូនដល់គណៈប្រតិភូបរទេស។

[០៩:៣៣:៣៥]

សម្រាប់ជាប្រតិចារឹក ខ្ញុំសូមផ្ដល់នូវបញ្ជីដែលបង្ហាញអំពីគណៈប្រតិភូមួយចំនួនដែលបានទស្សនកិច្ចនៅទំនប់១មករា ហើយខ្ញុំនឹងបង្ហាញអំពីកាលបរិច្ឆេទ និងលេខយោងឯកសារ។ ខ្ញុំនឹងទៅឲ្យលឿនបន្តិច ដំបូងគឺមានការទស្សនកិច្ចនៅដើមខែកុម្ភៈ ឆ្នាំ៧៧ គឺពេលចាប់ផ្ដើមការងារដំបូង គឺអ្នកកាសែតកូរ៉េខាងជើង។ ឯកសារគឺ E3/284 ជារបាយការណ៍របស់ហ្វីប៊ីស ជាភាសាអង់គ្លេសគឺមានលេខ ERN 00168413។ មិនទាន់មានការបកប្រែជាភាសាបារាំង និងភាសាខ្មែរនៅឡើយទេ។ បន្ទាប់មកទៀតមានអ្នកសារព័ត៌មានរ៉ូម៉ានី ដែលបានទស្សនកិច្ចនៅទំនប់នោះ គឺនៅថ្ងៃទី០៥ ខែមេសា ១៩៧៧ នៅពេលដែលទំនប់កំពុងតែសាងសង់ គឺឯកសារ E3/286 ទំព័រភាសាអង់គ្លេសគឺ 00168194។ បន្ទាប់មកទៀតមានគណៈប្រតិភូសហភាពស្ត្រីស្នេហាជាតិឡាវ ដែលដឹកនាំដោយស្រី ខាំផែង បូផា។ យើងបានបង្ហាញរូបថតនៃទស្សនកិច្ចនេះ ដែលមានអមដំណើរដោយ អៀង ធីរិទ្ធ ផងដែរជូនសាក្សីមួយរួចមកហើយ។ ហើយនៅក្នុងនោះគឺឯកសារ E3/286 ចុះថ្ងៃទី២៦ ទៅដល់២៥ ខែមេសា ឆ្នាំ១៩៧៧ ជាភាសាបារាំងគឺ 00701453 ទៅដល់ 54, ERN ជាភាសាអង់គ្លេស 00168253, ERN ជាភាសាគឺ 00681225 ទៅដល់ 26។ នៅក្នុងអត្ថបទនោះមានការបញ្ជាក់ដូចតទៅ ខ្ញុំសូមដកស្រង់៖ “កម្មករកសិកររាប់ម៉ឺននាក់ប្រឹងប្រែងធ្វើការសាងសង់ទំនប់ និងជីកប្រឡាយនៅការដ្ឋាននោះ។” សូមបញ្ចប់ការដកស្រង់។

[០៩:៣៦:០២]

បន្ទាប់មកទៀតមានទស្សនកិច្ចរបស់អនុរដ្ឋមន្ត្រី គីម យ៉ុង យ៉ុល មកពីកូរ៉េខាងជើង គឺនៅថ្ងៃទី១៧ ទៅដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៨ គឺឯកសារ E3/293 ERN ជាភាសាអង់គ្លេសគឺ 00169739 ទៅដល់ 40។ តមកទៀតគឺឯកសារ E3/75 គឺមានគណៈប្រតិភូបីដែលបានមកទស្សនកិច្ច។ ទី១ គឺគណៈប្រតិភូបក្សកម្មករម៉ាក្សស៊ីស-ឡេនីន ដាណឺម៉ាក គឺនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ៧៨ ជាភាសាអង់គ្លេសគឺ 00168945។ ទី២ គឺគណៈប្រតិភូនៃសមាគមបែលហ្សិក-កម្ពុជាដែលដឹកនាំដោយលោក ហ្វ្រង់ស្វ័រ រីហ្គ្គដ៍ គឺនៅដើមខែសីហា ឆ្នាំ១៩៧៨ ហើយឯកសារដដែលគឺអង់គ្លេសគឺ 00168941។ ជាចុងក្រោយ គឺសមាគមមិត្តភាពស៊ុយអែត-កម្ពុជា ដែលដឹកនាំដោយលោក ហ្គុនណា ប៊ីយស្ត្រមគឺនៅចុង

ខែសីហា ឆ្នាំ១៩៧៨ ជាភាសាបារាំងគឺ ERN 00 (សូមទោស) គឺ 01074580, ជាភាសាអង់គ្លេស 00169017។ អ្វីដែលសំខាន់នៅក្នុងអត្ថបទនោះ គឺមានការបញ្ជាក់ថានៅខែសីហា ឆ្នាំ១៩៧៨ កសិករ រាប់ពាន់នាក់នៃសហករណ៍ខិតខំប្រឹងប្រែង ដើម្បីសម្រេចផែនការសាងសង់ទំនប់៦មករា។

នៅមានឯកសារជាច្រើនទៀត ក៏ប៉ុន្តែខ្ញុំសូមបង្ហាញតែមួយចំនួនទេគឺ E3/76 ដែលនិយាយអំពី ទស្សនកិច្ចរបស់គណៈប្រតិភូបក្សកុម្មុយនីស្តបារាំង និងគណៈប្រតិភូសារព័ត៌មានតួកគី អាយឌីនលីក នៅថ្ងៃទី១៣ កញ្ញា ១៩៧៥។ ERN ជាភាសាអង់គ្លេសគឺ 00170396 មានការបញ្ជាក់ថា ពួកគាត់បាន ទស្សនកិច្ចទំនប់១មករា និង៦មករា។ ខ្ញុំសូមដកស្រង់៖ “ប្រជាជនសហករណ៍រាប់ពាន់នាក់ខិតខំប្រឹង ប្រែងធ្វើការដើម្បីបញ្ចប់ការសាងសង់។” នៅឯកសារដដែលគឺ E3/76 នៅចុងខែកញ្ញាគឺមានសមាគម មិត្តជប៉ុន-កម្ពុជា មកទស្សនកិច្ចនៅទំនប់ដែរគឺ ERN ជាភាសាអង់គ្លេស 00170431។

[០៩:៣៩:០៥]

ឯកសារពីរចុងក្រោយ ទី១គឺ E3/294 ដែលបង្ហាញអំពីទស្សនកិច្ចរបស់បក្សកុម្មុយនីស្តន័រវែស នៅថ្ងៃទី២៦ កញ្ញា ឆ្នាំ៧៨ ERN ជាភាសាអង់គ្លេសគឺ 00170186។ ឯកសារចុងក្រោយ គឺមាន ទស្សនកិច្ចប្រាំនៅខែធ្នូ ឆ្នាំ១៩៧៨ គឺឯកសារ E3/295។ ទី១ គឺគណៈប្រតិភូបក្សកុម្មុយនីស្តអាល្លឺម៉ង់ ខាងលិច ដឹកនាំដោយលោកឈ្មោះ *(ឮមិនច្បាស់)* គឺនៅខែធ្នូ ឆ្នាំ៧៨ គឺឯកសារជាភាសាអង់គ្លេស 00169084។ នៅថ្ងៃទី០៧ ធ្នូ ៧៨ គឺមានគណៈប្រតិភូពាណិជ្ជកម្មក្រៅប្រទេសចិន ដែលដឹកនាំដោយ ចេង ជា គឺនៅទំព័រអង់គ្លេស គឺ 00169074 ជាភាសាអង់គ្លេស។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ៧៨ គឺគណៈ ប្រតិភូបក្សពលករជប៉ុន បានមកទស្សនកិច្ចនៅទំនប់នោះ គឺជាទំព័រជាភាសាអង់គ្លេសគឺ 00169118 ដល់ 19។ នៅពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៨នោះ គឺមានទស្សនកិច្ចរបស់សាស្ត្រាចារ្យ ខាត់វែល និង អ្នកសារព័ត៌មាន ឌុដម៉ាន និង អេលីហ្សាបេត បេកយ័រ គឺនៅឯកសារដដែល E3/295 ទំព័រជាភាសា អង់គ្លេសគឺ 00169169។ និងជាចុងក្រោយ គឺនៅថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៨ គឺមាន ទស្សនកិច្ចរបស់គណៈប្រតិភូរ៉ូម៉ានី គឺនៅទំព័រជាភាសាអង់គ្លេស 00169158។

ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារ ហើយខ្ញុំគិតថា ទស្សនកិច្ចរបស់គណៈប្រតិភូបរទេសជាច្រើន ហ្នឹង បង្ហាញឲ្យឃើញថាការដ្ឋាននេះមានសារៈសំខាន់ណាស់នៅក្នុងខ្សែភ្នែករបស់បក្ស។ ដូច្នេះ ខ្ញុំសូម អនុញ្ញាតឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញឯកសាររបស់គាត់ពាក់ព័ន្ធនឹងទំនប់ ១មករាសិន ទើបយើងនឹងបង្ហាញបន្តទៅទៀតពាក់ព័ន្ធទៅនឹងការដ្ឋានការសាងសង់ព្រលានយន្តហោះ

កំពង់ឆ្នាំង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណើមួយទៅសហព្រះរាជអាជ្ញា តើលោកអាចផ្តល់លេខ ERN ឲ្យជាមុនទេចំពោះឯកសារដែលលោកចង់ប្រើប្រាស់នោះ? ព្រោះថាពេលខ្លះ យើងមានតែលេខយោង។ អ៊ីចឹងដើម្បីឲ្យភាគីបានដឹងច្បាស់ថា លោកសំដៅទៅលើផ្នែកណានៃឯកសារដែលលោកចង់ប្រើប្រាស់នោះ សូមឲ្យលោកផ្តល់លេខជាមុនមក ផ្តល់លេខERN ហើយការរៀបរាប់លេខរៀងនេះ គឺថាវាគួរឲ្យធុញទ្រាន់ណាស់ បើយើងឲ្យជាបន្តបន្ទាប់អ៊ីចឹង។ អ៊ីចឹងសូមឲ្យលេខ ERN ជាមុនមក បញ្ជាក់ឲ្យបានច្បាស់ជាមុនមក អ៊ីចឹងវាធ្វើឲ្យយើងងាយស្រួលជាង។ ហើយបើសិនជាឲ្យខ្ញុំកត់តាមលេខលោករហូតអ៊ីចឹង គឺវាធុញណាស់។

[០៩:៤២:៤០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកចៅក្រម។ យើងពិតជាមានហើយ ខ្ញុំគិតថា អ្នកបកប្រែគាត់មានលេខយោងហ្នឹងហើយ ហើយខ្ញុំនឹងផ្តល់ជូនភាគីទាំងអស់ នៅក្នុងថ្ងៃហ្នឹងពាក់ព័ន្ធទៅនឹងទស្សនកិច្ច។ ហើយចំពោះឯកសារផ្សេងទៀតនោះ ខ្ញុំមិនដឹងថា តើយើងនឹងមានការផ្លាស់ប្តូរឯកសារ ឬក៏យ៉ាងម៉េចទេ យើងពិបាកឲ្យលេខ ERN មុនណាស់។ ក៏ប៉ុន្តែយើងនឹងពិចារណាចំពោះសំណើរបស់លោកចៅក្រម សម្រាប់ការបង្ហាញលើកក្រោយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី សាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងទំនប់១មករា ដែលមានលំដាប់លំដោយដូចតទៅ។ ក៏ប៉ុន្តែជាបឋម ខ្ញុំ

សូមជម្រាបថា ឯកសារដែលខ្ញុំលើកមានចំនួន -- ទាំងអស់នោះ គឺជាពិសេសពាក់ព័ន្ធទៅនឹងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺយើងបានស្នើសុំឲ្យមានការបកប្រែហើយ ហើយឯកសារខ្លះមានការបកប្រែ ហើយឯកសារខ្លះទៀតមិនទាន់មានការបកប្រែ ក៏ប៉ុន្តែយើងបានរំពឹងថា ការបកប្រែឯកសារទាំងអស់នោះនឹងត្រូវបានធ្វើនៅខែមិថុនា ៣០ – ថ្ងៃទី៣០ ខែមិថុនា កន្លងផុតទៅនេះ ក៏ប៉ុន្តែយើងពុំទាន់បានទទួលឯកសារបកប្រែនោះនៅឡើយទេ។ ដូច្នេះប្រសិនបើថា ខ្ញុំមិនបានអាន ERN ជាភាសាបារាំង ឬក៏ជាភាសាអង់គ្លេស គឺមានន័យថា ជាឯកសារដែលយើងបានស្នើសុំឲ្យមានការបកប្រែរួចហើយ។

[០៩:៤៤:៤៣]

បាទជាបឋម ឯកសារដំបូង គឺជាឯកសារដែលមានលេខ E3/6850 ជាឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉យ លន់។ នៅក្នុងឯកសាររបស់គាត់ ដែលមាន ERN ជាភាសាខ្មែរ 00570948 មិនមាន ERN ជាភាសាអង់គ្លេស ឬភាសាបារាំងទេ។ លោក ម៉យ លន់ ដែលបានទៅធ្វើការនៅទំនប់១មករា បាននិយាយថា៖ "ក្នុងឆ្នាំ១៩៧៦ ដល់៧៧ ខ្ញុំបាទ និងកូន ប្រពន្ធត្រូវបានពួកខ្មែរក្រហមបង្ខំឲ្យទៅធ្វើការលើកទំនប់កាត់ស្ទឹងជីនិត ដែលមានឈ្មោះថាទំនប់១មករា និងទំនប់៦មករា និងធ្វើស្រែ បង្អត់អាហារ ឈឺថ្កាត់ គ្មានថ្នាំសង្កូវព្យាបាលទេ។ ពួកខ្មែរក្រហមបង្ខំឲ្យធ្វើការងារ គ្មានថ្ងៃឈប់សម្រាក់ទេ។ ក្នុងមួយថ្ងៃធ្វើការ ប្រហែលជា១៦ទៅ១៨ម៉ោង។" លោក ម៉យ លន់ បានបន្ថែមទៀតថា៖ "ក្នុងឆ្នាំ១៩៧៨ ខ្ញុំបាទត្រូវបានកម្មាភិបាលខ្មែរក្រហមឈ្មោះ នារីភឿក ចាប់យកទៅបម្រុងសម្លាប់ចោលនៅភូមិត្នោតជុំ ឃុំត្នោតជុំ ស្រុកបារាយណ៍ ប៉ុន្តែសំណាងល្អវាដោះលែងមកវិញ។"

ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ដែលមានលេខឯកសារ E3/6015 ជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះ គីម ហួន ភេទស្រី ERN នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ជាភាសាខ្មែរគឺ 00496987 ដល់ 88, ERN ជាភាសាអង់គ្លេស 00893526 ដល់ 27, ERN ជាភាសាបារាំង 00923453 ដល់54។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណីបានលើកថា ខ្ញុំសូមដកស្រង់៖ "នៅរដូវប្រាំងចុងឆ្នាំ១៩៧៦ គេបញ្ជូនខ្ញុំទៅការដ្ឋាន១មករា លើកទំនប់ លើកថ្ម ស្នាក់នៅវត្តត្រពាំងជ្រៃ ភូមិព្រៃស្រងែ ឃុំកំពង់ថ្ម ស្រុកសន្ទុក (ព្រំប្រទល់ជាប់ស្រុកបារាយណ៍) មានចម្ងាយ១គីឡូម៉ែត្រពីការដ្ឋានធ្វើការ ទាំងយប់ ទាំងថ្ងៃ។ គេដាក់ផែនការសម្រុកឲ្យហើយក្នុងរយៈពេលមួយខែកន្លះ។ អាហារគឺទទួលបានបាយខ្លះ បបរខ្លះ (បបររាងខាប់បន្តិច)។ នៅពេលចប់នៅខែប្រាំងដដែល តែចូលឆ្នាំ១៩៧៧ រួចត្រឡប់មកជាមួយមិត្តនារីពេទ្យវិញ។ បន្ទាប់មកនៅខែមីនា មេសា ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានបញ្ជូនទៅ

ការដ្ឋានវត្តសំរោង ភូមិសំរោង ឃុំបារាយណ៍ ស្រុកបារាយណ៍ ធ្វើការជីកប្រឡាយ។ ផែនការពេលនោះគឺក្នុងម្នាក់ៗ ក្នុងមួយថ្ងៃជីកប្រឡាយយកដីលើកទំនប់ប្រវែង៦ម៉ែត្រ ទទឹង១ម៉ែត្រនិងកម្ពស់០.៧ម៉ែត្រ។ របបហូបចុកទទួលបានបាយមួយវែក សម្លប្រហើរមួយចាន គ្នាប្អូនប្រាំនាក់។ សម្លមានត្រីមួយកង់ ទៅពីរកង់ ជួនកាលហូបជាមួយទឹកប្រហុក អន្លក់ត្រួយកណ្ដោល។ ពេលនៅការដ្ឋាននោះហើយដែលឈ្មោះ ឈឹម ស៊ីណាង (ប្ដីខ្ញុំសព្វថ្ងៃ) លួចស្រឡាញ់ខ្ញុំ បន្ទាប់មកមានមិត្តភក្តិប្រុសៗចំអន់ខ្ញុំ តែខ្ញុំមិនដឹងខ្លួនទេ (ខ្ញុំដឹងពីគាត់និយាយប្រាប់ពេលរៀបការហើយ) ហើយពេលនោះ គ្មានការជួបសាសាងគ្នា ឬទាក់ទងស្រឡាញ់គ្នាមុនទេ វាខុសសីលធម៌។ នៅចុងឆ្នាំ១៩៧៧ ខែច្រូតរួច (ខែមាឃ-បុស្ស) ខ្ញុំត្រូវទៅជីកប្រឡាយនៅការដ្ឋានភូមិពោធិ៍ខ្ពុំ ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ជាប្រឡាយដែលបន្តពីទំនប់១មករាមក។ ការហូបចុកពេលនោះស្រដៀងគ្នានៅការដ្ឋានវត្តសំរោងដែរ (ការដ្ឋានទំនប់១មករា)។

[០៩:៥១:១៤]

ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ មានលេខឯកសារ E3/6324a ជាឯកសារព័ត៌មានបន្ថែមរបស់លោកស្រី ឈឹម រីន ERN ជាភាសាខ្មែរ 00580542, ជាភាសាអង់គ្លេស 00866864 និងជាភាសាបារាំង 01132692។ នៅក្នុងសម្រង់របស់លោកស្រីបាននិយាយដូចតទៅ ខ្ញុំសូមលើកសម្រង់នេះ៖ “នៅក្នុងឆ្នាំ១៩៧៨ រូបខ្ញុំត្រូវបានពួកខ្មែរជម្លៀសឱ្យទៅធ្វើការនៅទំនប់១មករា ស្ទឹងជីនិត ដោយសាររូបខ្ញុំប្រកែកមិនព្រមរៀបការ ដោយប្ដីខ្ញុំនៅរស់។ នៅការដ្ឋានស្ទឹងជីនិតនេះលំបាកណាស់ គេឱ្យរែកដី ម្នាក់២ម៉ែត្រគូបក្នុងមួយថ្ងៃ។ ក្នុងមួយនាក់បង្គីពីរគូក្នុងម្នាក់។ ចាប់ផ្ដើមរែកដីពីម៉ោងប្រាំមួយព្រឹក រហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់។ ពួកវាឱ្យហូបបាយរីកៗជាមួយសម្លដើមចេក។ បង្គីដែលរែកនោះធំៗណាស់ ដាក់ដីទូញ រួចហើយឡើងជាន់ពីលើ។ ពេលចូលរែក ងើបពីរទៅបីដងបានរួច ហើយដី២ម៉ែត្រគូប បើធ្វើមិនរួច ពេលយប់ធ្វើទៀត។ ពេលបាយរីកៗនោះស៊ីសល់ ពួកវាទៅហាលនៅជិតបង្គន់ ដង្កូវវាចូលរួច យកមកបបរឱ្យពួកយើងខ្ញុំស៊ីទៀត។ រូបខ្ញុំនៅលើកទំនប់១មករាបានមួយឆ្នាំ គេក៏បញ្ជូនមកនៅភូមិតាំងក្រសាំងវិញ។” នៅក្នុងឯកសាររបស់លោកស្រីដែលមាន ERN (បាទសូមទោស) ដែលមានលេខ E3/6324 ERN ជាភាសាខ្មែរ 00533402, ERN ជាភាសាអង់គ្លេស 01066660 មិនមាន ERN ជាភាសាបារាំងទេ។ លោកស្រីបាននិយាយដូចតទៅ ខ្ញុំសូមលើកសម្រង់នេះ៖ “នៅពេលគេរៀបរយហើយ គេឱ្យខ្ញុំធ្វើរោងស្រូវ ឱ្យធ្វើជី លើកប្រឡាយ និងលើកដីដាក់ទំនប់១មករា (នៅជិតភូមិ) ទាំងមានផ្ទៃពោះ ៧ខែ។ ពេលនោះ ខ្ញុំមិនដឹងថាប្ដីខ្ញុំយ៉ាងណាទេ។”

[០៩:៥៥:២១]

ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ដែលមានលេខឯកសារ E3/6810a គឺជាព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ កន រុំ ភេទស្រី។ ERN ជាភាសាខ្មែរ 00588434, ERN ភាសាបារាំង 00588431 មិនមាន ERN ជាភាសាអង់គ្លេសទេ។ លោកស្រីបានលើកដូចតទៅ ខ្ញុំសូមដកស្រង់សម្រង់៖ "ប្រហែលជានៅចុងឆ្នាំ១៩៧៦ គេឲ្យខ្ញុំទៅរែកដីនៅកងចល័តនៅការដ្ឋានកំពង់ថ្ម។ ឯប្អូនទាំងពីររបស់ខ្ញុំត្រូវបានជម្លៀសមកនៅភូមិតារាមវិញ។ មានតែខ្ញុំទេដែលត្រូវទៅធ្វើការរែកនៅការដ្ឋានកំពង់ថ្មនៅតាំងក្រសាំង។ គេឲ្យរែកឲ្យបានកន្លះម៉ែត្រគូបក្នុងមួយថ្ងៃ។ ខ្ញុំត្រូវកាប់ដីដាក់បង្គី ហើយរែកយកទៅចាក់លើខ្នងទំនប់កំពង់ថ្ម។ ខ្ញុំឃើញមានក្មេងៗវ័យប៉ុនខ្ញុំធ្វើការនៅទីនោះ ប្រហែលជា៣០០នាក់តាមខ្ញុំរាប់។ ឯមនុស្សចាស់ក៏មានច្រើនដែរ ខ្ញុំរាប់មិនអស់ទេ ព្រោះការដ្ឋាននោះធំល្វឹងល្វើយណាស់ មើលទៅឃើញសុទ្ធតែមនុស្ស។ ពេលត្រូវបរិភោគ គេផ្លុំកញ្ចែ បើរត់ទៅទាន់គេ ទើបបានបបរហូប។ គេត្រូវសង្កត់ដីខ្នងទំនប់ឲ្យហាប់ដើម្បីកុំឲ្យទឹកហូរចេញ។ គេបានធ្វើអាងធំមួយដើម្បីឲ្យចាក់ស៊ីម៉ង់ត៍ ដើម្បីទប់បើកបិទទឹកចេញចូល។ អាងនេះមានទទឹងប្រហែល១២ម៉ែត្រ។ ក្នុងអំឡុងពេលធ្វើការនៅការដ្ឋាន ខ្ញុំត្រូវស្នាក់នៅក្នុងកងចល័តនៅការដ្ឋានកំពង់ថ្ម នៅតាំងក្រសាំងនោះ។ នៅរៀងរាល់ម៉ោងបីព្រឹក គេដើរផ្លុំកញ្ចែដាស់ឲ្យងើបធ្វើការ។ ធ្វើរហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបហូបបបររាវមួយវែកលាយត្រកួន។ ហើយម៉ោងមួយថ្ងៃត្រង់ ត្រូវធ្វើបន្តរហូតដល់ម៉ោងប្រាំ ញ៉ាំបបរម្តងទៀតហើយដេកតែម្តង។ ខ្ញុំឃើញគេធ្វើបាបមនុស្សញ៉ាំមិនឆ្អែត ហើយទីបំផុតមនុស្សនោះបានចងកសម្លាប់ខ្លួន។"

[០៩:៥៨:៥២]

ឯកសារចុងក្រោយរបស់ខ្ញុំដែលនឹងខ្ញុំអានជូន ពេលនេះមិនមែនជាឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ វាជាឯកសារទទួលចម្លើយរបស់សាក្សីដែលមានលេខ E3/9350។ បុគ្គលរូបនោះដែលបានសម្ភាស បាននិយាយនៅក្នុងឯកសាររបស់គាត់ ដែលមាន ERN ជាភាសាខ្មែរ 00239949, ជាភាសាបារាំង 00274344, ជាភាសាអង់គ្លេស 00244169 និងបន្តបន្ទាប់ ដែលលោកស្រីបានឆ្លើយនឹងសំណួរដូចតទៅ "សំណួរ៖ តើលោកស្រីមានដឹងពីការលើកទំនប់១មករាដែរឬទេ? ឆ្លើយ៖ ខ្ញុំបានចូលរួមក្នុងការលើកទំនប់១មករា ប៉ុន្តែខ្ញុំមិនចាំថា ទំនប់នោះចាប់ផ្តើមលើកពីឆ្នាំណាទេ។ សំណួរបន្ទាប់ សួរ៖ តើលោកស្រីមានចាំថា ការលើកទំនប់នោះមានមនុស្សចូលរួមប្រហែលប៉ុន្មាននាក់ទេ? ឆ្លើយ៖ ខ្ញុំឃើញមានមនុស្សច្រើនចូលរួមលើកទំនប់ តែខ្ញុំមិនមានចាំថា មានចំនួនប៉ុន្មាននាក់ទេ។ រំលងមួយសំណួរ

សំណួរបន្ទាប់ សួរ៖ សូមលោករៀបរាប់ពីសកម្មភាពលើកទំនប់១មករា? ឆ្លើយ៖ គេប្រើខ្ញុំឱ្យលើកទំនប់ដោយកំណត់ឱ្យជីកដី រែកនឹងបង្គីដាក់ខ្នងទំនប់ មួយថ្ងៃឱ្យបាន១ម៉ែត្រគូប។ ក្នុងករណីដែលធ្វើមិនគ្រប់តាមផែនការដែលគេដាក់ឱ្យ គេនឹងយកទៅប្រជុំណែនាំកសាង។ ការប្រជុំគេធ្វើច្រើន ធ្វើនៅពេលយប់សម្រាកពីការងារ ហើយភាគច្រើនហៅតែអ្នកដែលធ្វើមិនគ្រប់ផែនការប៉ុណ្ណោះ។ ចំពោះខ្ញុំវិញ ខ្ញុំធ្លាប់បានគេហៅទៅប្រជុំកសាងពីរដងដែរ។ ក្នុងការប្រជុំកសាង គេបាននិយាយថា បើមិត្តឯងធ្វើមិនគ្រប់ផែនការទេ មិត្តឯងត្រូវប្រយ័ត្ន។ ពេលនោះខ្ញុំមិនដឹងអំពីអត្ថន័យនៃពាក្យនេះទេ តែខ្ញុំខស្បាហ៍ចុកជើងបានជាខ្ញុំធ្វើមិនគ្រប់ផែនការ។ ម្យ៉ាងទៀត ខ្ញុំខិតខំធ្វើការទាំងឈឺ ទាំងជា ព្រោះខ្ញុំខ្លាចគេ។ អ្នកដែលមកហៅខ្ញុំនោះ គាត់ជាមេកងនៅក្នុងការដ្ឋានលើកទំនប់នោះ។ នៅក្នុងការដ្ឋានមានអ្នកដើរត្រួតពិនិត្យនៅពេលកំពុងធ្វើការ ហើយក្នុងករណីអ្នកណាធ្វើការមិនគ្រប់ផែនការ ឬខ្ជិលច្រអូស គេនឹងរាយការណ៍ទៅថ្នាក់លើដើម្បីឱ្យប្រធានកងមកហៅទៅប្រជុំណែនាំកសាង។"

[១០:០២:៤៣]

ក្នុងឯកសារដដែល គឺឯកសារ E3/9350 ERN ជាភាសាខ្មែរ 00239951, ERN ជាភាសាអង់គ្លេស 00244170, ERN ជាភាសាបារាំង 00274345។ លោកស្រីបានឆ្លើយនឹងសំណួរដូចតទៅ៖ "សួរ៖ តើនៅក្នុងការដ្ឋានមានអ្នកឈឺដែរឬទេ? ឆ្លើយ៖ នៅក្នុងការដ្ឋាន គឺគ្មានអនាម័យទេ គ្មានបង្គន់សម្រាប់បន្ទោបង់។ នៅពេលដែលយើងចង់បត់ដៃ បត់ជើង យើងទៅក្នុងព្រៃ ហើយនៅកន្លែងស្នាក់នៅនោះ មានរុយច្រើនណាស់សុទ្ធតែជារុយក្បាលខៀវ។ មានអ្នកឈឺច្រើន ជំងឺភាគច្រើនជាជំងឺរាករូសរាកមួល (សូមទោស) ជាជំងឺរាកមួល គ្រុន ជំងឺអាសន្នរោគ ។ល។ នៅតាមរោងនីមួយៗមានពេទ្យនៅប្រចាំការ ហើយពេលមានអ្នកឈឺ គេចែកថ្នាំមូលៗ ដូចអាចម៍ទន្សាយ។ ថ្នាំនោះលេបទៅជាខ្លះ មិនជាខ្លះ។ ប៉ុន្តែជំងឺអីក៏គេឱ្យថ្នាំអាចម៍ទន្សាយនោះដែរ និងមានចាក់ថ្នាំដែរ ហើយដបវាមានរាងដូចដបទឹកក្រូច។ មានអ្នកស្លាប់ដោយសារជំងឺម្នាក់នៅក្នុងការដ្ឋាននោះ ខ្ញុំបានឃើញផ្ទាល់ភ្នែក ប៉ុន្តែមិនមែននៅក្នុងក្រុមរបស់ខ្ញុំទេ ហើយខ្ញុំក៏មិនចាំឈ្មោះអ្នកស្លាប់នោះដែរ។ នៅក្នុងការដ្ឋានមនុស្សភាគច្រើន មានសភាពស្គមស្គាំង គឺដោយសារហូបចុកមិនគ្រប់គ្រាន់ និងធ្វើការបាក់កម្លាំង។"

ឯកសារបន្ទាប់គឺជាឯកសារវីដេអូ ដែលមួយចំណែកត្រូវបានផ្ដាប់បញ្ចាំងដោយការិយាល័យសហព្រះរាជអាជ្ញារួចហើយ។ ប៉ុន្តែយើងខ្ញុំចង់បញ្ចាំងផ្នែកដទៃទៀត ដែលនៅសេសសល់ គឺឯកសារ E3/3014R។ វីដេអូនេះបញ្ជាក់អំពីវត្តមាននៃក្មេងៗដែលរែកដី ជាពិសេសនៅវិនាទីទី១៥ និងវិនាទីទី

៣៨ ហើយក៏មានពលករជាច្រើនដែលមិនមានពាក់ស្បែកជើង។ ស្ថានភាពសម្លៀកបំពាក់ មិនសមរម្យទៅតាមភាពជាមនុស្ស។ ការរែកដីមានចម្ងាយឆ្ងាយ ពលកររែកដីដោយរត់ ពលករមិនអាចនិយាយគ្នាបានក្នុងពេលរែកដី ហើយពលករមានចំនួនច្រើន។ ខ្ញុំសូមអនុញ្ញាតលោកប្រធានបញ្ចាំងឯកសារដែលមានលេខ E3/3014R នេះ។

ពេលនេះខ្ញុំឃើញលោក គង់ សំអុន លើក។ សូមលោកប្រធាន -- ងើបឈរ។

[១០:០៧:១៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ លោកប្រធាន។ យើងខ្ញុំអត់មានជំទាស់នឹងការស្នើសុំរបស់សហមេធាវីនាំមុខក្នុងការបញ្ចាំងវីដេអូនេះទេ ក៏ប៉ុន្តែខ្ញុំសូមជំទាស់ទៅនឹងការអត្ថាធិប្បាយរបស់លោក ដែលរៀបរាប់ពីរូបភាពដែលមាននៅក្នុងវីដេអូ ហើយជាពិសេសយើងមិនទាន់បានទាំងបានឃើញវីដេអូនោះផង ហើយការរៀបរាប់នេះ វាបង្ហាញពីលក្ខណៈពីការធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយហើយ។ ដូច្នេះការធ្វើបែបនេះមិនត្រឹមត្រូវទេ។ បាទ សូមអរគុណ។

**លោក ពេជ អង្គ៖**

លោកប្រធានសូមអនុញ្ញាតឲ្យខ្ញុំឆ្លើយចំពោះការកត់សម្គាល់នេះ។ បាទ ជាការពិតដើម្បីងាយស្រួលយល់ទាំងអស់គ្នា ខ្ញុំមិនធ្វើសេចក្ដីសន្និដ្ឋានទេអម្បាញ់មិញ គ្រាន់តែខ្ញុំនិយាយថា នៅក្នុងនោះមានអ្វីខ្លះតែប៉ុណ្ណោះ។ នៅពេលដែលបញ្ចាំងវីដេអូទៅ ងាយស្រួល ហើយយើងចាប់អារម្មណ៍អំពីចំណុចដែលខ្ញុំបានលើកនោះ។ ដូច្នេះសូមប្រធានអនុញ្ញាត ដើម្បីឲ្យអ្នកបច្ចេកទេសបញ្ចាំងវីដអូ ដែលមានប្រវែង -- រយៈពេលបួននាទីនេះ។ សូមលោកប្រធានអនុញ្ញាត។

[១០:០៨:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៩:២៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តើលោកស្នើសុំហ្នឹងតែវិនាទីដែលលោកបានស្នើសុំអំមិញតែវិនាទីទី១៥ ហើយ

និងវិនាទីទី៣៨ ឬក៏បញ្ចាំងទូទៅ ព្រោះកន្លងមកសហព្រះរាជអាជ្ញារងអន្តជាតិហ្នឹង បានដាក់ស្នើសុំបង្ហាញជាលក្ខណៈទូទៅហើយ។ ហើយលក្ខណៈទៅទូទៅនេះ នាំឱ្យមានការជំទាស់តវ៉ាពីខាងក្រុមមេធាវីការពារក្តីលោក នួន ជា ហើយអង្គជំនុំជម្រះបានសម្រេចយល់ព្រមគាំទ្រទទួលយកការជំទាស់ហ្នឹងត្រឹមត្រូវ ហើយសុំឱ្យសហព្រះរាជអាជ្ញា – តំណាងសហព្រះរាជអាជ្ញាបញ្ជាក់ម្តងទៀត។ អ៊ីចឹងសហព្រះរាជអាជ្ញាព្រឹកមិញ គាត់បានបញ្ជាក់អំពីវិនាទីដែលពាក់ព័ន្ធជាមួយនឹងបំណងរបស់គាត់ ដែលមានចំណុចសំខាន់ៗបង្ហាញ ពាក់ព័ន្ធជាមួយនឹងគោលបំណងនៃការដាក់បង្ហាញវីដេអូហ្នឹងរួចហើយនៅនាទីសំខាន់ៗ មិនទូទៅទេ។ ឥឡូវនេះស្រាប់តែលោកស្នើសុំ ទី១ គឺមានតែវិនាទី១៥, ៣៨ វាមិនដឹងថាពីណាទៅណាទេ អាហ្នឹងបញ្ហា១។ ទី២ តើធ្វើទូទៅហ្នឹងឡើងវិញទៀតទេ ឬក៏យ៉ាងម៉េច ព្រោះធ្វើទូទៅហ្នឹង វាអត់មានប្រយោជន៍អីសម្រាប់ដល់ការដោះស្រាយបញ្ហាហ្នឹងទេ ព្រោះដោះស្រាយហ្នឹងស្នើជាក់លាក់ផង ដល់ពេលសុំៗដាក់៤នាទីផង ហើយម្តងបញ្ចាំងម្តងហើយ បង្ហាញម្តងហើយ។ ហើយនៅក្នុងសវនាការកាលពីដេញដោលសាក្សី យើងបានបង្ហាញម្តងហើយ។ ហើយយើងមិនទាន់ពិចារណាទេដែលវាមិនទាន់ដល់ដំណាក់កាលត្រូវពិចារណា មិនទាន់ដឹងថាប្រភពហ្នឹងមកពីណាផងនៃឯកសារនុ៎ង។ វាពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលធ្វើសវនាការដែរឬទេ។ លោកអាចបញ្ជាក់បានទេលើចំណុចនេះ ឱ្យច្បាស់លាស់ ពីព្រោះមិនមែនធ្វើតែប៉ុណ្ណឹងទេ វាអាចទៅមុខទៀតណា?

[១០:១១:២៣]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធានដែលផ្តល់ការណែនាំ។ តាមការពិតខ្ញុំព្យាយាមដើម្បីធ្វើឱ្យមានភាពជាក់លាក់ទៅលើអ្វីដែលខ្ញុំចង់បង្ហាញ។ ពីមុនដែលតំណាងសហព្រះរាជអាជ្ញាបានបង្ហាញនៅសប្តាហ៍មុន គឺជាវីដេអូផ្សេង មិនមែនវីដេអូមួយនេះទេ។ តែវីដេអូមួយនេះត្រូវបានបង្ហាញពី – ខ្ញុំមិនចាំកាលបរិច្ឆេទទេ នៅពេលដែលសហព្រះរាជអាជ្ញាយកប្រើប្រាស់ដើម្បីសួរទៅសាក្សីមួយរូប ខ្ញុំមិនបានចាំឈ្មោះទេ សូមអធ្យាស្រ័យអំពីបញ្ហានេះ។ ហើយមានតែចំណុចមួយនៅក្នុងវីដេអូនោះតែប៉ុណ្ណោះដែលតំណាងសហព្រះរាជអាជ្ញាបានលើក ដើម្បីឱ្យសាក្សីបញ្ជាក់ ដែលនិយាយអំពីចម្ងាយវែងនៃការដើររបស់ពលករតែប៉ុណ្ណោះ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំបង្ហាញនេះ ពាក់ព័ន្ធទៅនឹងក្មេងៗរែកដី គឺខ្ញុំអាចជម្រាបជូនអំពីចំណុចវិនាទីជាក់លាក់ គឺវិនាទីទី១៥ និងវិនាទី៣៨ នៃវីដេអូនេះ។ ប៉ុន្តែពីបញ្ហាទិដ្ឋភាពដែលគ្មានស្បែកជើងរបស់ពលករ គឺវាមានច្រើនកន្លែងនៅក្នុងវីដេអូនោះ។ ចំណែកឯទិដ្ឋភាពសម្លៀកបំពាក់

ការដើរផ្លូវឆ្ងាយ ឬក៏ជិត ការដើររែកដីដោយដើរឬរត់ ឬក៏លទ្ធភាពនៅក្នុងការ -- មានៗពលករដែលថា គាត់អាច គាត់ឈរនៅស្ងៀម ឬក៏ជជែកគ្នានៅក្នុងពេលនោះ ឬក៏មានចំនួនច្រើន ចំនួនតិចនោះ គឺជាទិដ្ឋភាពទាំងមូលតែម្តង ដែលអាចបង្ហាញអំពីអ្វីដែលជាចំណុចដែលខ្ញុំចង់លើកនេះ។ ដូច្នេះទាល់តែអាចមើលវីដេអូទាំង៤នាទីនេះ បានអាចបង្ហាញអំពីទិដ្ឋភាពដូចខ្ញុំបានចង្អុលជូននេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយឱ្យបុគ្គលិកផ្នែកសោតទស្សន៍ ហើយនិងរូបភាព បង្ហាញខ្សែវីដេអូ ដែលមានអត្តសញ្ញាណដូចតាមសំណើសុំរបស់សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១០:១៥:០៩]

*(ការបង្ហាញឯកសារជារូបភាពវីដេអូ)*

[១០:១៥:៤៥]

**លោក ពេជ អង្គ៖**

បាទៗ ដោយសារវីដេអូហាក់ដូចជាខ្លីបន្តិច ប៉ុន្តែមិនអីទេ ខ្ញុំទទួលត្រឹមប៉ុណ្ណឹង ហើយខ្ញុំអត់មានឯកសារសម្រាប់ជម្រាបជូនទៀតទេនៅពេលនេះ ពាក់ព័ន្ធទៅនឹងទំនប់១មករា។ ហើយខ្ញុំសូមថ្លែងអំណរគុណលោកប្រធាន ដែលបានអនុញ្ញាតឱ្យខ្ញុំលើកពីឯកសារគន្លឹះពាក់ព័ន្ធទៅនឹងទំនប់១មករា។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលមកវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៥៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅខាងភាគីសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។

**លោក វីណ្ឌៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សូមជម្រាបសួរលោកមេធាវី ហើយសូមជម្រាបសួរដល់សាធារណជនទាំងអស់។ លោកចៅក្រម នៅព្រឹកនេះគឺថា យើងនឹងធ្វើការបង្ហាញអំពីការដ្ឋានកំពង់ឆ្នាំង។ ហើយខ្ញុំនឹងផ្តោតទៅលើ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថា លោកគួរតែនិយាយឲ្យបានជិតមីក្រូហ្វូនបន្តិច ខាងខ្ញុំពិបាកស្តាប់។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកស្រី។ ខ្ញុំសូមបញ្ជាក់ឡើង តើលោកស្តាប់ខ្ញុំឮទេ? លោកស្រីស្តាប់ខ្ញុំឮទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំអត់ឮទេ តើអ្នកដទៃឮទេ?

**លោក វីណ្ឌៀម ស្មីត៖**

លោកស្រីចៅក្រម លោកស្រីស្តាប់ខ្ញុំឮទេ?

**ប្រធានអង្គជំនុំ៖**

បាទ ដូចមានបញ្ហាខាងប្រព័ន្ធសំឡេងៗភាសាអង់គ្លេស។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអ្នកបច្ចេកទេសពិនិត្យបញ្ហានេះឡើងវិញ។

*(មានបញ្ហាបច្ចេកទេស)*

[១០:៣៤:៥២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថាប្រហែលជាមានបញ្ហាកាសរបស់ខ្ញុំ ដូច្នេះសូមលោកចាប់ផ្តើម។

**លោក វីល្លៀម ស្មីត៖**

ឥឡូវលោកស្រីចៅក្រមស្ដាប់ឮទេ?

សូមជម្រាបសួរម្ដងទៀត ការធ្វើបទបង្ហាញរបស់ខ្ញុំ គឺផ្ដោតទៅលើព្រលានយន្តហោះកំពង់ឆ្នាំង ហើយព្រះរាជអាជ្ញានឹងលើកយកនូវឯកសារមួយចំនួន ដែលមិនមែនជាសក្ខីកម្មក្នុងសវនាការនោះឡើយ ហើយយើងធ្វើឡើងដើម្បីគាំទ្រ និងបង្ហាញ ព្រមទាំងបង្ហាញភស្តុតាងទៅលើធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានកើតឡើងនៅព្រលានយន្តហោះ ដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឧក្រិដ្ឋកម្មដែលយើងនឹងលើកឡើងនៅក្នុងឯកសារទាំងអស់នោះ គឺនឹងបង្ហាញអំពីការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ ការដាក់ឲ្យទៅជាទាសករ ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ អំពើមនុស្សឃាតនិងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ហើយក្រៅពីនេះ គឺថាវាបង្ហាញផងដែរទៅលើបទចោទមួយចំនួន ហើយនិងបង្ហាញអំពីឯកសារដែលពាក់ព័ន្ធនានា។

[១០:៣៦:០៧]

លោក លោកស្រីចៅក្រម ខ្ញុំសូមធ្វើការបង្ហាញឯកសារចំនួន៣៩ -- ២៩ ហើយយើងនឹងលើកយកនូវឯកសារថ្មីៗពីឆ្នាំ៧៥ដល់៧៩។ ប៉ុន្តែនៅក្នុងពេលវេលាដែលយើងបានបញ្ជាក់នោះ គឺនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សី ដែលបានប្រមូលផ្ដុំដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនិងសក្ខីកម្មមួយចំនួនដែលលោក លោកស្រីចៅក្រមបានស្ដាប់ឮ។

ឯកសារជាដំបូង គឺឯកសារ E3/182 ចុះថ្ងៃទី០៩ តុលា ឆ្នាំ៧៥ គឺជារបាយការណ៍កិច្ចប្រជុំបក្សកុម្មុយនីស្ដកម្ពុជា អង់គ្លេសមានលេខ 00183407, ខ្មែរមានលេខ 00019126 និងបារាំងមានលេខ 00292886។ ហើយនៅត្រង់កិច្ចប្រជុំនេះ គឺគេបានធ្វើការកត់ត្រានូវការជជែកគ្នាដូចតទៅ៖ “ឯព្រលានយន្តហោះ ខាងយោធាយើងមានផែនការធ្វើកន្លែងផ្សេង។ អាចពិនិត្យមើលខាងកំពង់ឆ្នាំង ពង្រឹង និងពង្រីកវា។ បើឆ្ងាយពេកយើងធ្វើតំបន់១៥។ ដូច្នេះទិសយើងដោយឡែក។ នៅចំពោះមុខរួមផ្សំនៅពោធិ៍ចិនតុង។” លោក លោកស្រីចៅក្រម ប្រសិនបើយើងមើលទៅបរិបទនៃឯកសារនេះ គឺគេនិយាយអំពីគោលដៅ។ ហើយភាពពាក់ព័ន្ធនៃឯកសារនេះ គឺថាបានបង្ហាញថា នួន ជា ហើយនិង ខៀវ សំផន បានដឹងអំពីផែនការ ហើយប្រហែលជាកំណត់ត្រាទី១ ក្នុងការបង្ហាញអំពីគោលគំនិតក្នុងការស្នើដែលថា មានព្រលានយន្តហោះនៅកំពង់ឆ្នាំង។

[១០:៣៨:១៤]

ហើយឯកសារបន្ត គឺឯកសារ E3/1139 ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់គឺឯកសារ ចុះថ្ងៃ២២ មករា ឆ្នាំ៧៦។ ឯកសារនេះនឹងជួយក្នុងការបង្ហាញនូវភស្តុតាងអំពីការទទួលខុសត្រូវផ្នែកយោធា នៅកងពល៥០២ ក៏ដូចជាអំពីគោលជំហរនយោបាយ ហើយនិងវណ្ណៈកម្មាភិបាលនៅក្នុងកងពល៥០២។ លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសានេះនៅលើអេក្រង់ ដើម្បីឲ្យសាធារណជនអាចពិនិត្យមើលជាឯកសារភាសាខ្មែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ហើយបុគ្គលិកផ្នែកសោតទស្សន៍ និងរូបភាពបង្ហាញឯកសារលើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វីណ្ដៀម ស្មីត៖**

ឥឡូវនេះ យើងឃើញហើយ លោក លោកស្រីចៅក្រម ឯកសារនេះបង្ហាញអំពីចំនួនកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅក្នុងកងពល៥០២ ហើយតារាងនេះបង្ហាញពីភេទ ក៏ដូចជាជំហរ គឺជំហររបស់បក្សកុម្មុយនីស្ត ថាតើជាជំហរល្អ មធ្យម ឬក៏ខ្សោយ និងចុងក្រោយ គឺវណ្ណភាព។ ហើយគោលដៅនៃឯកសារនេះ គឺដើម្បីបង្ហាញអំពីបញ្ហានៃវណ្ណភាព ក៏ដូចជាខ្នាំងវណ្ណៈ ដែលទាំងអស់នេះគឺជាអ្វីដែលកងពល៥០២ បានគិតពិចារណានៅក្នុងដំណាក់កាលដំបូង គឺក្នុងខែមករា ឆ្នាំ៧៦។

[១០:៤០:០៩]

ឥឡូវនេះ ខ្ញុំសូមបន្តទៅឯកសារបន្ទាប់។ ឯកសារបន្ទាប់គឺ E3/229 ហើយឯកសារនេះចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ៧៦ ហើយឯកសារនេះគឺជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃនោះ។ ហើយឯកសារនេះក៏បានបង្ហាញផងដែរថា នួន ជា និង ខៀវ សំផន គឺមានវត្តមាន។ គឺអង់គ្លេសមានលេខ 00182627, ខ្មែរមានលេខ 00000716 និងបារាំងមានលេខ 00334960។ ហើយយើងបានឃើញថាគេលើកឡើងអំពីព្រលានយន្តហោះ ដែលថាបានស្នើឲ្យពិនិត្យទៅលើការដ្ឋានថ្មី ជ្រៅបន្តិចដូចជាម៉ុត្លាតពង ឬកំពង់ឆ្នាំង។ ហើយភាពពាក់ព័ន្ធគឺថា ដំណើរការនៃការគិតរបស់គណៈអចិន្ត្រៃយ៍ គឺគិតអំពីទីតាំងដែលគេគ្រោងនឹងសាងសង់ព្រលានយន្តហោះ គឺនៅក្នុងថ្ងៃ២២ កុម្ភៈ ឆ្នាំ៧៦។

ឯកសារបន្ទាប់គឺ E3/236 គឺចុះថ្ងៃ១៩ ដល់ ២១ មេសា ឆ្នាំ៧៦ ហើយឯកសារនេះគឺជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលកត់ត្រាពីសេចក្ដីសម្រេច មិនមែនត្រឹមតែការពិភាក្សាប៉ុណ្ណោះទេ

ប៉ុន្តែជាការកំណត់សម្រេចបង្កើតព្រលានយន្តហោះនៅកំពង់ឆ្នាំង។ ហើយខ្ញុំនិយាយយោងទៅលើឯកសារលេខ ភាសាអង់គ្លេស 00183419, ខ្មែរមានលេខ 00019145 និងបារាំងមានលេខ 00322870។ គឺបានបញ្ជាក់ដូចតទៅនេះ៖ “ព្រលានយន្តហោះយោធា យើងរៀបចំដំណើរការនៅកំពង់ឆ្នាំងចុះ។ យើងត្រូវការពារប្រទេសឲ្យមានប្រសិទ្ធភាព។ គេឲ្យអ្វី យើងធ្វើនុំង បើខ្វះយើងទិញថែមមួយចំនួន។” គឺសេចក្តីសម្រេចនេះគឺនៅក្នុងខែមេសា ឆ្នាំ៧៦។

[១០:៤២:៤០]

ឯកសារបន្តទៀតគឺឯកសារ E3/222 ចុះថ្ងៃទី១៥ ឧសភា ឆ្នាំ៧៦ ហើយឯកសារនេះ គឺជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ហើយបានបង្ហាញថា នួន ជា ហើយនិង ខៀវ សំផន មានវត្តមានចូលរួមផងដែរ។ ហើយកំណត់ហេតុនេះបានកត់ត្រាអំពីការកសាងព្រលានយន្តហោះ គឺការចាប់ផ្តើមកសាងព្រលានយន្តហោះ។ ខ្ញុំចង់និយាយយោងទៅលើឯកសារអង់គ្លេស 00182666, ខ្មែរមានលេខ 00000771 និងបារាំងមានលេខ 00323892។ គឺបានបញ្ជាក់ដូចតទៅនេះ៖ “ព្រលានយន្តហោះសមមិត្តខៀវ រាយការណ៍ (គឺគេនិយាយសំដៅទៅលើ សុន សេន)។ នៅពង្រត្រូវចាក់គ្រួសច្រើន។ គាត់សួរយើងថា ផ្ទះប្រក់អី ធ្វើម៉េចកុំឲ្យក្តៅ? ពួកខែដី ក៏មកដល់ហើយដែល។” គឺធ្វើឡើងនៅក្នុងខែឧសភា ឆ្នាំ៧៦ របាយការណ៍នេះ។

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំសូមយោងទៅលើឯកសារ E3/3 ហើយខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះ នៅលើអេក្រង់ គឺឯកសារនេះ ចុះថ្ងៃទី០៩ តុលា ៧៦។ ហើយឯកសារនេះមានភាពពាក់ព័ន្ធដោយសារជួយក្នុងបង្ហាញថា បញ្ជាការកងពល៥០២គឺ ស៊ូ ម៉េត បានទទួលខុសត្រូវលើការកសាងព្រលានយន្តហោះ ហើយគាត់មានចេតនាបោសសម្អាតទាហាននៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា។ ហើយឯកសារនេះមានចំណងជើងថា “របាយការណ៍កិច្ចប្រជុំលេខាកងពល និងកងកងវរសេនាធំឯករាជ្យ” ហើយដឹកនាំដោយ សុន សេន ហើយរបាយការណ៍នេះបានកត់ត្រានូវការជជែកគ្នារវាងសេនាធិការ និងកងពលមជ្ឈិម អំពីតួនាទីរបស់គេក្នុងការបោសសម្អាតផ្ទៃក្នុង ការអប់រំរៀនសូត្រខ្លាំង ក្នុងចំណោមបញ្ហានានាដែលគេលើកយកមកពិភាក្សា។ នៅក្នុងកិច្ចប្រជុំនេះ ស៊ូ ម៉េត មានវត្តមាន គឺគាត់ជាមេបញ្ជាការកងពល៥០២។ ឯកសារត្រង់លេខ អង់គ្លេស 00940350, ខ្មែរមានលេខ 00052411 និងបារាំងមានលេខ 00334980។ ហើយគាត់បានកត់ត្រានូវការជជែកគ្នាដូចតទៅ៖ “ក្រោយបក្សបានបង្ហាញខ្សែក្បត់ខ្ពស់ជារបស់ចក្រពត្តិអាមេរិក និងពួកសេរីនិយម មានសេចក្តីរីករាយ និងកាន់តែជឿ

លើបក្ស។ ពិសោធនេះបញ្ជាក់ថា បក្សយើងក្តាប់បានមានជំហរប្រុងប្រយ័ត្នជាប់។ បើទំនាស់ ក្តាប់ទំនាស់បានច្បាស់ ជាជ័យជម្នះរបស់បក្សយើង។ បញ្ហានេះកំណត់ថា យើងកម្ចាត់ខ្មាំងបានជាមូលដ្ឋានហើយ ត្រូវតែមានវិធានការបន្តទៀត កុំឱ្យមានទី២, ទី៣, ទី៤អ្វីបន្តទៀត។ ខ្មាំងធ្វើអ្វីយើងទៀតមិនបានទេ ឱ្យតែយោធាយើងរឹង ស្អាតខាងនយោបាយ។ ត្រូវពង្រឹងបក្សខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង។ ត្រូវប៉ិនសម្រិតសម្រាំងដាច់ខាត។” លោក លោកស្រីចៅក្រម ឯកសារនេះគឺនៅថ្ងៃ០៩ តុលា ឆ្នាំ៧៦ ហើយហេតុផលដែលថា ឯកសារនេះនិយាយពី ស៊ូ ម៉េត ហើយលើកយកមកបង្ហាញជូនអង្គជំនុំជម្រះ គឺថាឯកសារនេះបានបង្ហាញថាអ្នកដែលទទួលខុសត្រូវក្នុងការកសាងព្រលានយន្តហោះក្នុងពេលជាមួយគ្នានោះ ក៏បានចូលរួមពាក់ព័ន្ធយ៉ាងសំខាន់ក្នុងការបោសសម្អាតទៅលើកងទ័ពបដិវត្តន៍កម្ពុជា។ ហេតុដូច្នេះហើយទើបខ្ញុំបង្ហាញឯកសារនេះ ដែលវាមានភាពពាក់ព័ន្ធ គឺបង្ហាញអំពីការបោសសម្អាតដែលកើតឡើងនៅព្រលានយន្តហោះ។

[១០:៤៧:៤៣]

ផ្នែកបន្ទាប់នៃឯកសារនេះ គឺឯកសារ E3/13 ហើយឯកសារនេះក៏ពាក់ព័ន្ធផងដែរ ដោយសារតែមេផ្ទាល់របស់ ស៊ូ ម៉េត គឺ សុន សេន គាត់បានដឹកនាំកិច្ចប្រជុំនេះ។ ហើយនៅត្រង់ភាសាអង់គ្លេសមានលេខ 00940354 ដល់ 55, ខ្មែរមានលេខ 00052414 និងបារាំងមានលេខ 00334982 ដល់ 83។ ប្រធានកិច្ចប្រជុំគឺ សុន សេន បានសន្និដ្ឋាន បានបញ្ចប់កិច្ចប្រជុំដោយលើកយកនូវវិធានការមួយចំនួននៅទំព័រចុងក្រោយ ដែលគាត់និយាយអំពីវិធីដំណើរការ គឺក្រោយពេលដែលគាត់ស្តាប់មេបញ្ជាការបាននិយាយអំពីការបោសសម្អាត ក៏ដូចជាបញ្ហាយោធាមួយចំនួន។ គាត់បន្តថា៖ “ទី១ ត្រូវអប់រំជាបន្តបន្ទាប់។ ទី២ ត្រូវសម្រិតសម្រាំងឱ្យបានល្អដាច់ខាតក្នុងន័យតស៊ូវណ្ណៈជាដាច់ខាត។ សម្រិតសម្រាំងត្រូវឈរលើគោលការណ៍បីយ៉ាង។ ប្រភេទទី១ ប្រភេទអន្តរាយ ត្រូវសម្រិតសម្រាំងដាច់ខាត។ ប្រភេទទី២ ប្រភេទសេរីធម្មតា ត្រូវអប់រំជាបន្តបន្ទាប់ក្នុងសាលាអប់រំរបស់យើង។ ប្រភេទទី៣ ប្រភេទពួកទើបតែខ្មាំងញុះញង់ ទើបតែគេញុះញង់ជាជំហានដំបូង ត្រូវអប់រំកសាងគេកុំឱ្យជឿខ្មាំងទៀត។” គោលដៅនៃឯកសារនេះ គឺចង់បង្ហាញអំពីកងទ័ពបដិវត្តន៍កម្ពុជាក្នុងការបោសសម្អាតទៅលើប្រភេទទាំងបីនៅពេលដែលគេរកឃើញខ្មាំង។

[១០:៥០:០០]

លោក លោកស្រីចៅក្រម ឯកសារបន្តដែលខ្ញុំចង់និយាយយោង គឺកំណត់ហេតុស្តាប់ចម្លើយ

សាក្សី គឺឯកសារ E3/5279 ហើយឯកសារនេះ គឺពាក់ព័ន្ធទៅនឹងការបង្ហាញអំពីឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅព្រលានយន្តហោះកំពង់ឆ្នាំង។ សាក្សីរូបនេះ គឺជាយុវជនអាយុ២០ឆ្នាំ នៅក្នុងឆ្នាំ៧៥ ហើយគាត់ស្ថិតនៅក្នុងកងពល៥០២។ គាត់ត្រូវបានគេបញ្ជូនទៅព្រលានយន្តហោះនៅចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧ រហូតដល់ឆ្នាំ៧៨។ នេះគឺជាអ្វីដែលគាត់បានប្រាប់អ្នកស៊ើបអង្កេត ក្នុងនាមជាយោធានៅក្នុងកងពល គឺនៅត្រង់ភាសាអង់គ្លេស 00293008 ដល់ 09, ខ្មែរមានលេខ 00287548 ដល់ 51, បារាំងមានលេខ 00342677 ដល់ 79។ គេសួរគាត់ដូចតទៅនេះ៖ "នៅពេលដែលគេបញ្ជូនលោកទៅព្រលានយន្តហោះកំពង់ឆ្នាំង តើគេបញ្ជូននៅពេលណា? ពួកគេបញ្ជូនខ្ញុំទៅព្រលានយន្តហោះកំពង់ឆ្នាំង នៅចន្លោះឆ្នាំ៧៦ និងដើមឆ្នាំ៧៧ ប៉ុន្តែខ្ញុំមិនចាំនោះទេ។ គេបញ្ជូនខ្ញុំទៅទីនោះ ដោយសារខ្ញុំស្ថិតនៅក្នុងកងពលទ័ពស្រុក២០ កាលពីឆ្នាំ៧២។ នៅពេលដែលគេបញ្ជូនលោកពីកងពល៧១ ពិសេស? ឆ្លើយ៖ ក្រោយពេលភ្នំពេញដួលរលំនៅថ្ងៃទី១៧ មេសា ៧៥ ក្រុមរបស់ខ្ញុំរួមបញ្ចូលនៅក្នុងកងពល៥០២ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ម៉េត។ ម៉េត ជាមេបញ្ជាការ ហើយនិង ល្វៃ គឺជាមេបញ្ជាការរង។ ខ្ញុំមិនដឹងថាតើមនុស្សទាំងអស់នេះនៅទីណាទេឥឡូវនេះ។ កងពល៥០២ធំណាស់ គឺគេគ្រប់គ្រងទៅលើទាហានទ័ពអាកាសនៅពោធិ៍ចិនតុង និងទាហានការពារអាកាស។ តើលោកឃើញអ្វីនៅពេលដែលលោកមកដល់ព្រលានយន្តហោះកំពង់ឆ្នាំងដំបូង? នៅពេលនោះ កន្លែងនោះគឺជាវាលស្រែ ដែលមានតែដើមត្នោត និងដើមឈើផ្សេងៗនៅឡើយទេ។ សកម្មភាពដែលខ្ញុំឃើញជាលើកដំបូង គឺឃើញគេគាស់គល់ត្នោត គល់ឈើ សម្អាតដី ដែលមានអង្គភាពនីមួយៗធ្វើតាមផែនការ និងប្លង់របស់គេដែលមានអ្នកជំនាញការចិនរាប់រយនាក់ជាអ្នកណែនាំ។ ពេលខ្ញុំទៅដល់ដំបូង ខ្ញុំឃើញមានមនុស្សជាច្រើនមកពីខាងព្រៃវែង និងស្វាយរៀង ដែលក្នុងនោះមួយថ្ងៃៗមានឡានដឹកមនុស្សចូលទីនោះរាប់រយឡាន។ នៅចន្លោះឆ្នាំ៧៨ មនុស្សត្រូវគេបញ្ជូនមកកាន់តែច្រើន ហើយការសម្លាប់ក៏កាន់តែមានច្រើន។ មនុស្សដែលមកពីព្រៃវែង និងស្វាយរៀង គឺជាអ្នកនៅក្នុងភូមិភាគបូព៌ា។ ហេតុអ្វីលោកដឹងថាអ្នកទាំងនោះមកពីទីនេះ? គឺគេសួរបែបនេះ ហើយគាត់ឆ្លើយថា៖ មនុស្សដែលមកពីខេត្តព្រៃវែង និងស្វាយរៀងទាំងនោះត្រូវបានគេបំបែកឲ្យទៅនៅជាមួយខ្ញុំដែរ ហើយពួកគាត់បានប្រាប់ខ្ញុំផ្ទាល់ថា មកពីភូមិភាគបូព៌ា។ ពួកគាត់សុទ្ធតែជាយោធា ដែលមិនដឹងខ្លួនថាមូលហេតុអ្វីដែល គេបញ្ជូនមកកំពង់ឆ្នាំងនេះ។ ក្រៅតែពីដឹងថាមេៗរបស់ខ្លួនត្រូវគេចោទថាក្បត់។ ពួកនោះធ្វើការនិងដេកនៅជាមួយខ្ញុំផ្ទាល់ ហើយនិយាយប្រាប់ខ្ញុំបន្ថែមថា អ្នកដែលមកនេះឋានៈត្រឹមតែយុទ្ធជនទេ។ ចំណែកមេៗដែលមានឋានៈ

ពីអនុសេនាតូចឡើងទៅ មិនដឹងគេបញ្ជូនទៅណាទេ។ សំណួរ៖ តើអ្នកទាំងនោះបាននិយាយប្រាប់លោកថាម៉េចខ្លះទៀត ទាក់ទងនឹងការបញ្ជូនមកការដ្ឋានព្រលានយន្តហោះនេះ? គាត់ថា គេបានកោះហៅប្រជុំ ហើយឲ្យដកអាវុធ។ បន្ទាប់មកគេឲ្យរៀបចំខ្លួនដើម្បីឲ្យមកធ្វើការ មកធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង។"

[១០:៥៤:១០]

បន្ទាប់មកទៀត អ្នកស៊ើបអង្កេតបានបន្តសួរ ហើយគេនិយាយថា៖ "លោកបានប្រាប់យើងថា នៅចន្លោះឆ្នាំ -- ខ្ញុំចង់ពន្យល់ទៅលើចំណុចពីរ។ ទី១ ពេលខ្ញុំទៅកាប់កូនឈើយកមកធ្វើនៅរោងព្រលានយន្តហោះ ខ្ញុំឃើញរណ្ដៅសាកសពជាច្រើននៅភ្នំពាមលោក គឺមានចម្ងាយប្រហែល៥គីឡូម៉ែត្រពីព្រលានយន្តហោះ ដែលគេសម្លាប់ថ្មីៗ ហើយមានស្នាមផ្អែកាយ និងលុបមិនទាន់ជិត ដែលខ្ញុំសន្និដ្ឋានថា គេប្រាកដជាយកមនុស្សពីការដ្ឋានព្រលានយន្តហោះទៅសម្លាប់នៅទីនោះ ពីព្រោះនៅក្នុងអង្គភាពខ្ញុំមានបាត់ខ្លួនមនុស្សមួយចំនួន។ ចំណុចមួយទៀត ខ្ញុំដឹងថា មានការសម្លាប់ជារៀងរាល់ថ្ងៃដោយការបញ្ឆោតថា យកមនុស្សទាំងនោះទៅជួយច្រូតស្រូវប្រជាជន។ ខ្ញុំដឹងរឿងនេះ ដោយសារកងការពារឡានដឹកមនុស្សយកទៅនោះ បានប្រាប់ខ្ញុំថា គេដឹកមនុស្សទាំងនេះ យកទៅសម្លាប់ចោល។ បើសិនជាអាចគេចខ្លួនបាន គេចទៅ។ ឡានដែលដឹកមនុស្សទាំងនោះ គឺចេញទៅទិសរ៉ារមាស។ សំណួរ៖ សូមលោករៀបរាប់ តើស្ថានភាពការងាររបស់លោកនៅការដ្ឋានព្រលានយន្តហោះយ៉ាងម៉េចដែរ? មនុស្សស្លាប់ជារៀងរាល់ថ្ងៃ ស្លាប់ដោយសារជំងឺ អ្នកខ្លះស្លាប់ដោយសារអត់បាយ បាក់កម្លាំង។ ខ្ញុំឃើញ គេសែងសាកសពយកទៅកប់នៅព្រៃក្បែរៗការដ្ឋានព្រលានយន្តហោះនោះ។ អ្នកជំងឺត្រូវបានគេយកទៅមន្ទីរពេទ្យដែលក្បែរការដ្ឋានព្រលានយន្តហោះនោះដែរ។"

សាក្សីរូបនេះបានផ្ដល់កិច្ចសម្ភាសន៍មួយទៀត ហើយឯកសារគឺ E3/5263 ហើយគាត់បាននិយាយបន្ថែមទៀត អំពីការយកចេញពីព្រលានយន្តហោះ ហើយបញ្ជូនទៅស-២២។ គឺឯកសារអង់គ្លេសមានលេខ 00282224 ដល់ 25, ខ្មែរមានលេខ 00270178 ដល់ 80 ហើយបារាំងមានលេខ 00283349 ដល់51។ បាទ លោកប្រធាន។

[១០:៥៦:៤២]

**ប្រធានអង្គជំនុំ៖**

ដូចមានការភ័ន្តច្រឡំទេ ស-២២ ឬស-២១? អត់ដែលឮសួរ ស-២២ ផង ហើយលោកបង្ហាញ

ម៉េចចេញ ស-២២ ពីណាមក? បញ្ជាក់ចំណុចនេះឡើងវិញ ក្រែងលោមានការភ័ន្តច្រឡំជាភាសាខ្មែរ ព្រោះគាត់ចេញមក ស-២២ មិនដឹងនៅទីណា ព្រោះយើងធ្វើសវនាការមក ដូចមិនទាន់ដែលបានជួប។

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន គឺខ្ញុំនិយាយអំពី ស-២២ ដែលយើងបានពិភាក្សាច្រើនដងហើយ នៅក្នុងការជំនុំជម្រះ គឺជាមន្ទីរសន្តិសុខមួយរបស់កងពល៥០២ ហើយសាក្សីរូបនេះ បានពន្យល់អំពីមន្ទីរ ស-២២ នេះ។ ដូច្នេះខ្ញុំសូមអនុញ្ញាតអាននូវឃ្លានេះ លោកប្រធាន។ "ក្រោយមកទៀត ខ្ញុំត្រូវបានគេសម្រិតសម្រាំងបញ្ជូនទៅ ស-២២ គឺស្ថិតនៅខាងលិចទឹកល្អក់ គឺនៅខាងលិចសាលាទឹកល្អក់។ ខ្ញុំមិនអាចចាំឈ្មោះអ្នកគ្រប់គ្រង ស-២២ ឡើយ។ មនុស្សរាប់រយនាក់ ត្រូវបានឃុំនៅស-២២ ដែលសុទ្ធតែជាកងទ័ពកងពល៥០២ ដែលទើបតែបញ្ចូលមកពីអង្គភាពភូមិភាគពិសេសចាស់។ ខ្ញុំបាននៅ ស-២២ នេះ ចំនួនបីទៅបួនខែ។ បានចេញទៅធ្វើការមួយអាទិត្យតែម្តង ហើយហូបចុកតែដើមចេក ផ្តៃចេក ត្រកួនលាយជាមួយអង្ករមួយគ្រាប់ៗ។ ចំពោះអ្នកយាមនៅ ស-២២ មានរបបបរហូប។ នៅចុងឆ្នាំ៧៧ ទើបខ្ញុំត្រូវបានចម្រាញ់ម្តងទៀត ទៅធ្វើការនៅព្រលានយន្តហោះនៅកំពង់ឆ្នាំង គឺទៅជាលើកទី២។ តែគាត់ទៅធ្វើការនៅព្រលានយន្តហោះ។ គាត់បានបញ្ជាក់ថា ទាហានរាប់ពាន់នាក់ត្រូវបានគេដកអាវុធចេញ ហើយអ្នកទាំងនោះ ត្រូវបានមកទាំងក្រុម។ ខ្ញុំឃើញមនុស្សរាប់រយនាក់ស្លាប់នៅទីនោះ ដោយសារខ្ញុំឃើញរណ្តៅ និងសពមនុស្សមានប្រឡាក់ឈាម នៅពេលដែលខ្ញុំត្រូវបានឲ្យទៅចូលព្រៃអារអុស។ ខ្ញុំដឹងថា អ្នកស្លាប់នោះ គឺជាអ្នកដែលធ្លាក់ខ្លួនឈឺ ដោយធ្វើការស្ទើរតែគ្មានម៉ោងសម្រាក ឬបានលួចចំណីហូប ដែលចំណីនោះ សុទ្ធតែដំណាំដែលខ្លួនឯងផ្ទាល់បានដាំ។"

[១០:៥៩:១៩]

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារបន្ទាប់គឺ E3/804។ ដូច្នេះខ្ញុំសូមអនុញ្ញាតបង្ហាញទៅលើឯកសារ គឺឯកសារចុះថ្ងៃទី១៥ ធ្នូ ៧៦ ហើយឯកសារនេះ គឺជាកំណត់ហេតុកិច្ចប្រជុំកងទ័ពបដិវត្តន៍កម្ពុជា គឺជាការប្រជុំរបស់មេបញ្ជាការកងពល ម៉េត ហើយបានពិភាក្សាអំពីតួនាទីរបស់គេក្នុងការបោសសម្អាតផ្ទៃក្នុង និងការអប់រំរៀនសូត្រខ្លាំង។ ឥឡូវនេះ ខ្ញុំសូមនិយាយយោងទៅលើឃ្លាមួយនៅត្រង់សេនាធិការបានកត់សម្គាល់។ នៅត្រង់ភាសាអង់គ្លេសមានលេខ 00233718, ខ្មែរមានលេខ 00008478 និងបារាំងមានលេខ 00386208។ ហើយគាត់បានបញ្ជាក់ដូចតទៅ៖ "កត់សម្គាល់អំពីខ្មាំង និយាយរួមពុំទាន់មានអីទេ។ ឯខ្មាំងខាងក្នុងក៏ត្រូវរប៉ាត់រប៉ាយជាមូលដ្ឋានដែរ។ តែ

ទន្ទឹមនេះ ក៏នៅមានបាតុភាពខ្លះបញ្ជាក់ថា នៅមានខ្មាំងធ្វើសកម្មភាពស៊ីរូងផ្ទៃក្នុងកងទ័ពយើង។ ហើយគាត់បានបញ្ជាក់បន្តទៀតថា៖ វិធានការរបស់យើង យើងត្រូវតែបោសសម្អាតខ្មាំងឲ្យបានស្អាត។ ដោយយើងត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង ហើយតាមពិតទៅគឺមូលហេតុគឺមានពាក់ព័ន្ធ។ មិនត្រូវគិតថានេះគឺជាបញ្ហាធម្មតានោះទេ។ ការរកខ្មាំងគឺត្រូវគ្រប់គ្រង ហើយនិងធ្វើការពិនិត្យទៅលើហេតុការណ៍នីមួយៗ។ ខ្មាំងខាងក្រៅ គឺមិនមែនជាអ្វីដែលត្រូវព្រួយបារម្ភនោះឡើយ ប៉ុន្តែយើងត្រូវយកចិត្តទុកដាក់ចំពោះខ្មាំងខាងក្នុងដែលនៅសល់។ ប្រសិនបើយើងមិនប្រុងប្រយ័ត្ន ហើយសន្តិភាពនិយម ពួកគេនឹងចាប់យកឱកាស ហើយធ្វើការវាយប្រហារទៅលើបដិវត្តន៍របស់យើង។" ហើយឯកសារនេះគឺមានភាពសំខាន់ដោយសារតែនេះជាគោលនយោបាយរួមពាក់ព័ន្ធទៅនឹងការបោសសម្អាតខ្មាំងដោយពួកខ្មែរក្រហម។ ហើយនេះគឺជាលក្ខណៈមួយនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ហើយវាជាកិច្ចប្រជុំដែលចូលរួមដោយ ស៊ូ ម៉េត។ ហើយខ្ញុំគិតថា ប្រហែលជាមានការបញ្ជាផងដែរពី សុន សេន។

[១១:០២:០៤]

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារE3/362 ហើយឯកសារនេះគឺពាក់ព័ន្ធដោយសារតែវាបានជួយបង្ហាញថា ហេតុអ្វីបានជាទាហានភូមិភាគបូព៌ាត្រូវបានបញ្ជូនទៅព្រលានយន្ត-ហោះ ហើយវាក៏ជួយបង្ហាញផងដែរថា អំពីស្ថានភាពធ្វើទុក្ខបុកម្នេញនៅព្រលានយន្តហោះ។ សាក្សីរូបនេះមានអាយុ២៣ឆ្នាំ គឺជាយុវជន នៅឆ្នាំ៧៥ គាត់ជាមេបញ្ជាការកងអនុសេនា ហើយគាត់មកពីភូមិភាគនិរតី ពីឆ្នាំ៧៥ ដល់៧៧។ ឯកសារនេះ គឺភាសាអង់គ្លេសមានលេខ 00268895, ខ្មែរមានលេខ 00210209 និងបារាំងមានលេខ 00268903។ គាត់បានបញ្ជាក់ថា គឺថាដំបូងគាត់និយាយអំពីការបោសសម្អាតនៅភូមិភាគបូព៌ា។ ហើយគាត់បាននិយាយអំពីថាតើអ្នកបូព៌ាទៅណា។ "មុនពេលធ្វើការបញ្ចូលកងទ័ពរបស់ភូមិភាគនិរតី ដើម្បីវាយប្រឆាំងនឹងកម្មាភិបាលរបស់ភូមិភាគបូព៌ា គឺពិតជាមានគម្រោង និងការរៀបចំសម្រាប់ធ្វើការបោសសម្អាតកម្មាភិបាលផ្ទៃក្នុងទាំងនោះ និងមានការប្រជុំរៀបចំគម្រោងដោយគណៈកម្មការអចិន្ត្រៃយ៍ដែលមាន ប៉ុល ពត, នួន ជា និង អៀង សារី។ រឿងរ៉ាវនេះគឺបណ្តាលមកពីផ្ទៃក្នុងពុំទុកចិត្តគ្នា និងការចោទថាខុសសីលធម៌។ ជាលទ្ធផលខ្លះត្រូវបានចាប់បញ្ជូនទៅកាន់មន្ទីរស-២១ និងខ្លះទៀតត្រូវបញ្ជូនទៅសាងសង់វាលយន្តហោះនៅកំពង់ឆ្នាំង។ គឺមុនការបោសសម្អាតនៅលើភូមិភាគបូព៌ា។ នៅក្នុងឆ្នាំ៧៥, ៧៦ សំ ប៊ិត បានបញ្ជាឲ្យចាប់មនុស្សក្នុងកងទ័ពដែលមានការពាក់ព័ន្ធនឹងវៀតណាម។ នៅក្នុងឆ្នាំ៧៥ មេបញ្ជាការវរសេនាតូច និងវរសេនាធំមួយចំនួនត្រូវ

បានចាប់ខ្លួនដោយចោទថា ជាគិញរបស់វៀតណាម។ ដូច្នេះនៅក្នុងកងទ័ពត្រូវបានចម្រាញ់ចាប់តាំងពីដើមដំបូង។ ហើយអ្នកដែលបានត្រូវចាប់ខ្លួននៅក្នុងកងទ័ព ដោយសារជាប់ពាក់ព័ន្ធការជួយវៀតណាម គឺចាប់ទៅតាមខ្សែក្បត់។ ការចាប់ចងគឺធ្វើទៅតាមបញ្ជារបស់ភូមិភាគ ដែលខ្ញុំគិតថាវាចេញពីថ្នាក់លើ សំ ប៊ិត ទៅទៀត។ ពួកអ្នកដែលត្រូវចាប់ខ្លួនទាំងនោះ ខ្លះត្រូវបញ្ជូនទៅកាន់ភ្នំពេញ និងខ្លះត្រូវបាននាំយកទៅមន្ទីរសន្តិសុខខេត្តកំពត។

[១១:០៥:០២]

ហើយកិច្ចសម្ភាសន៍បានបន្តទៀត ហើយគាត់បាននិយាយអំពីការបោសសម្អាតនៅភូមិភាគបូព៌ា។ គាត់គឺជាសាក្សីនៅក្នុងសំណុំរឿង០០២/០១ អង់គ្លេសមានលេខ 00268896 ដល់ 97 ខ្មែរមានលេខ 00210211 ដល់ 12 និងបារាំងមានលេខ 00268904 ដល់ 05។ ហើយសាក្សីនេះបានបញ្ជាក់ដូចតទៅនេះ៖ "សូមលោកពន្យល់បន្ថែមតាមការដឹងរបស់លោកពាក់ព័ន្ធនឹងរឿងការបោសសម្អាតមនុស្សនៅភូមិភាគបូព៌ា? មុនពេលបេសកកម្មបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ាចាប់ផ្តើម ខ្ញុំនិងមេបញ្ជាការយោធាផងទៃទៀត ត្រូវបានកោះហៅឲ្យទៅចូលរួមប្រជុំនៅផ្ទះ តាម៉ុក នៅខេត្តតាកែវ។ ហើយគេបានប្រាប់ពួកយើង នឹងត្រូវបញ្ជូនទៅបោសសម្អាតពួកអ្នកចូលដៃជាមួយវៀតណាមនៅភូមិភាគបូព៌ា។ គោលបំណងនៃបេសកកម្មនេះមានពីរ គឺវាយពួកវៀតណាមនៅក្នុងប្រទេសកម្ពុជា និងបោសសម្អាតពួកអ្នកចូលដៃជើងជាមួយវៀតណាម។ មេបញ្ជាការដែលចូលរួមការប្រជុំមាន៖ សូយ មេបញ្ជាការភូមិភាគនិរតី, រ៉ែន មេបញ្ជាការកងពល, ធីពូសសេ មេបញ្ជាការកងពលតូច២១០, អៀង ផាន មេបញ្ជាការមកពីតាកែវ និង សុខ ឈាន មេបញ្ជាការមកពីកំពត។ ការប្រជុំនោះគឺបន្ទាន់ ដោយមានរយៈពេលតែមួយថ្ងៃទេ។ មានទ័ព៧០០នាក់មកពីកំពត ១.០០០នាក់មកពីតាកែវ និង៧០០-៨០០នាក់មកពីកណ្តាល។ មួយថ្ងៃបន្ទាប់ពីការប្រជុំ គេបានបញ្ជូនពួកយើងទៅភ្នំពេញ និងស្នាក់នៅមួយយប់នៅបឹងត្របែក ដែលជាទីបញ្ជាការដ្ឋានរបស់កងពល៧០៣។ ថ្ងៃបន្ទាប់មក សុន សេន បានមកប្រជុំប្រាប់អំពីគោលបំណងនៃបេសកកម្មនេះម្តងទៀត និងបានបញ្ជាឲ្យមេបញ្ជាការរៀបចំគម្រោងលម្អិត។ មួយថ្ងៃមកទៀត ពួកយើងបានចេញដំណើរទៅកាន់ខេត្តស្វាយរៀង ដែលបានមកស្នាក់នៅអ្នកលឿងចំនួនពីរទៅបីអាទិត្យ។ មានការប្រជុំជាច្រើនដោយថ្នាក់កងពល ដើម្បីរៀបចំគម្រោងផែនការនេះ។ បន្ទាប់មក រ៉ែន ដែលជាកូនប្រសារ តាម៉ុក បានហៅខ្ញុំតាមទូរស័ព្ទឲ្យទៅភ្នំពេញ ដើម្បីចូលរួមការប្រជុំពិសេស ជាមួយមេដឹកនាំធំៗពាក់ព័ន្ធរឿងគម្រោងធ្វើការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា។ មាន

អ្នកចូលរួមប្រហែល៦០០ទៅ៧០០នាក់ ដែលក្នុងនោះមាន មាស មុត, សុខ ឈាន, អៀង ផាន, ឌី និង ធី ហើយក៏មានវត្តមាន ប៉ុល ពត, តាម៉ុក, នួន ជា និង សុន សេន ផងដែរ។ ពេលនោះ នួន ជា បាននិយាយថា យើងត្រូវតែបោសសម្អាតខ្មាំងផ្ទៃក្នុង និងវាយពួកយួនឈ្លានពាន។ ការបោសសម្អាត បានឡើងដល់កម្រិតខ្ពស់បំផុតក្នុងឆ្នាំ៧៧ ដែលបង្ហាញដូចដែលបានរៀបរាប់ក្នុងទស្សនាវដ្ដីទង់បដិវត្តលេខ៧។ ទស្សនាវដ្ដីនេះក៏បាននិយាយផងដែរ អំពីការកសាងកម្លាំងស្នូលចេញពីពួកកសិករ ម្ចាស់ស្រុក ដែលមិនរាប់បញ្ចូលនូវពួកបញ្ញវន្ត។”

[១១:០៨:២១]

ហើយសាក្សីមួយទៀត ក៏ដូចជាកិច្ចសម្ភាសន៍របស់សាក្សីមួយនេះ គឺបាននិយាយអំពីថាតើកម្មាភិបាលបូព៌ាត្រូវបានបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងដោយរបៀបណា។ ខ្ញុំនិយាយឯកសារ E3/361 អង់គ្លេសមានលេខ 00766453, ខ្មែរមានលេខ 00194467 ដល់ 68 និងបារាំងមានលេខ 00268884 ដល់ 85។ “សំណួរសួរថា៖ តើអ្នកបានធ្វើដូចម្ដេចចំពោះកម្មាភិបាលភូមិភាគបូព៌ា? គឺថាមជ្ឈិមបានផ្ញើខ្ញុំ និងអ្នកដទៃទៀតទៅភូមិភាគបូព៌ា ដើម្បីចាប់កម្មាភិបាលទាំងអស់ នៅក្នុងកងពលតូច និង បញ្ជូនពួកគេមកការដ្ឋានព្រលានយន្តហោះពោធិ៍ចិនតុង។ មេបញ្ជាការត្រូវបានបញ្ជូនមកភ្នំពេញ ហើយទាហានដែលជាកូនចៅនោះ ត្រូវបានបញ្ជូនទៅឲ្យកសាងព្រលានយន្តហោះនៅក្នុងខេត្តកំពង់ឆ្នាំង។ ខ្ញុំមិនដឹងថា មេបញ្ជាការមកពីភូមិភាគបូព៌ាប៉ុន្មាននាក់បានបញ្ជូនមកភ្នំពេញ ឬទៅស-២១ នោះទេ។ ទាហានទាំងអស់ គឺត្រូវដឹកជញ្ជូនតាមឡានទាហាន ហើយត្រូវបានគេយកមកការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ កងពលត្រូវបានបញ្ជូនទៅភូមិភាគបូព៌ា ដើម្បីបោសសម្អាតកម្មាភិបាលដែលមានឈ្មោះនៅក្នុងកងពល ហើយក្នុងនោះមានកងពល៧០៣ ឈ្មោះ ធី ហើយកងពល៤៦០ នោះគឺជាមកពីខាងកំពង់សោម។ ខ្ញុំមិនចាំកងបញ្ជាការកងពលនេះទេ ប្រហែលជាឈ្មោះ សោម សារី។ ទាហានជាង ១០.០០០នាក់ត្រូវបានចាប់ខ្លួន បញ្ជូនទៅធ្វើការចាប់ខ្លួន។”

អង់គ្លេសគឺ 00766457, ខ្មែរ 00194471 ដល់ 72 និងបារាំង 00268889 ដល់ 90។ គាត់ត្រូវបានសំណួរដូចខាងក្រោម៖ “អ្នកណាជាអ្នកធ្វើសេចក្ដីសម្រេចបញ្ជូនកម្មាភិបាលបូព៌ាទៅធ្វើព្រលានយន្តហោះកំពង់ឆ្នាំង និងទៅភ្នំពេញ? បទបញ្ជាគឺចេញពី សុន សេន ដែល សុន សេន ទទួលបញ្ជាពីមជ្ឈិម។ ការបញ្ជូនគឺដកយកមកកន្លែងកងពលរបស់ឈ្មោះ វ៉ែន នៅព្រលានយន្តហោះខាងលិចស្វាយរៀង ហើយដឹកនាំមកភ្នំពេញតាមឡាន ហ្សេ.អឹម.សេ និងឡានអាហ្វ៊ីនចិន។ មនុស្សដែលត្រូវ

យកមកមានប្រហែល៥.០០០នាក់។ សំណួរក៏សួរទៀតថា៖ តើ នួន ជា បាននិយាយលម្អិតអ្វីខ្លះទាក់ទងនឹងការបោសសម្អាតជួរក្នុង? នួន ជា បាននិយាយអំពីការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ខ្មាំងដែលជាដៃជើងយួន។ នួន ជា បានបញ្ជាឲ្យចាប់គឺបោសសម្អាត។ ជំនាន់នោះពាក្យ បោសសម្អាត មានន័យថាចាប់ និងសម្លាប់។ ខ្ញុំសោកស្ដាយណាស់ គេចោទថាមេក្បត់ កូនទាហានក៏ត្រូវតែចាប់ដែរ។ នេះជារឿងពិត។" កិច្ចសម្ភាសន៍ទាំងពីរនេះ គឺបានមកពីសាក្សីម្នាក់ដែលបានចូលរួមពាក់ព័ន្ធយ៉ាងខ្លាំងនៅក្នុងការបោសសម្អាតភូមិភាគបូព៌ា។ ហើយហេតុដូច្នេះឯង ឯកសារនេះគឺថាមានភវនីយហេតុដែលគួរឲ្យជឿជាក់បានយ៉ាងខ្លាំង។

[១១:១២:១៩]

ខ្ញុំសូមចូលទៅឯកសារមួយទៀតគឺ E5 -- បាទ គឺសុំបង្ហាញឯកសារនេះនៅលើអេក្រង់ គឺឯកសារ E3/807 ចុះថ្ងៃទី០១ មីនា ៧៧ ដែលពាក់ព័ន្ធទៅនឹងកងទ័ពបដិវត្តន៍កម្ពុជាដែលមានការប្រជុំនៅក្រោម ស៊ូ ម៉េត និង សុន សេន ហើយនិងកងពលដទៃទៀត។ នៅក្នុងកិច្ចប្រជុំនោះ ពួកគេនិយាយគ្នាអំពីតួនាទីក្នុងការបោសសម្អាត ហើយនិងអប់រំកែប្រែ។ នៅក្នុងកិច្ចប្រជុំនេះ ត្រង់*អ៊ីអ៊ែរអិន*គឺ ERN 00933834, ខ្មែរ 00052304 ដល់ 05 និងបារាំង 00323922។ "ស៊ូ ម៉េត មេបញ្ជាការកងពល៥០២ ទទួលខុសត្រូវនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ផ្ទៃក្នុងមានបញ្ហាចងគ្រាប់បែកសម្លាប់មិត្តយើង ថាទំនាស់ពីប្រធានអនុសេនាតូចទិតៀនខ្លាំង។ សមាសភាពមួយចំនួនដែលយើងចាប់កន្លងមក ច្បាស់ជាសមាសភាពខ្មាំងមែន។ ពួកមិនល្អបានបញ្ជូនទៅ ស-២១ ជាង៥០នាក់ ហើយយើងក៏មានលេខាកងពលមួយចំនួនទៀតដែលត្រូវបានដកហូតនោះផងដែរ។" ការពាក់ព័ន្ធទៅនឹងឯកសារនេះ យើងនិយាយអំពីឥរិយាបថដែលទទួលខុសត្រូវគ្រប់យ៉ាងក្នុងការចាត់ចែង គ្រប់គ្រងការកសាងព្រលានយន្តហោះកំពង់-ឆ្នាំង។ យើងមិនដឹកថាសមាសភាពមិនល្អទាំង៥០នាក់នេះ ត្រូវបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងឬទៅកន្លែងណាផ្សេងទេ។ នេះគឺជាឥរិយាបថរបស់គាត់ពាក់ព័ន្ធទៅនឹងការបោសសម្អាតជាទូទៅ។

[១១:១៤:៣២]

ហើយយើងខ្ញុំក៏សូមយោងឯកសារ E3/1140 ចុះថ្ងៃទី០១ មករា ៧៧ ហើយនេះគឺជារបាយ-ការណ៍មកពី ស៊ូ ម៉េត មេបញ្ជាការកងពល៥០២ បញ្ជូនទៅ ឌុច នៅខែមេសា ១៩៧៧។ ហើយយើងខ្ញុំយល់ឃើញថា មិនត្រូវការបង្ហាញERN ទេ ដោយសារឯកសារច្រើនដែលនិយាយថា៖ "សមមិត្ត ឌុច ក្រោយពីទទួលបានចម្លើយ យើងបានបញ្ជូនមនុស្សទៅស-២១ ដូចតទៅឈ្មោះ ផន ប្រពន្ធឈ្មោះ ផល

ហើយមួយទៀតឈ្មោះ សោម ក៏ត្រូវបានបញ្ជូនទៅថ្ងៃ៣០ មីនា ៧៧។ សៀ ដែលប្រពន្ធគាត់ឈ្មោះ ហឿង ជាខ្មែរក្បត់ ក៏ត្រូវបានចាប់ខ្លួន ហើយក៏ជាខ្មែរយៈរបស់ សោម។ ៣) មុត គឺមេបញ្ជាការវរសេនាតូច៥១១។ ចម្លើយរបស់ឈ្មោះ សារុំ បញ្ជូនទៅនៅថ្ងៃទី៣១ ខែមីនា ៧៧។ លេខរៀងទី៤ ឈ្មោះ ផល ដែលជាសមាជិករបស់កងវរសេនាតូចលេខ៥១៤ តាមចម្លើយឈ្មោះ សារុំ, ឈ្មោះ សោម ត្រូវបញ្ជូនទៅនៅថ្ងៃទី០១ មេសា ៧៧។ ៥) គឺអ្នកដែលនៅសល់ ឈ្មោះដែលនៅសល់ សូមរាយការណ៍។" នេះគឺជាហត្ថលេខារបស់មេបញ្ជាកងពល៥០២ ឈ្មោះ ម៉េត។

ហើយនៅថ្ងៃទី០៧ មេសា ១៩៧៧ គឺឯកសារ E3/894 ចុះថ្ងៃទី០៧ មេសា ៧៧។ យើងខ្ញុំសូមប្រកាសអនុញ្ញាតពីអង្គជំនុំជម្រះ បង្ហាញនៅលើអេក្រង់កុំព្យូទ័រ។ នេះគឺជារបាយការណ៍របស់កងទ័ពបដិវត្តន៍កម្ពុជា ដែលរៀបនូវបញ្ជីជាចំនួនឈ្មោះនូវបុគ្គលិកនៅកងពល៥០២ នៃកងទ័ពបដិវត្តន៍កម្ពុជា។ ចំនួនសរុបទាំងអស់នោះ គឺថាពិបាកនឹងឃើញណាស់ ឲ្យឃើញសរុបទាំងអស់ ប៉ុន្តែគ្រាន់ថាចំនួនសរុបតួលេខតែម្តងគឺ ៦១.១៨៩នាក់។ ហើយកងពល៣១០ និងកងពល៤៥០ គឺហាក់បីដូចជាត្រូវបានបញ្ជូនទៅកំពង់ឆ្នាំង ដែលមានចំនួន១.៥២២។ ហើយកងពល៥៥០ មានចំនួនដល់១.៥២២នាក់។ យើងឃើញថា មនុស្សជាង២០.០០០នាក់ត្រូវបានបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង គឺមិនរាប់បញ្ចូលនូវចំនួនដែលមាននៅព្រលានយន្តហោះពីមុននោះទេ។ ឯកសារបង្ហាញថា អ្នកទាំងអស់នោះមានវត្តមានរួចហើយនៅទីនោះ។ ហើយសមាជិកនៃកងពលដទៃទៀត ក៏បានបញ្ជូនមកព្រលានយន្តហោះកំពង់ឆ្នាំងដែរ។ ដូច្នេះនៅពេលដែលយើងខ្ញុំត្រូវការបង្ហាញអំពីចំនួនគឺថា វាជាតួលេខមួយក្នុង ដែលមានក្នុងកម្រិតអប្បបរមាទេ គឺថានៅតិចជាងចំនួនសរុបនៅក្នុងឯកសារនេះឆ្ងាយណាស់។

[១១:១៨:២២]

ឥឡូវនេះ ខ្ញុំសូមចូលទៅលើឯកសារ E3/970 ចុះថ្ងៃទី៣០ ឧសភា ៧៧ ហើយនេះគឺជារបាយការណ៍មកពី ស្វ៊ មេ៉ត មេបញ្ជាការកងពល៥០២ ផ្ញើទៅ ឌុច នៅឯ ស-២១។ ខ្ញុំសូមអានរបាយការណ៍នេះដោយសង្ខេប៖ "ជូនសមមិត្តឌុច ជាទីគោរពស្រឡាញ់។ នៅថ្ងៃទី២៤ ខែឧសភា ៧៧ ខ្ញុំបានបញ្ជូនពួកក្បត់ចំនួន២៧នាក់ ដែលជាខ្មែរក្បត់ជាមួយនឹងកងពល៣១០ និងកងពល៤៥០។ ប៉ុន្តែលេខរៀងទី២៥ គឺជាខ្មែររបស់ សោម ហើយនិង ម៉ៅ។ នៅល្ងាចមិញនេះ គឺយើងបានបញ្ជូន២៥នាក់។ ហើយយើងខ្ញុំបញ្ជូនពីរទៀតនៅល្ងាចនេះ។ នៅម៉ោងប្រាំពីរ ឬប្រាំបីយប់នេះ ខ្ញុំនឹងបញ្ជូនថែមទៀតនូវខ្មែរក្បត់គឺលេខរៀងទី២៥ ហៀន ដែលត្រូវបានបញ្ជូនទៅនៅថ្ងៃទៅ២៥ មីនា ៧៧។ ហើយនៅម៉ោង

ដប់ ឬដប់មួយយប់នេះ ខ្ញុំនឹងបញ្ជូនទៅបន្ថែមប្រាំពីរនាក់ទៀត។ កាលពីប៉ុន្មានថ្ងៃមុននេះ លោកនិយាយថា លោកនឹងផ្តល់ចម្លើយមកឲ្យខ្ញុំ។ ប្រសិនណាជាអង្គការមិនជំទាស់ទេ យើងខ្ញុំស្នើសុំថាឲ្យបន្តការស្រាវជ្រាវរែកមុខរកខ្មាំងបន្តទៅទៀត។" ចំណុចមួយដែលបាននិយាយក្នុងរបាយការណ៍នេះ គឺថា ស៊ូ ម៉េត ដែលជាមេបញ្ជាការកងពល៥០២ ទទួលខុសត្រូវនៅព្រលានយន្តហោះកំពង់ឆ្នាំងនោះ គឺថា ទទួលខុសត្រូវចំពោះសមាជិកកងទ័ពបដិវត្តន៍កម្ពុជាដ៏ច្រើនលើសលប់ ដែលពាក់ព័ន្ធនៅក្នុងការបោសសម្អាតកងទ័ព សមាជិកកងទ័ពបដិវត្តន៍កម្ពុជា។ ឯកសារពាក់ព័ន្ធទៅនឹងពួកក្បត់ចំនួន២៧នាក់ ដែលបញ្ជូនទៅ ស-២១។

ឥឡូវនេះខ្ញុំសូមចូលទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីពីរ ដែលនៅក្នុងកងពល៣១០ ពីសាក្សីក្នុងកងពល៣១០ ដែលបង្ខំឲ្យធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ។ វាមិនច្បាស់នោះទេ ថាមិនដឹងថាតើសមាជិកកងពល៣១០ និង ៤៥០ ដែលត្រូវបញ្ជូនទៅហ្នឹង មិនដឹងបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង ឬក៏ ស-២១ ទេ។ ក៏ប៉ុន្តែជាការគួរឲ្យចាប់អារម្មណ៍ គឺថាត្រូវពិនិត្យមើលទៅលើចម្លើយរបស់សាក្សីមកពីកងពល៣១០ និង ៤៥០ ពាក់ព័ន្ធទៅនឹងការបោសសម្អាតទូទៅនេះ។

[១១:២១:១៣]

ឯកសារបន្ទាប់មកទៀតគឺ E3/7877 ជាកំណត់ហេតុស្តាប់ចម្លើយរបស់យុវជន អាយុ២០ឆ្នាំ នៅក្នុងឆ្នាំ១៩៧៥ គាត់នៅកងពល៣១០ ជាកងទ័ពកងពល៣១០ បញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង ERN អង់គ្លេស 00346979, ខ្មែរ 00342437, បារាំង 00411785 ដល់ 86។ គាត់បានឆ្លើយដូចតទៅ៖ "ពួកគេ ឈ្មោះ ទុយ មកថាខ្ញុំត្រូវគេបាន គេត្រូវបញ្ជូនខ្ញុំទៅឲ្យលត់ដំនៅកំពង់ឆ្នាំង។ តើប្រជាជនប៉ុន្មាននាក់? នៅកំពង់ឆ្នាំង គេឲ្យលោកធ្វើអ្វី? គេបញ្ជូនខ្ញុំមកកំពង់ឆ្នាំង គឺខ្ញុំមកតែម្នាក់ឯង ប្រហែលជានៅដើមឆ្នាំ៧៨។ គេឲ្យខ្ញុំដាប់ថ្ម ដើម្បីដាក់ឆ្នូនឲ្យផ្ទុះដើម្បីបំបែកថ្ម។ ហើយធ្វើរងដាក់យន្តហោះ។ ហើយថ្មកិនក្រាលធ្វើព្រលានយន្តហោះ។ ក្នុងមួយថ្ងៃមានមនុស្សរបួសពីប្រាំទៅប្រាំមួយនាក់ ដោយសារថ្មផ្ទុះខ្ទាតត្រូវ។ ពេលខ្លះគេឲ្យខ្ញុំទៅជីកដីនៅកន្លែងព្រលានយន្តហោះ។ តើនៅកន្លែងការដ្ឋានព្រលានយន្តហោះមានមនុស្សច្រើនដែរឬទេ? នៅទីនោះមានមនុស្សច្រើនរហូតទៅដល់រាប់ពាន់ ដែលសុទ្ធតែមាននិន្នាការ ដូចជា សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ដែលគេបញ្ជូនខ្លួនមកឲ្យលត់ដំ។"

[១១:២២:៥១]

ឯកសារបន្ទាប់គឺឯកសារ E3/5276 គឺជាចម្លើយរបស់កងទ័ពម្នាក់អាយុ២៥ឆ្នាំ នៅក្នុងឆ្នាំ៧៥

ដែលជាកងទ័ពនៅក្នុងកងពល៣១០ ហើយគេបញ្ជូនគាត់ឲ្យទៅធ្វើការនៅកំពង់ឆ្នាំង នៅដើមឆ្នាំ១៩៧៧ រហូតដល់៧៨។ ERN ជាភាសាអង់គ្លេស 00287356, ខ្មែរ 00282954 ដល់ 55 និងបារាំង 00339922។ គាត់បានឆ្លើយទៅនឹងសំណួរនេះដូចតទៅ៖ “សាក្សីខ្លះបាននិយាយថា គាត់បានឃើញគេដឹកមនុស្សដែលជាប់ចំណងចេញពីការដ្ឋានយកទៅសម្លាប់ចោល។ សូមលោកបញ្ជាក់តាមការដែលលោកដឹង។ ខ្ញុំមិនដែលបានឃើញហេតុការណ៍នេះ ផ្ទាល់ភ្នែកទេ តែពេលប្រជុំខ្ញុំបានឮគេនិយាយថា បើគេរកឃើញអ្នកណាមានកំហុសឆ្គងក្នុងការងារ គេនឹងយកទៅដាក់គុកព្រៃស និងសម្លាប់ចោលហើយ។ ខ្ញុំសម្គាល់ឃើញអ្នកដែលធ្វើការជាមួយខ្ញុំ បាត់ខ្លួន ដោយគេប្រាប់ថា គេដកអ្នកទាំងនេះយកទៅធ្វើការនៅទីនោះ ឬធ្វើការនៅកន្លែងនេះ ឬកន្លែងនោះជាដើម ។ល។ ខ្ញុំក៏មិនដែលបានឃើញអ្នកដែលបាត់ខ្លួនត្រឡប់មកវិញទេ។”

[១១:២៤:១១]

ឯកសារបន្ទាប់មកទៀត គឺឯកសារ E3/3959 ហើយក៏ជាចម្លើយរបស់កងទ័ពម្នាក់ ដែលមានអាយុ១៩ឆ្នាំ នៅក្នុងកងពល៣១០ ក្នុងឆ្នាំ១៩៧៥ ហើយដែលគេត្រូវបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង នៅចុងឆ្នាំ៧៦ ដល់ចុងឆ្នាំ៧៧។ ERN ភាសាអង់គ្លេស 00278685, ខ្មែរ 00270168 បារាំង 00486100។ គាត់បានឆ្លើយទៅនឹងសំណួរដូចតទៅ៖ “តើនៅពេលណា ដែលអង្គការឲ្យលោកទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង? ឆ្លើយ៖ ប្រហែលនៅចុងឆ្នាំ១៩៧៦ ខ្ញុំត្រូវអង្គការបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ នៅទីនោះ ខ្ញុំធ្វើការដូចជា គាស់គល់ដូង និងគល់ត្នោត។ ការធ្វើព្រលានយន្តហោះនេះ គឺមានតែគ្នាខ្ញុំប៉ុណ្ណោះ មិនមានក្រុមណាមកពីមុន ឬបន្តទៀតទេ។ ក្នុងក្រុមខ្ញុំមានប្រហែល៦០០នាក់ និងមានជនជាតិចិនពីរនាក់ ជាអ្នកបច្ចេកទេសសម្រាប់គ្រប់គ្រង៥០នាក់។ ខ្ញុំធ្វើការនៅទីនោះ ប្រហែល៥ខែ។ តើសុខទុក្ខអ្នកធ្វើការនៅទីនោះ យ៉ាងដូចម្ដេចដែរ? ឆ្លើយ៖ មិនមានសម្លាប់មនុស្សទេ គឺស្លាប់ដោយសារជំងឺ និងធ្វើការងារធ្ងន់ធ្ងរពេកតែប៉ុណ្ណោះ។ អ្នកដែលគ្រប់គ្រងនៅទីនោះគឺ តាធួក និង តាល្វៃ (សព្វថ្ងៃមិនដឹងរស់ ឬស្លាប់ទេ) ដែលជាពួកនិរតី និងនៅកងពល៥០២។”

[១១:២៥:៤៦]

ហើយបន្តទៅទៀត សាក្សីនិយាយអំពីការបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យ ហើយត្រឡប់មកព្រលានយន្តហោះកំពង់ឆ្នាំងវិញ។ ហើយគាត់បានផ្ដល់នូវចំណាប់អារម្មណ៍ដូចតទៅ។ អង់គ្លេសគឺ 00278686, ខ្មែរ 00270169 ទៅដល់ 70 និងបារាំង 0048 --។ “គឺថាបន្ទាប់មកទៀត ចំពោះលោក

ឲ្យលោកធ្វើអ្វីដែរ? បន្ទាប់មកខ្ញុំត្រូវរបួស។ គេបញ្ជូនខ្ញុំទៅមន្ទីរពេទ្យ១៧មេសា ក្រោយមកបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងវិញ។ នៅទីនោះ ខ្ញុំឃើញមានកងទ័ពខ្មែរក្រហមមកពីបូព៌ា និងពីកន្លែងដទៃទៀត រស់នៅទីនោះយ៉ាងច្រើន ជាពិសេសអ្នកពិការ និងអ្នកមានរបួស។ ទាហានទាំងនោះមិនមានអាវុធអ្វីទៀតទេ។ ក្រោយមកទៀត ពួកអ្នកពិការ និងអ្នករបួសទាំងនោះ ត្រូវបានគេយកទៅសម្លាប់ចោលនៅអមលាំង ដោយប្រាប់ថា អ្នកទាំងនោះថាទៅច្បាំង។ ខ្ញុំត្រូវបានរួចខ្លួន ដោយសារឈ្មោះ ចាន់ ប្រធានគដែលជាប្រធានរបស់ខ្ញុំ ពេលប្រយុទ្ធជាមួយវៀតណាម បានជួយខ្ញុំ។ ពេលនោះ តាចាន់ (ខ្ញុំមិនដឹងស្លាប់ឬរស់ទេ) ជាអ្នកសម្លាប់មនុស្សទាំងនោះ។ គាត់គឺជាអ្នកមកពីនិរតី។ តាសុង ក៏ត្រូវបានគេសម្លាប់ក្នុងពេលនោះដែរ។"

[១១:២៧:១៦]

ហើយយើងខ្ញុំសូមបន្តទៅឯកសារ E3/3962 គឺជាចម្លើយរបស់កងទ័ពម្នាក់ អាយុ២១ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មកពីអតីតកងពល៣១០ ហើយគាត់ត្រូវបានបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង នៅដើមឆ្នាំ៧៨ ដល់ខែមករា ៧៩។ ត្រង់ ERN ជាភាសាអង់គ្លេស 00293367 ដល់ 69, ខ្មែរ 00287538 ដល់ 40 និងបារាំង 00355875 ដល់ 78។ គាត់បានឆ្លើយទៅនឹងសំណួរទាំងនោះ៖ "ពេលដែលលោកទៅដល់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងដំបូង តើលោកបានឃើញអ្វី? តើគេឲ្យលោកធ្វើអ្វី? ឆ្លើយ៖ ពេលទៅដល់ដំបូង ខ្ញុំបានឃើញដើមឈើទាំងអស់ ត្រូវបានគេកាប់ផ្ដួលរំលំ ហើយនិងបានឃើញមនុស្សរាប់ម៉ឺននាក់កំពុងធ្វើការ។ ពេលនោះគេឲ្យខ្ញុំគាស់គល់ត្នោត គល់ឈើ និងសម្អាតដីធ្លី។ សំណួរ៖ តើអ្នកដែលខ្ជិលហ្នឹង គេត្រូវរិះគន់ដោយរបៀបម៉េច អ្នកខ្ជិលធ្វើការ? ឆ្លើយ៖ "អ្នកដែលខ្ជិលនោះ គឺត្រូវបានគេយកមកកសាង អប់រំ ហើយបើថានៅតែខ្ជិលទៀត គឺថាត្រូវបានបាត់ខ្លួនរហូតហើយ។ ខ្ញុំឮសួរថា ពាក្យថា បញ្ជូនទៅហ្នឹង គឺថាបាត់ខ្លួនជារហូតហើយ។ នៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ខ្ញុំបានឃើញគេហៅអ្នកមានកំហុសទៅរៀនសូត្រ ដោយចាប់ចងដាក់ឡានបើកចេញទៅ។ ខ្ញុំបានឃើញហេតុការណ៍នេះកើតឡើង ឈ្មោះ វាំង និង អៀង ត្រូវបានឲ្យគេកសាងខ្លួន ព្រោះត្រូវយកទៅភ្នំពេញហើយ បើមិនទៅព្រៃស ក៏ទៅទួលស្លែងដែរ។ បន្ទាប់មកក៏មានការប្រជុំពីពួកនិរតី ទិតៀនខ្ញុំទៀត។"

[១១:២៨:២២]

ហើយក្រោយមកទៀតគាត់និយាយថា៖ "ថាតើលោកយល់ថាយ៉ាងម៉េចដែរ ហេតុអ្វីបានជាអ្នកដែលមកពីភូមិភាគនិរតីជាច្រើនត្រូវបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង? នៅការដ្ឋានព្រលាន

យន្តហោះកំពង់ឆ្នាំង ខ្ញុំបានចូលរួមប្រជុំជាមួយនឹងអ្នកនៅក្នុងអង្គភាពដើម្បីណែនាំ និងប្រាប់ថា មនុស្ស នៅបូព៌ាក្បត់បក្ស រត់ចូលទៅក្នុងប្រទេសវៀតណាម។ ដូច្នេះគេបញ្ជូនមកធ្វើការនៅទីនេះ ដើម្បីតាមដានមើល។ តើលោកបានកត់សម្គាល់ថា ចំណាត់ការបែបណា គេចាត់ចំណាត់ការបែបណាខ្លះ ចំពោះមនុស្សមកពីបូព៌ានោះ? ឆ្លើយ៖ ខ្ញុំកត់សម្គាល់ឃើញថាអ្នកទាំងនោះ បើសិនមានកំហុសឆ្គងតែម្តងគឺត្រូវបាត់ខ្លួន។ កំហុសទាំងនោះគឺមានដូចជា ការធ្វើការមិនតាមផែនការ និយាយស្តីមិនគោរពវិន័យ និយាយស្តីមិនទទួលខុសត្រូវ ។ល។ បន្ទាប់មកគេក៏ហៅទៅ ដោយប្រាប់ថា ទៅរៀនសូត្រ ហើយបាត់ខ្លួនរហូត។ សួរ៖ តើលោកធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនោះរហូតដល់ពេលណា? ឆ្លើយ៖ ខ្ញុំធ្វើការនៅទីនោះរហូតដល់ថ្ងៃវៀតណាមវាយចូលមកកំពង់ឆ្នាំងនៅខែ០១ ឆ្នាំ៧៩ ដោយសភាពការណ៍មិនស្រួល ថ្នាក់លើបានបញ្ជាឲ្យពួកខ្ញុំរើសម្ភារៈ ដូចជារ៉ូឡូ ម៉ាស៊ីនបង្ហាប់ដី ឡានបែន ត្រាក់ទ័រ និងសម្ភារៈសម្រាប់ព្រលានយន្តហោះដុតចោល រួចហើយនាំគ្នារត់ទៅទិសវាំងមាសនៅក្នុងស្រុកទឹកផុស។ សួរ៖ លោកបាននិយាយប្រាប់យើងថា ការបោសសម្អាតមនុស្សមកពីបូព៌ាដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងនោះជាច្រើន សូមលោកបញ្ជាក់ឲ្យបានច្បាស់? ឆ្លើយ៖ នៅពេលដែលពួកខ្ញុំរត់ចេញពីការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនោះមក ប្រហែល១០ថ្ងៃក្រោយមកនៅទួលខ្ពស់ផ្លូវទៅអមលាំងក្នុងខេត្តកំពង់ស្ពឺ គេហៅប្រមូលពួកបូព៌ាដែលរត់ចេញពីព្រលានយន្តហោះកំពង់ឆ្នាំងមកជាមួយគ្នានោះថា បំពាក់អាវុធឲ្យទៅវ៉ៃយួន ហើយអ្នកទាំងនោះក៏បានលើកដៃថាខ្លួនមកពីបូព៌ា។ នៅក្នុងថ្ងៃដដែលនោះ អ្នកទាំងនោះត្រូវបានគេនាំទៅទិសខាងត្បូងវត្តទួលខ្ពស់ដែលមានរណ្តៅជីកទុកហើយស្រាប់។ អ្នកដែលនាំទៅទីនោះគឺមានកាន់កាំភ្លើង។ មុនគេនាំអ្នកទាំងនោះទៅ ខ្ញុំបានឃើញត្រាក់ទ័រជីករណ្តៅដែលមានទំហំប្រហែល១៥ម៉ែត្របួនជ្រុង ជម្រៅប្រហែល៣ម៉ែត្រ។ រយៈពេលប្រហែល៥ថ្ងៃក្រោយមក គេបានដកពួកខ្ញុំទៅភូមិមួយទៀត ដែលមានចម្ងាយប្រហែល១គីឡូម៉ែត្រពីភូមិទួលខ្ពស់ ដែលនៅនោះខ្ញុំបានឃើញពំនូកខោអាវជាច្រើន ហើយខ្ញុំក៏សួរគេ គេនិយាយថាម្ចាស់ខោអាវទាំងនោះត្រូវបានសម្លាប់ចោលអស់ហើយ គឺសម្លាប់នៅក្នុងភូមិទួលខ្ពស់នោះឯង។ ៥ថ្ងៃក្រោយមកទៀត គេបានបំពាក់អាវុធឲ្យពួកខ្ញុំវ៉ៃវៀតណាម។ នៅពេលកំពុងជិះឡានតាមវត្តភូមិទួលខ្ពស់នោះ ខ្ញុំធុំក្លិនស្អុយសាកសពចេញមកពីវត្តទួលខ្ពស់នោះ។ ទើបខ្ញុំសន្និដ្ឋានថា អ្នកដែលគេបណ្តើរយកទៅនោះ ត្រូវគេសម្លាប់ដាក់ក្នុងរណ្តៅដែលខ្ញុំបានឃើញគេជីកនោះហើយ។”

[១១:៣២:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណព្រះរាជអាជ្ញារងអន្តរជាតិ។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលមកវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅបន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងនាំឲ្យគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។

ផ្អាកបន្តិចសិន លោកព្រះរាជអាជ្ញារង មានបញ្ហា!

បាទ សូមអញ្ជើញសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមអភ័យទោសលោកសហព្រះរាជអាជ្ញា។ លោកប្រធាន ខ្ញុំសូមធ្វើសំណើខ្លីមួយលោកប្រធាន តើលោកប្រធានអនុញ្ញាតទេ?

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ តាងនាមឲ្យក្រុម ខៀវ សំផន ខ្ញុំសូមលទ្ធភាពដើម្បីអាចឆ្លើយតបទៅនឹងការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃចន្ទព្រឹក។ ដោយសារតែខ្ញុំបានពិភាក្សាជាមួយក្រុម នួន ជា រួចហើយ គាត់បានបញ្ជាក់ថា គាត់មិនចង់បង្ហាញឯកសារគន្លឹះអ្វីទេ។ ដូច្នេះមានន័យថា យើងមិនចំណាយពេលច្រើនជាងការគ្រោងទុកទេដើម្បីឆ្លើយតបនោះ។ ហើយសវនាការអាចបន្តបានធម្មតាតាមការគ្រោងទុកទៅតាមផែនការ។ សំណើនេះគឺត្រូវបានធ្វើឡើងដើម្បីឲ្យយើងអាចរៀបចំចម្លើយរបស់យើងជាក់លាក់ ដែលមានលេខ ERN ច្បាស់លាស់ទៅនឹងអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ហើយនិងមានផ្នែកផ្សេងៗនៃឯកសារដែលសហព្រះរាជអាជ្ញាបានបង្ហាញនោះ។ នេះជាសំណើខ្លីដែលយើងចង់ធ្វើឡើងផ្អែកទៅតាមកាលវិភាគរបស់អង្គជំនុំជម្រះនោះ។

[១៣:៣២:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យបានច្បាស់ទាំងអស់គ្នា ខ្ញុំយល់ថាភាគីមេធាវីការពារក្តីទាំងពីរមិនបង្ហាញឯកសារគន្លឹះទេមែនទេ? ហើយខ្ញុំចង់ដឹងផងដែរ ថាតើមេធាវីការពារក្តីលោក នួន ជា ដែលយើងដឹងថាមិនបង្ហាញឯកសារអីនោះ គាត់ចង់ធ្វើមតិយោបល់ទៅលើអ្វីដែលបានបង្ហាញដោយសហព្រះរាជអាជ្ញា ឬក៏អត់ ហើយនិងអ្វីដែលបង្ហាញដោយសហមេធាវីនាំមុខនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ចៅក្រម ឡាវែន៍ យើងអត់ទេ។

**ប្រធានអង្គជំនុំ៖**

បាទ ដោយឃើញថាសំណើសុំរបស់សហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ក្នុងការដែលខ្លួនធ្វើការអត្ថាធិប្បាយទៅលើបណ្តាឯកសារ ដែលដាក់បង្ហាញដោយភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្លួនត្រូវការពេលវេលាសមស្របដើម្បីពិនិត្យសិក្សាលើបណ្តាឯកសារដែលបានដាក់បង្ហាញនៅថ្ងៃនេះ នោះគឺជាមានមូលហេតុសមស្រប។ ដូច្នេះ

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតតាមសំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន បានន័យថា នៅថ្ងៃចន្ទ យើងនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីធ្វើការជំទាស់តវ៉ា ឬក៏អត្ថាធិប្បាយលើបណ្តាឯកសារទាំងឡាយដែលដាក់ដោយភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងពេលនៅសល់ យើងនឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីនៅក្នុងអង្គហេតុថ្មី។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៣:៣៤:៤៤]

**លោក វីណ្ស៊ៀម ស្មីត៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរអស់លោកទាំងអស់គ្នា។ ជាដំបូង យើងចង់បញ្ជាក់ថាតើលោកចៅក្រម គឺថាខាងព្រះរាជអាជ្ញាអាចមានឱកាសធ្វើការឆ្លើយតបទៅនឹងក្រុមមេធាវីការពារក្តី ខៀវ សំផន ដែរឬក៏អត់? យើងខ្ញុំចង់ដឹងថាតើយើងខ្ញុំមានឱកាសនឹងធ្វើការឆ្លើយតបទៅវិញដែរឬក៏អត់?

លោក លោកស្រីចៅក្រម យើងចង់ -- យើងៗព្យាយាមគោរពទៅតាមកាលវិភាគទាក់ទងទៅនឹងការកំណត់ពេលវេលារបស់យើង ហើយខាងព្រះរាជអាជ្ញាបានផ្តល់នូវបញ្ជីមួយទៅអ្នកមន្ត្រីច្បាប់ជាន់ខ្ពស់កាលពីសប្តាហ៍មុនហើយ ដើម្បីឱ្យលោក លោកស្រីចៅក្រមចាប់អារម្មណ៍។ ហើយនៅក្នុងឯកសារនោះគឺនិយាយអំពីទំនប់១មករា គឺយើងផ្តល់ឯកសារនៅថ្ងៃទី២៥ ខែ០៨ ២០១៥។ ហើយក៏ទាក់ទងទៅនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ។ ខ្ញុំគិតថា យើងមានពេលវេលាគ្រប់គ្រាន់ដើម្បីបង្ហាញឯកសារទាក់ទងទៅនឹងព្រលានយន្តហោះកំពង់ចាម*(ស៊ីក)* ប៉ុន្តែខ្ញុំនឹងសង្ខេបទៅលើឯកសារដែលនៅសល់ដើម្បីឱ្យអស់លោក លោកស្រីចៅក្រមធ្វើការពិចារណា។ ដូច្នេះហើយ យើងខ្ញុំគិតថាវាជាការសំខាន់ ក្នុងការបង្ហាញអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅព្រលានយន្តហោះកំពង់ឆ្នាំង ក៏ដូចជាការចូលរួមចំណែករបស់ការបោសសម្អាតនៅក្នុងព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ។ ឥឡូវនេះ ខ្ញុំព្យាយាមសង្ខេបទៅលើឯកសារដែលខ្ញុំចង់ធ្វើការពិចារណា។ ទី១ គឺនៅពេលព្រឹកនេះយើងបានបង្ហាញនូវឯកសារមួយចំនួន ពាក់ព័ន្ធទៅនឹង ស៊ូ ម៉េត ដែលជាមេបញ្ជាការកងពល៥០២ ដែលគាត់ទទួលខុសត្រូវលើការដ្ឋានព្រលានយន្តហោះ ក៏ដូចជាទំនាក់ទំនងដែលគាត់មានជាមួយនឹង ឌុច ដែលជាប្រធាន ស-២១ គឺជាមន្ទីរធ្វើទារុណកម្ម ហើយនិងសម្លាប់មនុស្ស។ ហើយខ្ញុំក៏បានបង្ហាញផងដែរថា ស៊ូ ម៉េត បានចូលរួមយ៉ាងសកម្មនៅក្នុងការបោសសម្អាតយោធា។

[១៣:៣៧:១៨]

ហើយឯកសារមួយទៀតដែលបានជួយដល់ការបង្ហាញផងដែរ គឺជាលិខិត គឺជាសារទូរលេខមួយមកពី ស៊ូ ម៉េត ផ្ញើជូន ឌុច។ ហើយខ្ញុំចង់ឲ្យលោក លោកស្រីចៅក្រមពិចារណាផងដែរថា គឺឯកសារ E3/1054។ ឯកសារបន្ទាប់ទៀតគឺ E3/9381 គឺជាឯកសារ មុននឹងជាលេខ E3/1050 E3/1141 ចុះថ្ងៃ១៨ ខែកក្កដា។ ហើយមួយទៀតគឺ E3/1040, E3/8380, 8385 នៅឆ្នាំ៧៧ និង E3/1087 ចុះថ្ងៃ០៣ តុលា ៧៧។ ឯកសារទាំងអស់នេះ គឺថាជាឯកសារដែលខ្ញុំចង់បន្ថែមទៅលើអ្វីដែលខ្ញុំបានអានកាលពីព្រឹកនេះ គឺជាឯកសារទំនាក់ទំនងរវាង ស៊ូ ម៉េត ផ្ញើទៅ ឌុច ជាឯកសារដែលស្នើសុំព័ត៌មានពី ឌុច ទាក់ទងទៅនឹង ថាតើអ្នកដែលគេឃុំនៅស-២១ ហ្នឹង បាននិយាយអ្វីខ្លះអំពីកម្មាភិបាលដទៃទៀតនៅក្នុងកងពលរបស់គាត់ ឬក៏អំពីកម្មាភិបាលផ្សេងៗទៀតនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា។ ប៉ុន្តែអ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាឯកសារទាំងអស់នេះបានបង្ហាញថា ស៊ូ ម៉េត បានចូលរួមយ៉ាងសកម្ម នៅក្នុងការបោសសម្អាត។ ជាពិសេសការសម្លាប់អ្នកនៅក្រោមបង្គាប់របស់គាត់ គឺជាយោធារបស់គាត់ហ្នឹង ដោយមិនមានយុត្តកម្មផ្នែកផ្លូវច្បាប់អ្វីទាល់តែសោះ គឺការសម្លាប់នៅព្រលានយន្តហោះកំពង់ឆ្នាំង និងមកពីកន្លែងផ្សេងៗទៀត។ ហើយឯកសារទាំងអស់នេះបានគាំទ្រទៅដល់សក្ខីកម្មរបស់សាក្សី ដែលនិយាយអំពីការសម្លាប់ ការបាត់ខ្លួន ការអប់រំ ការរៀនសូត្រនៅព្រលានយន្តហោះកំពង់ឆ្នាំង ដោយកងពល៥០២ ដែលទាំងអស់នេះសុទ្ធតែជាសក្ខីកម្មដែលយើងបានស្តាប់ឮ។

[១៣:៣៩:៣៩]

ហើយឯកសារពីរបន្តទៀត ដែលខ្ញុំចង់បង្ហាញ គឺជាឯកសារដែលនិយាយអំពីការបោសសម្អាតនៅកងពល៧១០ៗ គឺទាក់ទងទៅនឹងចំនួនមនុស្សដែលត្រូវបានបោសសម្អាតនៅព្រលានយន្តហោះ។ គឺជាហេតុការណ៍ដែលកើតឡើងនៅក្នុងឆ្នាំ៧៧ ហើយនេះជាឯកសារថ្មី គឺឯកសារ E3/1182 ផ្ញើពី អ៊ុងរ៉ែន ទៅសេនាធិការ។ ហើយឯកសារទាំងអស់នេះ បានបង្ហាញអំពីចំនួនយ៉ាងច្រើនរបស់កងពល៧១០ ដែលធ្វើការនៅក្នុងព្រលានយន្តហោះ។ ហើយដែលបង្ហាញពីតួនាទីយ៉ាងសកម្មរបស់គាត់នៅក្នុងបោសសម្អាត។ គឺនៅក្នុងឯកសារទាំងអស់នេះ បានបង្ហាញ គឺចុះខែកក្កដា ឆ្នាំ៧៨។

លោក លោកស្រីចៅក្រម ឯកសារទាំងអស់នេះ ដែលយើងខ្ញុំបានដាក់ជូន គឺជាឯកសារដែលអាចគាំទ្រដោយឯកសារ E3/369 ជាកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់មេបញ្ជាការកងវរៈដែលធ្វើការនៅព្រលានយន្តហោះផងនោះដែរ ហើយឯកសារនេះ ក៏បានផ្តល់ភស្តុតាងអំពីឧក្រិដ្ឋកម្មនៃការបោសសម្អាតនៅទីនោះ។

ហើយចំណុចទី៣ គឺប្រភេទឯកសារទី៣ ដែលបង្ហាញអំពីគោលគំនិត ឬក៏ទស្សនៈ នៃការដាក់ឲ្យទៅជាទាសករ ដែលថាកម្មករត្រូវបង្ខំធ្វើការ ទោះបីថាពួកគាត់ ក្នុងលក្ខខណ្ឌមួយដែលថាពួកគាត់មិនអាចចាកចេញពីព្រលានយន្តហោះបាន ឬក៏ត្រូវបានគេដាក់ឲ្យទៅជាទាសករ។ ឯកសារទាំងអស់នេះ គឺ E3/1094 ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ៧៨ មកពីមន្ទីរ៥០៣គឺផ្ញើជូនអង្គការ ដែលបង្ហាញពីព្រឹត្តិការណ៍មួយចំនួននៅក្នុងខែកក្កដា។ ដែលអ្នកជាប់ឃុំ ឬក៏ដែលជាទាហាន ឬក៏កម្មករនោះបានរត់ចេញពីការដ្ឋាន ហើយត្រូវបានគេចាប់ក្នុងពេលផ្សេងៗគ្នា ហើយអ្នកទាំងអស់នោះ ត្រូវបានគេចាត់ទុកថាជាខ្មាំង។ បន្ថែមពីលើនេះឯកសារទាំងអស់នោះ ក៏បាននិយាយអំពីសារៈសំខាន់នៃការអនុវត្តនូវមធ្យោបាយមួយចំនួនចំពោះទាហាន ដោយឲ្យមានការការពារយ៉ាងរឹងមាំនៅជុំវិញបរិវេណការដ្ឋាន។ ហើយខ្ញុំសូមលើកបញ្ជាក់ថា បញ្ហាទាំងអស់នេះ គឺវាពាក់ព័ន្ធសំខាន់ទៅនឹងហេតុការណ៍នានា ជាពិសេស គឺហេតុការណ៍ដាក់ឲ្យទៅជាទាសករជាដើម។

[១៣:៤២:៥៨]

ហើយឯកសារប្រភេទទី៤ និងឯកសារប្រភេទចុងក្រោយ ដែលខ្ញុំចង់ឲ្យអស់លោក លោកស្រីចៅក្រមធ្វើការពិចារណា និងមើលពិចារណាផងដែរ គឺឯកសារដែលពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅភូមិភាគបូព៌ា គឺអ្នកដែលជាប់ឃុំមកពីភូមិភាគបូព៌ា ត្រូវបានគេយកទៅឃុំឃាំងនៅក្នុងការដ្ឋាន ហើយក្រោយមកទៀត ត្រូវបានគេបោសសម្អាតជាទ្រង់ទ្រាយធំ។ ហើយបន្ទាប់មកទៀត នៅពេលដែលវៀតណាមចូលមក គឺគេបោះបង់ចោលព្រលានយន្តហោះ។ ដូច្នេះលោក លោកស្រីចៅក្រម ប្រហែលជាបានធ្លាប់ស្តាប់នូវឯកសារដែលនិយាយអំពី ឬក៏ដែលបានផ្តល់នូវភស្តុតាងអំពីទាហានមកពីខាងបូព៌ាដែលត្រូវបានគេសម្លាប់នៅជិតវ៉ាំរមាសជាដើម គឺមានចម្ងាយតែប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះ ពីការដ្ឋានព្រលានយន្តហោះ។ មានសាក្សីពីររូបដែលផ្តល់នូវភស្តុតាងជាក់ស្តែងទាក់ទងទៅនឹងហេតុការណ៍នេះ ហើយដែលលោក លោកស្រីចៅក្រមបានស្តាប់រួចមកហើយគឺ E3/7893។ ហើយសាក្សីរូបនេះ បាននិយាយអំពីការសង្កេតឃើញផ្ទាល់របស់គាត់នៅវត្តទឹកផុស គឺនៅជិតវ៉ាំរមាស គឺនៅជិតស្ថានីយរថភ្លើងវ៉ាំរមាស។ ហើយគាត់បាននិយាយអំពីការសម្លាប់ជាទ្រង់ទ្រាយធំគឺ 7894 គឺជាការសម្លាប់នៅភូមិក្បាលឡាន។ ហើយឯកសារទាំងពីរនេះ គឺនិយាយអំពីការបោសសម្អាតការសម្លាប់ជាទ្រង់ទ្រាយធំចំពោះទាហានដែលរត់ចេញពីការដ្ឋានព្រលានយន្តហោះ នៅពេលដែលវៀតណាមចូលមកដល់តំបន់នេះ។ ហើយឯកសារនេះក៏និយាយអំពីការដែលពួកគាត់ត្រូវបានគេបោកបញ្ឆោតឲ្យមកធ្វើការប្រឆាំង។

[១៣:៤៥:១៥]

ខ្ញុំដឹងថាជនជាប់ចោទមិនត្រូវបានចោទប្រកាន់ពីបទល្មើសទាំងអស់នេះទេ ព្រោះថាហេតុការណ៍ទាំងអស់នេះកើតឡើងនៅក្រោយយុត្តាធិការលើពេលវេលារបស់អង្គជំនុំជម្រះ។ ប៉ុន្តែអង្គជំនុំជម្រះអាចប្រើប្រាស់ភស្តុតាងទាំងអស់នេះ ដើម្បីបង្ហាញ ប្រសិនបើមិនអាចទេអាហ្នឹងនោះគឺជាផន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។ ហើយឯកសារនេះក៏បាននិយាយផងដែរ ថាតើអ្នកដែលមកពីភូមិភាគបូព៌ាត្រូវបានគេសម្លាប់នៅព្រលានយន្តហោះកំពង់ឆ្នាំងដែរឬអត់? ដូច្នេះភស្តុតាងទាំងអស់នេះបង្ហាញថា តើនៅពេលក្រោយមកហ្នឹងគេប្រព្រឹត្តយ៉ាងដូចម្តេចចំពោះអ្នកទោសទាំងអស់នោះ។ ដូច្នេះយើងអាចឃើញថា អ្នកជាប់ឃុំត្រូវបានគេប្រព្រឹត្តក្នុងលក្ខណៈជាការធ្វើទុក្ខបុកម្នេញនៅការដ្ឋានព្រលានយន្តហោះ។ ប៉ុន្តែយើងយល់ថា វាមិនអាចជាភស្តុតាងក្នុងការបង្ហាញពិរុទ្ធភាពរបស់ជនជាប់ចោទនៅក្នុងការសម្លាប់រង្គាលទាំងអស់នេះទេ។ ដូច្នេះខ្ញុំគិតថា ឯកសារទាំងអស់ដែលខ្ញុំបានបង្ហាញនៅថ្ងៃនេះគឺបង្ហាញថា កងពល៥០២ទទួលខុសត្រូវក្នុងការកសាងព្រលានយន្តហោះនៅកំពង់ឆ្នាំង ដើម្បីទប់ទល់ជាមួយខ្មាំងមកពីខាងក្រៅ ដូចជាមកពីដូចជា វៀតណាមជាដើម។ ហើយកងពលនេះបានសម្លាប់ វៀនសូត្រ និងលត់ដំទៅលើកម្មករទាំងអស់នៅក្នុងព្រលានយន្តហោះដែលគេជឿជាក់ថាជាខ្មាំង។ ការធ្វើដូច្នេះ ដើម្បីការពារខ្លួនគេពីខ្មាំងផ្ទៃក្នុង។ ហើយឯកសារដែលខ្ញុំបានលើកបង្ហាញកន្លងមកទាំងនេះបានបង្ហាញថា មេបញ្ជាការរបស់កងទ័ពបដិវត្តន៍កម្ពុជា រួមទាំងកងពល៥០២ បង្ហាញថាខ្មាំងផ្ទៃក្នុងគឺជាខ្មាំងដែលមានគ្រោះថ្នាក់ជាងខ្មាំងមកពីខាងក្រៅ។ ហើយក៏បង្ហាញផងដែរថា កងពល៥០២ ឬក៏មេដឹកនាំកងពល៥០២ ជាអ្នកទទួលខុសត្រូវទៅលើការកសាងព្រលានយន្តហោះ ព្រោះថាការកសាងព្រលានយន្តហោះហ្នឹងមានគោលដៅពីរ។ ទី១ ដើម្បីការពារ និងទី២ ដើម្បីបោសសម្អាតខ្មាំង។

ដូច្នេះខ្ញុំសូមបញ្ចប់ការធ្វើបទបង្ហាញទាក់ទងទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ ហើយខ្ញុំសូមបន្ត សូមប្រគល់វេទិកាជូនទៅដើមបណ្តឹងរដ្ឋប្បវេណី ហើយនៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់ខ្ញុំនឹងធ្វើការបង្ហាញឯកសារបន្តទៀត។

[១៣:៤៨:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៀតនេះ សូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម ព្រមទាំងភាគី សាធារណជន និងដើមបណ្ដឹងរដ្ឋប្បវេណីសាជាថ្មី។ នៅពេលនេះ ពាក់ព័ន្ធទៅនឹងការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនេះ ខ្ញុំពុំមានឯកសារច្រើនសម្រាប់បង្ហាញទេ គឺមានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីរ។ ដោយលើកសម្រង់ខ្លីៗមកបង្ហាញ ឬអានជូនលោក លោកស្រីចៅក្រមនៅក្នុងការពិចារណា។

ខ្ញុំសូមជម្រាបថា ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីររូបនេះ គឺជាអនីតិជននៅពេលដែលគាត់ត្រូវបានបញ្ជូនទៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដោយម្នាក់មានអាយុ ម្នាក់ៗមានអាយុ១៥ ឬក៏១៦ឆ្នាំនាពេលនោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីទី១ ដែលមានឈ្មោះថា រូ រ៉េន ឯកសាររបស់គាត់ គឺឯកសារ E3/9694។ ហើយខ្ញុំសូមជម្រាបថា លោក រូ រ៉េន នេះលោកត្រូវបានគេយកទៅធ្វើទ័ពនៅកងពល៧០៣ថ្មី ប្រចាំនៅទីក្រុងភ្នំពេញ ហើយក្រោយមកត្រូវបានបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ ហើយដែលនៅក្នុងនោះ ខ្ញុំសូមដកស្រង់សម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ ដែលមាន ERN ជាភាសាខ្មែរគឺ 00365048, ជាភាសាអង់គ្លេស 00398344, ERN ជាភាសាបារាំងគឺ 00909841។ ដោយខ្ញុំសូមដកស្រង់ដូចតទៅ៖ "ឆ្នាំ១៩៧៧ គេបញ្ជូនខ្ញុំទៅធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដោយយកទៅវាយថ្មភ្នំទាំងយប់ទាំងថ្ងៃ។ ខ្ញុំត្រូវនៅទីនោះរហូតដល់ចុងឆ្នាំ១៩៧៨។ ស្ថានភាពពេលនោះមានមនុស្សស្លាប់ច្រើនណាស់ ស្លាប់ដោយអត់បាយ ខ្លះទៀតត្រូវអង្គការយកទៅសម្លាប់ចោល មិនអាចគណនាបានឡើយ។"

[១៣:៥២:០៦]

ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីទី២ ដែលជាឯកសារដែលខ្ញុំ ឯកសារចុងក្រោយរបស់ខ្ញុំសម្រាប់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង គឺដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានឈ្មោះថា ផែ ប៉ាប។ ឯកសាររបស់គាត់គឺលេខ E3/6427a ដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដែលពីដំបូងគាត់រស់នៅខេត្តកំពង់ធំនៅឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ (បច្ចុប្បន្ននេះស្រុកស្ទឹងសែន)។ ក្រោយមក គាត់ត្រូវបាននាំឲ្យចូលនៅក្នុងកងពល៣១០ ដែលមានកងកុមារមួយនៅក្នុងនោះ ហើយកងពលនេះនៅទីក្រុងភ្នំពេញ ដែលគាត់បញ្ជាក់នៅក្នុងឯកសាររបស់គាត់ថា នៅមុខម្តុំមុខមន្ទីរពេទ្យកាល់ម៉ែត ហើយដែលគាត់ត្រូវបានគេឲ្យធ្វើជាអ្នកព្យាបាលអ្នករបួសនៅទីមន្ទីរពេទ្យនោះផងដែរ។ ក្រោយមកគាត់ត្រូវបានគេបញ្ជូនទៅព្រលាន

យន្តហោះខេត្តកំពង់ឆ្នាំង។ ដូច្នេះខ្ញុំសុំដកស្រង់សម្រង់ ERN របស់គាត់ សម្រង់របស់គាត់ដែលមាន ERN ដូចតទៅ ERN ជាភាសាខ្មែរ 00581529 មិនមាន ERN ជាភាសាអង់គ្លេស ឬជាភាសាបារាំងទេ។ ដូច្នេះខ្ញុំសុំអានសម្រង់ដូចតទៅ៖ "ក្រោយពីនោះមានព្រឹត្តិការណ៍ចាប់ សោ ភឹម។ បន្ទាប់ពីនោះទើបគេបញ្ជូនខ្ញុំទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង។ ការងារដែលខ្ញុំធ្វើគឺ សម្អាតសំរាមនៅកន្លែងសង់ព្រលាន បៀកស៊ីម៉ង់ត៍ ស្រោចដំណាំ។ ខ្ញុំត្រូវក្រោកតាំងពីម៉ោងបី ឬបួនយប់ស្រោចដំណាំ។ កងខ្ញុំតែងតែបាត់មនុស្ស ខ្ញុំអត់ដឹងថា បាត់ទៅណាទេ។"

នេះគឺជាឯកសារចំនួនពីរ ដែលខ្ញុំអាចបង្ហាញបានពាក់ព័ន្ធទៅនឹងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដែលឯកសារនេះ និយាយអំពីការងាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងនិយាយអំពីថាតើអ្វីគាត់បានឃើញចំពោះការប្រព្រឹត្តទៅលើអ្នកដទៃទៀតនៅខេត្តកំពង់ឆ្នាំង។ បាទ ខ្ញុំសូមបញ្ជាក់ឡើងវិញចំពោះឯកសារទី១ ប្រហែលជាខ្ញុំបានអានច្រឡំ គឺឯកសារដែលមានលេខ ERN -- ដែលមានលេខ E3/4694 ដែលជាឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ រូ រ៉េន។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។

[១៣:៥៦:១៥]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី។ ខ្ញុំនឹងបន្តបទបង្ហាញរបស់ខ្ញុំអំពីការដ្ឋានទំនប់ត្រពាំងថ្ម។ ឯកសារទី១ ដែលខ្ញុំចង់ឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ពិចារណាគឺឯកសារ E3/771។ ឯកសារនេះ គឺជាការចេញផ្សាយនៃទស្សនាវដ្តីទង់បដិវត្តចុះខែកក្កដា សីហា ១៩៧៧ ហើយជាឯកសារមួយគួរឲ្យចាប់អារម្មណ៍ណាស់ ដោយសារថាវាមានពាក់ព័ន្ធទៅនឹងគម្រោងសាងសង់ត្រពាំងថ្មបីបួនទំព័រ ហើយ ERN ពាក់ព័ន្ធគឺអង់គ្លេស 00509685 ដល់ 87 ហ្នឹងជាភាសាអង់គ្លេស, ជាភាសាខ្មែរ 00376343 ដល់ 45 និងជាភាសាបារាំង 00594052 ដល់ 55។ ចំណុចទី១ គឺថាឯកសារនេះទាក់ទងទៅនឹងការរៀបរាប់លម្អិតអំពីគម្រោងលើកទំនប់នេះ។ ឯកសារនេះក៏បានផ្តល់នូវកាលបរិច្ឆេទ គឺខែកុម្ភៈ ១៩៧៧ និងបញ្ជាក់ថាក្រោយពីការ -- ទំនប់នោះគឺថាបន្តធ្វើរហូត

រដូវប្រាំងឆ្នាំ១៩៧៨។ ហើយខ្ញុំនឹងសូមអានផ្នែកមួយនៃសម្រង់ សូមដកស្រង់៖ “បងប្អូនយើងចាប់ផ្ដើមលើកទំនប់នៅថ្ងៃទី១៦ ខែកុម្ភៈ ១៩៧៧ ហើយគឺគេចាប់ផ្ដើមកសាងទំនប់ត្រពាំងថ្មនៅទិសខាងលិចសំដៅទៅភ្នំពន្លៃ គឺដែលមានប្រវែងប្រាំបីពាន់--។ ហើយយើង ក្រោយមកចាប់ផ្ដើមពីទិសខាងកើត ពីប៉ោយតាអុង ហើយបន្តទៅខាងស្មោង។ ហើយចប់ពីស្មោងទៅខាងជើង ដើម្បីឲ្យទៅដល់រហូតទៅទល់ភ្នំកូនខ្ពែង ចម្ងាយ១៤.៨០០ម៉ែត្រ។ សរុបទាំងអស់ទំនប់អាងត្រពាំងថ្មមានប្រវែង២០គីឡូម៉ែត្រ ហើយមានកម្ពស់៨ម៉ែត្រ បាតក្រោម៤០ទៅ៧០ម៉ែត្រ ហើយខ្នងលើពី៧ទៅ៨ម៉ែត្រ ទៅ១០ម៉ែត្រ។ ចេញពីទំនប់អាងនេះ បងប្អូនមានជីកប្រឡាយធំៗបីខ្សែទៀត ដែលមាត់លើប្រវែង១២ម៉ែត្រ បាតក្រោម២ម៉ែត្រជម្រៅ១,៥ម៉ែត្រទៅ២ម៉ែត្រ។ ខ្សែទី១ បងប្អូនជីកចេញពីទ្វារទឹកទី១ ធ្លាក់ទៅដល់ស្ទឹងរំដួលចម្ងាយជាង២០គីឡូម៉ែត្រ។ ខ្សែទី២ ចេញពីទ្វារទឹកទី២ ឆ្លងកាត់ផ្លូវជាតិលេខ៦ វាលរហាលរហូតដល់អូររន្ទះ។ ខ្សែទី៣ គឺថានៅក្នុងរដូវប្រាំង បងប្អូនពង្រីងពង្រីកឲ្យកាន់តែធំ និងកាត់តែរឹងមាំថែមទៀត ដោយលើកទំនប់អាងឲ្យបានកម្ពស់៨ម៉ែត្រ បាត១២០ម៉ែត្រ ខ្នងលើ២៥ម៉ែត្រ ដើម្បីតម្កល់ទុកទឹកប្រើប្រាស់ឲ្យបាន១លានម៉ែត្រគូប។” បញ្ចប់ការដកស្រង់។

[១៤:០០:១៧]

ហើយមុននឹងខ្ញុំបន្តជាមួយឯកសារនេះទៀត គឺថាការរៀបរាប់នេះ វាស៊ីចង្វាក់គ្នាទៅនឹង គឺឯកសារ E3/8050 ដែលរៀបរាប់កាន់តែលម្អិតទៅទៀត ហើយវាស៊ីចង្វាក់គ្នាផង។ ឧទាហរណ៍ ការស្ដីអំពីអត្តសញ្ញាណទីតាំង គឺបានរៀបរាប់ថាមានប្រវែងប្រហែលជា៩គីឡូម៉ែត្រ ហើយឯកសារមួយទៀតថា ប្រហែលជា១៣ ប្រវែង១៣គីឡូម៉ែត្រ។ ERNជាភាសាអង់គ្លេស00428005, ខ្មែរ00464720 និងបារាំង 00450434។ ដូច្នេះផ្នែកនៃឯកសារនេះ យើងខ្ញុំសូមលើកឡើងថា វាមានការពាក់ព័ន្ធទៅនឹងការដឹងជាលម្អិតរបស់មជ្ឈិម អំពីគម្រោងសាងសង់ទំនប់នេះ និងអំពីទំហំនៃការសាងសង់ទំនប់នេះ ក៏ដូចជាផែនការសម្រាប់ពេលអនាគតផងដែរ។ ដូច្នេះ ខ្ញុំសូមបន្តអានជាមួយឯកសារនេះ។ ឯកសារនិយាយថា គឺទំនប់នេះត្រូវតែធ្វើសម្រេចទៅតាមផែនការរបស់មជ្ឈិម។ ហើយក៏បានរៀបរាប់អំពីស្ថានភាព ក៏ដូចជាបរិបទដែលប្រឈមមុខដោយកងទ័ពខ្មែរក្រហមនៅពេលដែលប្រឈមមុខជាមួយនឹងរបប លន់ នល់ ផង។ ខ្ញុំសូមអានផ្នែកដែលពាក់ព័ន្ធនេះ សូមដកស្រង់៖ “នៅក្នុងអំឡុងពេលកសាងសង់អាងត្រពាំងថ្ម សហករណ៍របស់យើងទាំងស្រីទាំងប្រុស យុវជន យុវនារី មកពីតំបន់ភាគខាងជើងនៃបាត់ដំបងបានប្រើប្រាស់កម្លាំងកាយចិត្តរបស់ខ្លួន ហើយបូជាអ្វីៗគ្រប់យ៉ាងដើម្បីបម្រើដល់ផល

ប្រយោជន៍សមូហភាព និងសម្រេចផែនការរបស់បក្សឲ្យបានទាំងស្រុង និងយ៉ាងជោគជ័យ។ បងប្អូនយើងបានធ្វើការ និងស្នាក់នៅការដ្ឋានការងារនេះជាច្រើនខែ ដូចដែលអ្វីដែលយុទ្ធជន យុទ្ធនារីនៃកងទ័ពបដិវត្តន៍របស់យើងបានធ្វើនៅពេលដែលពួកគេវាយប្រយុទ្ធ ដើម្បីកម្ទេចខ្មាំងនៅក្នុងអំឡុងពេលសង្គ្រាមដែរ។ បងប្អូនបានប្រយុទ្ធកាប់ដី រែកជញ្ជូនដីទាំងយប់ទាំងថ្ងៃ ក្រោមកម្តៅថ្ងៃចែងចាំងពេញមួយប្រាំងដោយឥតត្អូញត្អែរអ្វីឡើយ។ ផ្ទុយទៅវិញ នៅគ្រប់ពេលវេលាធ្វើការងារទាំងអស់ បងប្អូនរីករាយជាប់ជានិច្ច ហើយកាន់តែវាយសម្រុកផង កាន់តែឯកភាពគ្នា ហើយកាន់តែស្និទ្ធស្នាលស្រឡាញ់គ្នាទៅទៀត។ យោងទៅតាមលក្ខខណ្ឌភូមិសាស្ត្រ ដែលជាវាលដ៏ធំធេងនេះ គ្មានបឹងត្រពាំង ហើយកម្លាំងក៏មានច្រើនរាប់ម៉ឺននាក់។ យុទ្ធជន យុទ្ធនារីយើងត្រូវតែដោះស្រាយគ្រប់បញ្ហាទាំងអស់ប្រចាំថ្ងៃ ជាក់ស្តែងគឺប្រយុទ្ធនឹងការខ្វះខាតទឹកប្រើប្រាស់ ព្រោះរទេះ និងឡានដឹកជញ្ជូនទឹកជាយកមកផ្តល់ជូនមិនទាន់ និងមិនគ្រប់គ្រាន់តាមសេចក្តីត្រូវការទេ។ នៅចំណុចចំពោះសហករណ៍នេះ បងប្អូនមិនត្រឹមតែមិនស្មុគស្មាញ ឬត្អូញត្អែរប៉ុណ្ណោះទេ តែបងប្អូនបានឯកភាពគ្នាជាទស្សនៈ ជាគោលជំហរថា ការលំបាករបស់យើងពេលនេះ ទោះជាយ៉ាងណាក៏ដោយ ក៏មិនស្មើនឹងការលំបាករបស់បង ប្អូន បងៗកម្មាភិបាល និងយុទ្ធជន យុទ្ធនារី កងទ័ពបដិវត្តន៍ដែលប្រយុទ្ធកសាងកម្លាំងបដិវត្តន៍ កសាងមូលដ្ឋានបង្អែកបដិវត្តន៍ និងវាយប្រយុទ្ធកម្ទេចខ្មាំង ក្នុងសម័យតស៊ូនយោបាយសម្ងាត់ នយោបាយផ្ទៃក្នុង និងសង្គ្រាមបដិវត្តន៍ជាង៥ឆ្នាំកន្លងមកនោះដែរ។”

[១៤:០៤:១៨]

ដូច្នេះផ្នែកនេះ យើងខ្ញុំសូមលើកឡើងថាវាពាក់ព័ន្ធទៅនឹងចំណុចជាច្រើន។ ទី១ គឺការដឹងឮរបស់មជ្ឈិមចំពោះអាងនេះ ហើយថាកម្លាំងពលកម្មគឺថាត្រូវតែធ្វើឲ្យបានសម្រេចផែនការបក្ស និងឲ្យបានជោគជ័យ ហើយក៏ដូចជាទំហំនៃការងារដ៏ច្រើនលើសលប់ ដែលមានកម្លាំងពលកម្មរហូតទៅដល់រាប់ពាន់នាក់។

ឯកសារដែលចង់បង្ហាញបន្ទាប់គឺឯកសារ E3/300។ ឯកសារនេះមានសម្រង់ចេញពីការផ្សាយចេញពីវិទ្យុផ្សាយសំឡេងរបស់កម្ពុជាពីភ្នំពេញ។ សម្រង់នេះក៏និយាយអំពីការដ្ឋានទំនប់ត្រពាំងថ្មដែរ ហើយក៏ៗបានលើកឡើងអំពីផែនការរបស់បក្សកម្មុយនីស្តកម្ពុជាទាំងស្រុងផងដែរ។ ERN ដែលមានការពាក់ព័ន្ធនេះគឺថាជាខ្មែរ S00704541, អង់គ្លេស S00702870, បារាំង S00006803។ សេចក្តីផ្សាយនេះគេនិយាយអំពីៗការបង្កើតៗនូវសហជីពកម្មករកម្ពុជាលើកទី២២ ខួបលើកទី២២ ដែលមាន

ចំណងជើងថា "ប្រព័ន្ធសមូហភាព និងឯកជនភាវូបនីយកម្ម គឺវាខុសគ្នាទាំងថ្ងៃទាំងយប់។ ហើយគម្រោងនេះត្រូវបានធ្វើឡើងដោយមានគំនិតផ្តួចផ្តើមដ៏ត្រចះត្រចង់ពីថ្នាក់ដឹកនាំ ដោយសារតែជំហរឯករាជ្យ អធិបតេយ្យ ដែលត្រូវបានបង្កើតនូវប្រព័ន្ធសមូហភាពមួយនៅទូទាំងប្រទេសកម្ពុជា នៅក្នុងអំឡុងពេលនោះដោយម្តង។" បញ្ចប់ការដកស្រង់។

ហើយបន្ទាប់មកឯកសារនេះក៏ពន្យល់អំពីថា តើប្រព័ន្ធសមូហភាពហ្នឹង វាពាក់ព័ន្ធនឹងអ្វីខ្លះ។ សូមដកស្រង់៖ "ទាក់ទងទៅនឹងការកសាងជាតិ នៅលើវិស័យកសាងជាតិ ក្រោមរបបសមូហភាពដ៏ឧត្តុង្គឧត្តម ជនបទនៃកម្ពុជាប្រជាធិបតេយ្យ បានផ្លាស់ប្តូរមុខមាត់យ៉ាងច្រើន ដែលមានលក្ខណៈខុសគ្នាទាំងស្រុងទៅនឹងជនបទកាលពីសម័យសង្គ្រាម និងមុនរំដោះ។ ការរៀបចំប្រព័ន្ធធារាសាស្ត្រ ត្រូវបានស្ថាបនាឡើងនៅគ្រប់ភូមិភាគ គ្រប់តំបន់ និងគ្រប់ស្រុកភូមិទាំងអស់។" បញ្ចប់ការដកស្រង់។ ហើយខាងក្រោមមកទៀត និយាយអំពីការប្រព័ន្ធផ្គត់ផ្គង់ទឹក ហើយក្នុងនោះការដ្ឋានទំនប់ត្រពាំងថ្ម ក៏លើកយកមកនិយាយមួយក្នុងចំណោមក្នុងអាងស្តុកទឹកដទៃៗទៀតផងដែរ។

[១៤:០៧:៣០]

ឯកសារដែលខ្ញុំបង្ហាញមួយទៀតនោះ គឺឯកសារ E3/18 នេះគឺជាសៀវភៅរបស់ ខៀវ សំផន និយាយអំពីប្រវត្តិសាស្ត្រកម្ពុជាថ្មីៗ និងមូលហេតុជាច្រើនទៀតនៅពីខាងក្រោយនេះ។ ហើយ ERN ដែលមានការពាក់ព័ន្ធភាសាអង់គ្លេស 00103780, ខ្មែរ 00103878 និងភាសាបារាំង 00595487។ ហើយការដែលខ្ញុំដាក់*ហាយឡាយ*នេះ គឺៗថា ខៀវ សំផន បាននិយាយអំពីការបានឃើញ ពិនិត្យឃើញការដ្ឋានទំនប់ត្រពាំងថ្ម នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ៧៥ ដល់៧៩។ ហើយគាត់ក៏ឡើងចំណុចដូចគ្នាដែរ នៅក្នុងឯកសារ E3/592 ដែលជាលិខិតចំហរមួយមកពី ខៀវ សំផន។ ហើយនៅក្នុងឯកសារនេះ គាត់បានលើកឡើងដូចតទៅ សូមដកស្រង់៖ "បន្ថែមលើនេះទៅទៀត ទោះបីខ្ញុំបានធ្វើដំណើរតិចតួចក៏ដោយចន្លោះពីឆ្នាំ៧៥-៧៩ ខ្ញុំបានឃើញផ្ទាល់ភ្នែកនូវសមិទ្ធិផល ដែលខ្ញុំបានឃើញដូចជា ការកសាងប្រព័ន្ធធារាសាស្ត្រនៅក្នុងទូទាំងប្រទេស ដូចជាការដ្ឋានទំនប់ត្រពាំងថ្ម ដែលស្ថិតនៅក្នុងភ្នំស្រុក ខេត្តបន្ទាយមានជ័យនេះជាដើម ហើយនិងអាងទឹកកំពីងពួយ ដែលនៅទិសខាងកើតខេត្តបាត់ដំបង ហើយដែលលាតៗសន្ធឹង ទៅតាមវាលស្រែដាច់កន្ទុយភ្នែក។ ទាំងអស់នេះ ធ្វើឱ្យខ្ញុំជឿរបបនេះ ហើយនិងគោរពដល់ស្មារតីនៃមនុស្សរាប់រយពាន់នាក់ ដែលបានបូជាអាយុជីវិតរបស់ខ្លួន ហើយក៏ដូចជាការធ្វើការងារនៅក្នុងការដ្ឋានមួយនេះដែរ។" បញ្ចប់ការដកស្រង់។ គឺចំណុចនេះ គឺបញ្ជាក់ឱ្យ

ឃើញថា ខៀវ សំផន បានដឹងអំពីទំហំនៃការលើកទំនប់នេះ ERN ពាក់ព័ន្ធនោះគឺជាភាសាអង់គ្លេស 00002803, បារាំង 00623776 និងខ្មែរ 00002799។

[១៤:១០:១៣]

ឯកសារបន្ទាប់គឺឯកសារ E3/178 ដែលជារបាយការណ៍ប្រចាំសប្តាហ៍របស់គណៈកម្មាធិការតំបន់៥ ដែលលើកឡើងចេញនៅថ្ងៃទី២១ ឧសភា ៧៧។ ឯកសារនេះ គឺបានផ្ញើជូនទៅលេខាភូមិភាគ ក៏ដូចជាទៅមន្ទីរ៥៦០។ គឺថាឯកសារនេះមានព័ត៌មានច្រើនណាស់ ពាក់ព័ន្ធទៅនឹងការដ្ឋានអាងទំនប់ត្រពាំងថ្មនេះ។ ផ្នែកទី១ ដែលខ្ញុំចង់លើកដកស្រង់ គឺនិយាយអំពីអាងទំនប់ទឹកនេះទាំងស្រុង ដែលនិយាយថា អាងទំនប់ទឹកត្រពាំងថ្មនេះជាយុទ្ធសាស្ត្រ គឺការកសាងទ្វារទឹកធំៗ ចំនួនបី ដែលត្រូវបញ្ចប់នៅក្នុងខែឧសភា ទុកសំណង់ខាងលើបញ្ចប់ជាបណ្តើរៗតទៅទៀត។ អាងទឹក និងទ្វារទឹកនៅជើងគ្រួសបានបញ្ចប់ហើយ។ ព្រែកជីកប្រវែង២៣គីឡូម៉ែត្រ តភ្ជាប់ពីទ្វារទឹកទី១ត្រពាំងថ្ម មកស្ទឹងអន្លង់សាដែលមានមាត់លើ១២ម៉ែត្រ បាតក្រោម៦ម៉ែត្រ ជម្រៅ១ម៉ែត្រ បានបញ្ចប់ហើយ។" ដូច្នេះផ្នែកនេះ ក៏វាពាក់ព័ន្ធនឹងចំណុចពីរ គឺរាយការណ៍ពីតំបន់ទៅថ្នាក់លើ ហើយក៏ដូចជាយុទ្ធសាស្ត្រនៃការកសាងដែលត្រូវ ដែលបានបញ្ចប់រួចហើយនោះ។ ហើយសារនេះផងដែរ ERN ជាភាសាអង់គ្លេសគឺ 00342719, ខ្មែរ 00275596 និងបារាំង 00623317។

ចំណុចទី២ ដែលខ្ញុំចង់លើកឡើងនៅក្នុងឯកសារនេះ គឺឯកសាររៀបរាប់អំពីចេតនានៅក្នុងការធ្វើវិទ្ធង្សនារារាំងទៅដល់គម្រោងការកសាងលើកទំនប់នេះ។ ខ្ញុំសូមអានផ្នែកនេះតែម្តង សូមដកស្រង់៖ "ដោយការវែកមុខ និងរកឃើញពួកក្បត់ សមាសភាពពួក១៧មេសា មកពីភ្នំពេញ គេបានរៀបចំផែនការដើម្បីបំផ្លាញអាងស្តុកទឹករបស់យើង។ តាមការវែកមុខ ហើយនិងយើងដឹងថាល្បិចរបស់ខ្មាំង គឺគេលាក់របស់ដូចជាមាន ចប កាំបិត រណារ ពូថៅជាដើម ។ល។ គេបំផ្លិចបំផ្លាញនេះ ដើម្បីរារាំងយើងកុំឲ្យប្រើប្រាស់ឧបករណ៍ទាំងអស់នេះ។ ដល់ពេលយើងដឹង ឬក៏ចាត់តាំងឲ្យពួកគេធ្វើការ ពួកគេយកលេសថា ពួកគេគ្មានឧបករណ៍សម្រាប់ធ្វើការទាំងនេះទេ។ ហើយយើងបានវែកមុខរកយ៉ាងជោគជ័យ ហើយសមាសភាព១៧មេសានេះ គឺសមាសភាព១៧មេសាមកពីភ្នំពេញ។ ការពិនិត្យទៅលើសកម្មភាពរបស់គេ និងចម្លើយនៃខ្សែបណ្តាញរបស់គេ និងយោងទៅលើរូបថតដែលអង្គការយើងនេះ បានស្នើសុំធ្វើការស្រាវជ្រាវនេះ។" ERN ជាអង់គ្លេសនោះគឺ 00342709, ខ្មែរ 00275587 និងបារាំង 00623305។

[១៤:១៣:៥៧]

ចំណុចចុងក្រោយដែលខ្ញុំចង់ឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់នោះ គឺនិយាយពីសេចក្តីថ្លែងការណ៍របស់ថ្នាក់តំបន់។ គឺទី១ ទុកចិត្តផែនការរបស់បក្ស ដោយអនុវត្តផែនការគ្រប់ផ្នែកទាំងអស់ គឺផែនការឆ្នាំ១៩៧៧ របស់បក្ស។ ERN ដែលពាក់ព័ន្ធនោះគឺ 00342711 ជាអង់គ្លេស, ជាភាសាខ្មែរ 0027 5589 និងជាភាសាបារាំង 00623307។ ភាពពាក់ព័ន្ធនៃឯកសារនេះ គឺថា គឺវាពាក់ព័ន្ធទៅនឹងការវែកមុខរកខ្មាំងដែលរារាំងទៅដល់គម្រោងសាងសង់អាងស្តុកទឹក នៅក្នុងផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាទាំងស្រុងតែម្តង។

ឯកសារបន្ទាប់មកទៀត គឺឯកសារ E3/179។ នេះគឺជារបាយការណ៍មកពីមន្ទីរ៥៦០ ចុះថ្ងៃទី២៩ ឧសភា ១៩៧៧។ គឺឯកសារនេះចេញ៩ថ្ងៃ ក្រោយពីចេញរបាយការណ៍មុននេះ ហើយក៏វាបញ្ជាក់បន្ថែមទៅលើឯកសារដែលបង្ហាញមុននេះបន្តិចដែរ ពាក់ព័ន្ធទៅនឹងចំនួនកម្លាំងពលកម្មមកពីតំបន់៥។ សម្រាប់តំបន់៥ គឺមានព័ត៌មានរាយការណ៍ដូចខាងក្រោម សូមដកស្រង់៖ “អាងទឹកយុទ្ធសាស្ត្រនៅត្រពាំងថ្ម កំពង់សង់ទ្វារទឹកទាំងបី និងបញ្ចប់វានៅខែ៥ – នៅខែឧសភា។ ហើយព្រែកជីកប្រវែង២៣គីឡូម៉ែត្រ មាត់លើ១២ បាតក្រោម៦ម៉ែត្រ ជម្រៅ១ម៉ែត្រ បានបញ្ចប់ហើយនៅស៊ីសុផុន។” ហើយ ERN ជាអង់គ្លេស 00183016 ដល់ 17, ខ្មែរ 00008501, បារាំង 00236772។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍នៃឯកសារនេះ គឺថា៦ថ្ងៃក្រោយពីឯកសារមុនចេញមក គឺថាឯកសារនេះក៏បានចេញបន្ទាប់មកទៀតដោយរៀបរាប់ជាសង្ខេប។

[១៤:១៦:២៨]

ឯកសារពីរបន្ទាប់ទៀត ដែលខ្ញុំយកមកបង្ហាញជូនអង្គជំនុំជម្រះនោះ គឺមួយឆ្នាំក្រោយមកទៀត គឺនៅខែឧសភា ១៩៧៨ ហ្នឹងគិតពីខែឧសភា ៧៧ មក៧៨ គឺមានតេឡេក្រាមមួយមកពី រស់ ញឹម ជូនអង្គការ៨៧០។ ហើយឯកសារពាក់ព័ន្ធនោះគឺឯកសារ E3/950 ចុះថ្ងៃទី១១ ឧសភា ៧៨។ រស់ ញឹម បានចាប់ផ្តើមសរសេររាយការណ៍ជូនអង្គការ៨៧០ ដូចតទៅ សូមដកស្រង់៖ “ខ្ញុំសូមរាយការណ៍អំពីសភាពការណ៍ការងាររួមមានដូចតទៅ ទាំងនៅក្នុងភូមិភាគ ទី១) ក្រោយពីខ្ញុំបានជួបអង្គការ ត្រឡប់មកវិញ ហើយបានចុះទៅធ្វើការខាងតំបន់៥ តំបន់៣ តំបន់១ និងតំបន់៤។ នៅថ្ងៃទី១០ ខែឧសភានេះ ខ្ញុំជួបធ្វើការជាមួយសមមិត្តក្នុងគណៈអចិន្ត្រៃយ៍ប្រចាំការ ក្នុងការជួបការមួយគណៈអចិន្ត្រៃយ៍នោះគឺខ្ញុំរាយការណ៍ពីការណែនាំរបស់៨៧០ រួចហើយពិនិត្យសភាពការណ៍ក្នុងភូមិភាគរួមដូចតទៅ។”

ហើយផ្នែកខាងក្រោយនៃឯកសារនេះមានផ្នែកមួយដែលមានចំណងជើងថា "ផែនការកសាងគ្រប់ផ្នែកទាំងអស់"។ សូមដកស្រង់៖ "អាងស្តុកទឹកនៅក្នុងតំបន់៥ គឺមានអាងទឹកត្រពាំងថ្មត្រូវបាន -- ត្រពាំងថ្មគឺបានពង្រឹងថែមរួចហើយ។ ហើយពាក្យពង្រឹងថែមហ្នឹង គឺថាត្រូវបានបន្តរហូតទៅដល់រដូវប្រាំង១៩៧៨។ ហាក់ដូច្នេះ បញ្ជាក់ឲ្យឃើញថា ឯកសារនេះគឺស៊ីសង្វាក់គ្នាទៅនឹងឯកសារទស្សនាវដ្ដីទង់យុវជន-យុវនារី។ នៅក្នុងឯកសារនេះ រស់ ញឹម ក៏និយាយអំពីកិច្ចសហការរបស់គាត់ជាមួយ តារិន មកពីខាងភូមិភាគនិរតី។ ហើយក៏មាននិយាយអំពីស្ថានភាពចំណីអាហារ ដែលនិយាយថា សូមដកស្រង់៖ "គួរឲ្យសង្វេគណាស់ គឺថាចំនួនម្ហូបអាហារនៅក្នុងតំបន់ទាំងមូលមានការខ្វះខាត ប៉ុន្តែខ្ញុំជួបជាមួយសមមិត្ត រិន ហើយខ្ញុំបានស្នើគាត់ឲ្យពិនិត្យមើលការច្រូតស្រូវទាំងអស់ហ្នឹង ថាតើវាខ្វះខាតអីដែរ ហើយយើងត្រូវកំណត់របបអាហារ ថាតើរបបអាហារនេះត្រូវបានទទួលប៉ុនណា។" សូមបញ្ចប់ការដកស្រង់។

[១៤:១៩:២២]

ចុងបញ្ចប់នៃឯកសារនេះ រស់ ញឹម សរសេរថា ដកស្រង់៖ "សូមឲ្យអង្គការផ្ដល់មតិយោបល់ -- សូមឲ្យអង្គការសូមណែនាំបន្ថែម"។ ហើយអង់គ្លេស ERN នោះគឺ 00185215 ដល់ 18, ខ្មែរ 00021043 ដល់ 45 និងភាសាបារាំង 00296221 ដល់ 23។ ដូច្នេះភាពពាក់ព័ន្ធនៃឯកសារនេះ ខ្ញុំសូមបញ្ជាក់ថា ទី១ គឺវានិយាយអំពីការដ្ឋានទំនប់ត្រពាំងថ្ម ហើយក៏និយាយអំពីរចនាសម្ព័ន្ធថ្នាក់លើនៅភូមិភាគពាយ័ព្យនោះផងដែរ។

សារទូរលេខទី២របស់ រស់ ញឹម ផងដែរគឺឯកសារនេះគឺ E3/863 ចុះថ្ងៃទី១៧ ឧសភា ៧៨ ក៏ដូចជាឯកសារមុននេះដែរ គឺថាជារបាយការណ៍ចេញពី រស់ ញឹម ជូនទៅអង្គការ។ គាត់ក៏និយាយអំពីកិច្ចសហការរបស់គាត់ជាមួយ តារិន ទៅលើបញ្ហាចំណីអាហារ ជាពិសេស សុំដកស្រង់៖ "តំបន់៥នៅតែមានបញ្ហាដែរ ជាមួយនឹងពូជស្រូវសម្រាប់ដើមរដូវនេះ។ ខ្ញុំធ្វើការជាមួយសមមិត្ត រិន នេះទៅលើបញ្ហានេះ ហើយស្នើសុំគាត់មកបញ្ជូនមកខ្ញុំនូវស្រូវពូជចំនួន ១៤.000បាវ។" ERN ជាភាសាអង់គ្លេស 00321961, បារាំង 00623408 និងខ្មែរ 00076286។ ចំណុចសំខាន់នៃឯកសារនេះ និយាយថា ក៏មាននិយាយអំពីរចនាសម្ព័ន្ធថ្នាក់លើនៅក្នុងភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៨។

[១៤:២១:៤៤]

ឯកសារពីរបន្ទាប់ដែលខ្ញុំចង់យកមកបង្ហាញនោះ គឺឯកសារនោះពាក់ព័ន្ធទៅនឹងអ្វីដែលបាន

លើកឡើងជាច្រើនដងរួចមកហើយ និយាយអំពីដំណើរទស្សនកិច្ចរបស់ ឆឹង យឹងគួយ មកកាន់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៧។ ឯកសារទី១គឺ E3/1783។ ឯកសារនេះគឺជាឯកសារសារព័ត៌មានរបស់ចិនឈ្មោះ ស៊ីនហ័រ គឺនៅក្នុងដើមខែធ្នូ ១៩៧៧ ហើយក៏បានបញ្ជាក់ថា ឆឹង យឹងគួយ ត្រូវបានអមដំណើរដោយ ប៉ុល ពត។ ហើយឯកសារនេះក៏បញ្ជាក់ផងដែរថា រស់ ញឹម បានជួបជាមួយនឹង ប៉ុល ពត និង ឆឹង យឹងគួយ ហើយក៏បានធ្វើបទបង្ហាញខ្លីអំពីការកសាងអាងស្តុកទឹក រួមទាំងបញ្ជាក់ឲ្យឃើញថា គឺការកសាងនេះ គឺធ្វើឡើងដោយឆ្លើយតបទៅនឹងការអំពាវនាវរបស់គណៈកម្មាធិការមជ្ឈិម។ ជាពិសេសឯកសារនិយាយថា សុំដកស្រង់៖ “សមមិត្ត រស់ ញឹម អនុប្រធានទី២នៃប្រធានគណៈរដ្ឋកម្ពុជាប្រជាធិបតេយ្យ និងជាលេខាគណៈភូមិភាគពាយ័ព្យនៃបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្នុងភូមិភាគពាយ័ព្យ បានមានប្រសាសន៍ថា អាងស្តុកទឹកត្រូវកសាងក្នុងឆ្នាំនេះដោយប្រជាជនក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ ហើយប្រើរយៈពេលតិចជាង២ខែដែលជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់គណៈកម្មាធិការមជ្ឈិមបក្ស ដើម្បីកសាងអាងស្តុកទឹកដ៏ធំមួយនេះ។ ឆ្នាំនេះ អាងស្តុកទឹកនេះអាចស្តុកទឹកបាន១៥០លានម៉ែត្រគូប។ ក្រោយមកប្រឡាយចំនួនបីត្រូវបានជីកក្នុងរយៈពេលមួយសប្តាហ៍ ដើម្បីភ្ជាប់អាងស្តុកទឹកដែលអាចស្រោចស្រពស្រែបានជាង៧.០០០ហិកតា។ ពេលនេះ អាងស្តុកកំពុងត្រូវបានពង្រីកបន្ថែមទៀត។ ៤ឆ្នាំក្រោយ អាងនេះអាចស្តុកទឹកបានចំនួន៣០០លានម៉ែត្រគូប។” រស់ ញឹម ក៏បាននិយាយផងដែរ សុំដកស្រង់៖ “គ្រោះរាំងស្ងួតបានកើតឡើងនៅពេលយើងចាប់ផ្តើមសាងសង់អាងស្តុកទឹក ហើយប្រជាជនចំនួន ២០.០០០នាក់បានចូលរួមសាងសង់ ហើយអត់មានទឹកហូបគ្រប់គ្រាន់ទេ។” បញ្ចប់ការដកស្រង់។ ហើយ ERN ដែលពាក់ព័ន្ធនោះគឺជាភាសាអង់គ្លេស 00498180 ដល់ 81, ខ្មែរ 00659259 ដល់ 60 និងជាភាសាបារាំង 00606766។ ឯកសារនេះ គឺថាវាពាក់ព័ន្ធគ្នាទៅនឹងការផែនការពង្រីក តភ្ជាប់អាងស្តុកទឹកនេះក្នុងឆ្នាំ១៩៧៧ ហើយវាក៏ពាក់ព័ន្ធទៅនឹងការដឹងអំពីស្ថានភាពការងាររបស់ថ្នាក់លើផងដែរ។ ហើយចុងបញ្ចប់ គឺថាដឹងពីទំហំការងារទាំងមូលដែលថាមានប្រជាជនធ្វើការងារ២០.០០០នាក់នោះ។

[១៤:២៥:០៨]

ឯកសារបន្ទាប់នោះគឺឯកសារ E3/1339 ជាសេចក្តីរាយការណ៍មួយ។ ERN ពាក់ព័ន្ធនោះគឺ 00168341 ហើយក្នុងពេលនេះមិនទាន់មាន ERN ជាភាសាខ្មែរទេ ជាភាសាបារាំងនៅឡើយទេ មិនទាន់បានបកប្រែទេ។ នេះពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដដែល ដែលរៀបរាប់ថាតើ ឆឹង យឹងគួយ បានធ្វើ

ដំណើរពីសៀមរាប ទៅកាន់ភូមិភាគពាយ័ព្យដោយមានការអមដំណើរដោយ ប៉ុល ពត និង វន វេត។ ក៏និយាយផងដែរថា រស់ ញឹម ក៏ពាក់ព័ន្ធនៅក្នុងព្រឹត្តិការណ៍នេះផងដែរ។ សូមដកស្រង់៖ “នៅព្រំប្រទល់រវាងតំបន់ភាគខាងជើង និងភាគខាងលិច សមមិត្ត នឹង យើងគួយ ហើយនិងសមមិត្តចិនដទៃទៀត គឺត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅដោយសមមិត្ត រស់ ញឹម លេខាភូមិភាគពាយ័ព្យនៃបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជន។” បញ្ចប់ការដកស្រង់។ ហើយបន្ទាប់មកក៏និយាយថា -- ក៏បន្តនិយាយអំពីអាងស្តុកទឹកត្រពាំងថ្មនេះបន្ថែមទៀតនៅពេលរសៀល។

ឯកសារបន្ទាប់ដែលខ្ញុំចង់បង្ហាញ គឺថាពាក់ព័ន្ធដំណើរទស្សនកិច្ចរបស់ជនបរទេស គឺអ្នកកាសែតយូហ្គោស្លាវី។ ឯកសារនេះគឺឯកសារ E3/4604 គឺជាទស្សនាវដ្តីទង់បដិវត្ត ខែមេសា ១៩៧៨ ដែលនិយាយអំពីបទបង្ហាញរបស់សមមិត្តលេខាភូមិភាគនៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឱកាសខួបលើក -- មហាជ័យជម្នះលើកទី ខួបលើកទី៣នៃមហាជ័យជម្នះ១៧ មេសា។ បាទ នេះគឺជាបទបង្ហាញរបស់គាត់។ ផ្នែកដែលពាក់ព័ន្ធដែលខ្ញុំលើកឡើងនោះ គឺវានិយាយពីអាងស្តុកទឹកនៅទំនប់ត្រពាំងថ្ម ត្រង់ផ្នែកមួយហៅថា “បន្ទាប់មកខ្ញុំចង់ជម្រាបជូនសមមិត្ត អំពីផ្នែកទី២នេះ ដែលនិយាយអំពីការកសាងប្រទេស” បញ្ចប់ការដកស្រង់។ ហើយផ្នែកនេះ គឺវាបាននិយាយដូចតទៅ សូមដកស្រង់៖ “ចលនាដោះស្រាយទឹកនេះ ធំធេងណាស់ ខ្លាំងក្លាណាស់ សម្បើមមហិមាណាស់។ ខ្ញុំសូមរាយការណ៍ជូនបក្ស ជំនួសមុខរដ្ឋាភិបាល ដែលយើងបាន អាចស្តុកទឹករហូតទៅដល់១០០លានម៉ែត្រគូបឡើងទៅ។ យើងធ្វើអ្វីបានច្រើនដូចសមុទ្រ។ ហៅពួកក្រុមកាសែតយូហ្គោស្លាវី មកមើលអាងទឹកយើងនៅខេត្តបាត់ដំបង ហើយត្រពាំងថ្មនៅភ្នំស្រុក មើលទៅវាមិនឃើញត្រើយ គាត់ថាគាត់ទើបមកពីកំពង់សោម ឃើញសមុទ្រនៅកំពង់សោម ដល់មកមើលអាងទឹកនៅភ្នំស្រុក ខាងបាត់ដំបង គាត់ថាមានសមុទ្រមួយទៀតនៅកន្លែងនេះ។ ការចាប់អារម្មណ៍សមុទ្រមួយទៀត បានសេចក្តីថា អាងទឹកហ្នឹងវាធំ ធំល្វឹងល្វើយមើលដាច់កន្ទុយភ្នែក សុទ្ធតែទឹក គឺជិត២០០លានម៉ែត្រគូប យើងធ្វើតែមួយឆ្នាំ។” ដូច្នេះគឺថាគេបានបង្ហាញអំពីពេលវេលាសាងសង់តែមួយឆ្នាំ ក៏ដូចជាទំហំនៃគម្រោងនេះ ហើយអំពីការដឹងរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងការកសាងនេះ។

[១៤:២៨:៥៨]

ហើយឯកសារបន្ត ជាភាសាអង់គ្លេសគឺមានលេខ 00519843, ជាភាសាខ្មែរគឺមានលេខ 00064727 ហើយបារាំងគឺមានលេខ 00519843 គឺដូចគ្នា។ ខ្ញុំចង់លើកអំពីកំណត់ហេតុស្តាប់ចម្លើយ

សាក្សី ហើយទាំងអស់នេះគឺពាក់ព័ន្ធទៅនឹងស្ថានភាពនៅពេលចុងក្រោយនៅពេលដែលកម្មាភិបាលភូមិភាគបូព៌ាបានមកដល់។ ហើយដំបូង ខ្ញុំសូមលើកយកអំពីឯកសារ E319/19.3.33 គឺគេបានសាកសួរសាក្សីអំពីការទទួលខុសត្រូវនៅត្រពាំងថ្ម ហើយចម្លើយរបស់គាត់គឺថា៖ “ខ្ញុំរែកដី ហើយនិងកសាងទំនប់ ហើយខ្ញុំទទួលខុសត្រូវនៅថ្មពក ហើយ សាន គឺជាអនុប្រធានក្រុម។ ឡុង (ស្លាប់ហើយ) គឺជាអនុប្រធាន គាត់មកពីភូមិភាគពាយ័ព្យ”។ ហើយចុះក្រោមបន្តិចនៅក្នុងសំណួរចម្លើយដដែលហ្នឹង គឺថា៖ “យន់ មកពីភូមិភាគនិរតី ទទួលខុសត្រូវលើកងទាំងអស់នៅត្រពាំងថ្ម។” សូមបញ្ចប់ការដកស្រង់។

សំណួរបន្តដែលគេសួរសាក្សីហ្នឹង គឺសំណួរចម្លើយទី១០ គេបានសួរដូចតទៅនេះ៖ “តើលោកចង់បន្ថែមអ្វីទៀតទេ? ហើយគាត់បានឆ្លើយថា៖ ខ្ញុំចង់បន្ថែមថា ការរស់នៅក្រោមសិទ្ធិអំណាចរបស់ពួកខាងនិរតី គឺវេទនាណាស់ ព្រោះយើងមិនបានទទួលអាហារគ្រប់គ្រាន់ ទោះបីថាយើងធ្វើការហត់នឿយខ្លាំងក៏ដោយ ហើយពេលខ្លះយើងត្រូវធ្វើការទាំងយប់ទាំងថ្ងៃ។” សូមបញ្ចប់ការដកស្រង់។ ហើយភាពពាក់ព័ន្ធនៃឯកសារនេះ គឺបង្ហាញអំពីស្ថានភាពរស់នៅនៅក្រោមខាងនិរតី។

[១៤:៣១:៣៥]

ឯកសារបន្តនៅក្នុងចំណុចនេះគឺ E319/21.3.5 ហើយអ្វីដែលខ្ញុំចង់ដកស្រង់ទីនេះ គឺសំណួរចម្លើយ២៧ និងសំណួរចម្លើយ២៨។ “សំណួរ៖ លោកនិយាយថា លោកធ្វើការនៅក្នុងកងចល័តនៅអង្គត្រពាំងថ្ម ហើយនៅស្ពាន ហើយនិងនៅការដ្ឋានស្ពានស្រែង។ តើលោកអាចប្រាប់បានទេ ថាតើស្ថានភាពរស់នៅ និងស្ថានភាពការងារមានលក្ខណៈយ៉ាងម៉េចដែរ? តើក្រោយកម្មាភិបាលនិរតីមកដល់ស្ថានភាពនោះមានលក្ខណៈដូចម្តេចដែរ? ឆ្លើយ២៧៖ មុនកម្មាភិបាលនិរតីមកដល់ ស្ថានភាពការងារគឺគេឲ្យយើងជីកដីពី២ ឬ៣ម៉ែត្រគូបក្នុងមួយថ្ងៃ។ នៅពេលដែលកម្មាភិបាលនិរតីមកដល់ គឺគេឲ្យយើងរែកដី៣ម៉ែត្រគូបក្នុងមួយថ្ងៃ។ ចំពោះរបបអាហារ គឺអ្នកធ្វើការនៅតាមកងចល័ត មានលក្ខណៈមិនមានអ្វីហូបគ្រប់គ្រាន់ដូចតែគ្នា។ នៅមុននិងពេលក្រោយពួកកម្មាភិបាលនិរតីមកដល់ គឺគេឲ្យយើងរែកដីនៅពេលយប់។ សំណួរ៖ តើការចាប់ខ្លួនមនុស្ស និងសម្លាប់មនុស្សមានស្ថានភាពដូចគ្នាដែរឬទេ នៅមុននិងក្រោយពួកកម្មាភិបាលនិរតីមកដល់? ឆ្លើយ៖ តាមពិតទៅមុនពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មិនខ្លាំងប៉ុន្មានទេ ប៉ុន្តែក្រោយពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មនុស្សរឹតតែខ្លាំងឡើង។” សូមបញ្ចប់ការដកស្រង់។

[១៤:៣៣:០៦]

ឯកសារបន្តនៅក្នុងចំណុចដដែលនេះគឺ E319/19.3.47 ហើយនេះគឺជាសំណួរចម្លើយទី១៨។ សាក្សីត្រូវបានគេសួរថា៖ "តើអ្នកណាជាអ្នកគ្រប់គ្រងកងចល័តតំបន់៥ ហើយនៅពេលដែលគាត់ធ្វើការនៅទំនប់ត្រពាំងថ្ម? គាត់ឆ្លើយថា៖ តាវ៉ាល់ គ្រប់គ្រងកងចល័តតំបន់៥ ដែលធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។" បន្ទាប់មកគេសួរអំពីតួនាទីរបស់គាត់នៅការដ្ឋានទំនប់ត្រពាំងថ្ម គាត់បានឆ្លើយថា៖ "ខ្ញុំគ្រប់គ្រងកងតូច ដែលមានមនុស្ស៣០នាក់។ ខ្ញុំធ្វើការនៅទំនប់ត្រពាំងថ្មបាន៣ខែ ហើយពេលហ្នឹងទំនប់ត្រពាំងថ្ម គឺគេបានធ្វើរួចរាល់ គឺមុនចូលឆ្នាំខ្មែរ ក្នុងឆ្នាំ៧៧។ ប្រហែលជាខែឧសភា ឆ្នាំ៧៧ ពួកនិរតីបានចូលមកដល់ ហើយគេបានរំសាយកងចល័ត និងចាប់ផ្ដើមចាប់កម្មាភិបាលដឹកនាំពួកពាយ័ព្យ ដូចជាមេចល័ត និងមេវរៈទាំងអស់។ ខ្ញុំត្រូវបានគេដកឱ្យទៅធ្វើការនៅទំនប់គបឹដើម។ តាមពិតទំនប់ត្រពាំងថ្មធ្វើរួច ធ្វើហើយចប់សព្វគ្រប់ ប៉ុន្តែលើកលែងតែស្ពានមួយចំនួន នៅមិនទាន់ធ្វើចប់ពេញលេញនៅឡើយ។ ហើយក្នុងសំណួរទី១៣ គេបានសួរថា៖ តើលោកអាចរៀបរាប់អំពីស្ថានភាពការងារ និងស្ថានភាពរស់នៅនៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ និងពួកនិរតីដែរឬទេ? ហើយគាត់ឆ្លើយថា៖ ស្ថានភាពរស់នៅនិងស្ថានភាពការងារស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ គឺមានការងាយស្រួលជាងការគ្រប់គ្រងរបស់ពួកនិរតី ពីព្រោះយើងមានអាហារហូបគ្រប់គ្រាន់។ ប៉ុន្តែនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី គឺមានការលំបាកយ៉ាងខ្លាំង ហើយហូបមិនគ្រប់គ្រាន់"។

[១៤:៣៥:១១]

ឯកសារបន្តទៀត គឺកំណត់ហេតុស្តាប់ចម្លើយសាក្សី គឺឯកសារ E319/19.3.24 ហើយនេះគឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលធ្វើការនៅទំនប់ត្រពាំងថ្ម ហើយនៅពេលនេះគាត់និយាយថា៖ "អ៊ឹម ចែម បានមកដល់ទីនោះនៅក្នុងខែកក្កដា ឬក៏សីហា ឆ្នាំ៧៧។ ហើយគេបានសួរសំណួរដូចគ្នា គឺថា៖ តើលោកមានអ្វីបន្ថែមទេ? ហើយគាត់និយាយថា៖ "ខ្ញុំចង់បន្ថែមថា នៅក្រោមរបបខ្មែរក្រហមទាំងការគ្រប់គ្រងរបស់ពួកពាយ័ព្យ និងពួកនិរតី ស្ថានភាពរស់នៅមានការលំបាកបំផុត ហើយយើងមិនមានអាហារសម្រាប់បរិភោគទេ។"

ហើយឯកសារបន្តដែលខ្ញុំចង់បង្ហាញនៅក្នុងបញ្ជីនេះផងដែរគឺ E319/21.3.3។ នេះគឺនៅត្រង់ចម្លើយ១០៣ សាក្សីត្រូវបានគេសួរ៖ "លោកបាននិយាយពីមុនថា តាវ៉ាល់ គឺជាមេដឹកនាំជាន់ខ្ពស់បំផុតនៅតំនប់ត្រពាំងថ្ម។ បន្ទាប់ពីគាត់ត្រូវបានគេចាប់ខ្លួន ថាតើអ្នកណាមកជំនួសគាត់? ហើយគាត់ឆ្លើយថា៖ តាពាល់ មកពីខាងនិរតីមកជំនួសគាត់។ ហើយសំណួរ១០៥ គេសួរសាក្សីអំពី តាពាល់៖ ថាតើ

តាពាល់ មកពីភូមិភាគនិរតី ឬក៏អត់? ហើយគាត់ឆ្លើយថា៖ បាទ គាត់សាហាវណាស់ គាត់មានភ្នែកស្រលៀង។" ហើយក្រោយមកនៅក្នុងការសម្ភាស គេសួរអំពីការរំលោភដែលគាត់បាននិយាយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ ហើយគាត់និយាយថា៖ "ស្ត្រីពីរនាក់ ហើយបន្ទាប់មកគាត់ផ្ដល់ឈ្មោះ មកពីស្រុកព្រះនេត្រព្រះ គឺជាពេទ្យនៅក្នុងកងចល័តរបស់ខ្ញុំ។ ពួកគាត់ត្រូវបានតាពាល់ ដែលមកពីនិរតី និងគ្នាម្នាក់ទៀត យកទៅសម្លាប់។ ខ្ញុំមិនបានឃើញការសម្លាប់នោះដោយផ្ទាល់ភ្នែកទេ តែអ្នកនៅកងជាមួយខ្ញុំ បានប្រាប់ខ្ញុំថា សាកសពស្ត្រីទាំងពីរនាក់នោះ ស្លាប់ទាំងរាងកាយនន្ទលគក រាងកាយអាក្រាត។ ហើយគាត់និយាយថា ដោយសាររាងកាយអាក្រាត យើងយល់ថា អ្នកទាំងពីរនោះ ត្រូវបានគេរំលោភមុនគេសម្លាប់។"

[១៤:៣៧:៤៤]

ហើយសាក្សីដដែលនៅត្រង់ចម្លើយ៩២ ដល់ចម្លើយ៩៤ គាត់បានឆ្លើយអំពីការរស់នៅ បន្ទាប់ពីពួកនិរតីបានមកដល់ ហើយគាត់និយាយថា ស្ថានភាពរស់នៅគឺពិបាក។ នៅពេលសួរអំពីម្ហូបអាហារគាត់និយាយថា៖ "គេឲ្យអង្ករមួយកំប៉ុងទឹកគោ ៣០នាក់ ហើយគេឲ្យយើងធ្វើការទាំងយប់ទាំងថ្ងៃ។ ហើយសំណួរទី៩៤ គេសួរថា៖ "ក្រោយពេលដែលពួកនិរតីមកកាន់កាប់ ការបាត់ខ្លួន និងការចាប់ខ្លួនមានលក្ខណៈយ៉ាងណាដែរ? ហើយគាត់ឆ្លើយថា៖ បាទ គឺមានការបាត់ខ្លួន និងចាប់ខ្លួនកាន់តែច្រើន។"

លោកប្រធាន ឥឡូវខ្ញុំត្រូវបន្តទៅដល់ប្រធានបទថ្មី ប៉ុន្តែខ្ញុំឃើញថា វាហាក់ដូចជាដល់ពេលសម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ផ្នែកបន្តដែលខ្ញុំចង់ពិភាក្សាគឺ ជាព័ត៌មានទូទៅអំពីផ្នែកដែលពាក់ព័ន្ធគឺតំបន់៥ នៃភូមិភាគឧត្តរ។ ហើយចំណុចដំបូងគឺ E3/1181 គឺនិយាយអំពីភូមិភាគពាយ័ព្យ គឺចុះខែកក្កដា ឆ្នាំ៧៧ ហើយឯកសារនេះគឺមានពីរផ្នែក។ ផ្នែកទី១ នៃឯកសារនេះ គឺជារចនាសម្ព័ន្ធនៃតំបន់៥ ហើយនិងស្រុកនីមួយៗនៅក្នុងតំបន់៥។ ហើយផ្នែកទី២ គឺជាការសង្ខេបប្រជាជននៅក្នុងស្រុកនីមួយៗ។ ផ្នែកនៃរចនាសម្ព័ន្ធនោះ គឺមាននូវឈ្មោះមួយចំនួនដែលយើងធ្លាប់ឮនៅក្នុងសក្ខីកម្ម គឺឈ្មោះ ហ៊ឹង្ស ជាលេខាតំបន់៥ ហើយតារាងរចនាសម្ព័ន្ធបានបង្ហាញថា គាត់ត្រូវបានគេចាប់ខ្លួន ហើយនិងឈ្មោះ ជាល ដែលជាលេខាគណៈតំបន់១៥ ហើយមានឈ្មោះ ម៉ោង និង សំអាត គណៈស្រុកព្រះនេត្រព្រះ និង ហាត់ គណៈស្រុកភ្នំស្រុក។ ហើយទាំងអស់នេះគឺមាននៅទំព័រ 00223175 ជាភាសាអង់គ្លេស, 00612290 ជាភាសាបារាំង និង 00214488 ជាភាសាខ្មែរ។

ផ្នែកទី២នៃឯកសារនេះ គឺមានចំណងជើងថា "ទិដ្ឋភាពទូទៅនៃស្រុកនីមួយៗ"។ ហើយខ្ញុំចង់ឲ្យជំនុំជម្រះចាប់អារម្មណ៍ទៅលើផ្នែកមួយពាក់ព័ន្ធនឹងស្រុកភ្នំស្រុក ហើយនិងផ្នែកមួយទៀតពាក់ព័ន្ធនឹងស្រុកព្រះនេត្រព្រះ។ ផ្នែកដែលពាក់ព័ន្ធនឹងស្រុកព្រះនេត្រព្រះបាននិយាយដូចតទៅនេះ៖ "មានប្រជាជនជាង៧០.០០០នាក់។ ប្រជាជនចាស់មានប្រហែល៣០០គ្រួសារ ទៅពីភ្នំពេញប្រហែល៥០.០០០ប្លាយ។ ប្រជាជនថ្មីក្នុងស្រុកមានជាង ២០.០០០។" សុំបញ្ចប់ការដកស្រង់។ ហើយចំពោះស្រុកព្រះនេត្រព្រះឯកសារបានបញ្ជាក់ដូចតទៅនេះ ខ្ញុំសុំដកស្រង់៖ "ប្រជាជនមុន១៧មេសាមាន១៥០គ្រួសារ។ ចេញទៅពីភ្នំពេញជាង ៧០.០០០នាក់។ នៅព្រះនេត្រព្រះក្រោយ១៧ ជាង៣០.០០០នាក់។ សង្កាត់ព្រះនេត្រព្រះនិងប្រាសាទមានសភាពគួរសម។" សុំបញ្ចប់ការដកស្រង់។ ហើយផ្នែកនេះគឺនៅត្រង់ទំព័រ 00223176 ជាភាសាអង់គ្លេស, 00214490 ជាភាសាខ្មែរ និង 00612291 ជាភាសាបារាំង។

[១៥:០៥:០៦]

ឯកសារទី២ ដែលមាននៅក្នុងផ្នែកទិដ្ឋភាពទូទៅនេះដែរគឺឯកសារE3/9284 ដែលបានរៀបរាប់

អំពីស្រុកទាំងអស់នៅក្នុងតំបន់៥ ហើយក៏រៀបរាប់អំពីឃុំដែលស្ថិតនៅក្នុងស្រុកនីមួយៗដែលអាចជួយដល់លោក លោកស្រីចៅក្រម ក្នុងការយល់ទៅលើសក្ខីកម្មរបស់សាក្សីមួយចំនួន។ ទំព័របន្តនៃឯកសារនេះ គឺមាននូវពាក្យដូចតទៅនេះ៖ “ក្នុងឯកសារ អាហ៊ីង្ស ក៏បាននិយាយអំពីរចនាសម្ព័ន្ធរបស់បណ្ដាញសេ.អ៊ី.អា នៅក្នុងភូមិ ឃុំ ស្រុក តំបន់៥ផងដែរ។” ដូច្នេះខ្ញុំគិតថាយើងមិនចាំបាច់ត្រូវអានឯកសារនេះអំពីលេខ -- មិនត្រូវអានលេខERNឡើយ ព្រោះយើងមើលឯកសារនេះជារួម។

ផ្នែកបន្តដែលខ្ញុំចង់ពិភាក្សាផងដែរ គឺឯកសារមកពីមន្ទីរស-២១ ពាក់ព័ន្ធទៅនឹងបុគ្គលមួយចំនួនដែលយើងបានស្ដាប់ឮនៅក្នុងផ្នែកនៃការសវនាការនេះ។ ឯកសារទី១ ដែលខ្ញុំចង់លើកយកមកបង្ហាញគឺ E3/1900 គឺជាបញ្ជីអ្នកទោសត្រូវបានកម្ទេចនៅថ្ងៃ០៦ មីនា ឆ្នាំ៧៨។ ហើយនៅក្នុងលេខ១២ គឺមានបុគ្គលម្នាក់ឈ្មោះ អោក ហ៊ន ដែលមានឈ្មោះហៅក្រៅថា វ៉ាល់ ដែលត្រូវបានគេសរសេរថាជាលេខាតំបន់៥ ហើយកាលបរិច្ឆេទចូល ស-២១ គឺនៅថ្ងៃទី២៩ មិថុនា ឆ្នាំ៧៧។ ERN ឯកសារនោះគឺជាភាសាអង់គ្លេស មានលេខ 00193556 និងបារាំងគឺមានលេខ 00909168។ ឯកសារដើមជាភាសាខ្មែរទើបតែបានដាក់ចូលក្នុងសំណុំរឿងកាលពី២សប្ដាហ៍មុន ហើយយើងដឹង -- ទើបតែដឹងថាឯកសារនេះ មិនទាន់បានដាក់ចូលទៅក្នុងសំណុំរឿងនៅឡើយ។ ដូច្នេះនៅពេលនេះគឺឯកសារនេះ ស្ថិតនៅក្នុងលេខ E357.1 ហើយ ERN ពាក់ព័ន្ធគឺលេខ 01128615។

[១៥:០៧:៤៤]

ឯកសារ ស-២១ ទី២ គឺ ឯកសារដែលមានលេខ E3/3972 គឺមានចំណងជើងថា “បញ្ជីប្រចាំខែរបស់អ្នកទោសមកពីភូមិភាគពាយ័ព្យ និងភូមិភាគបស្ចិម នៅខែកញ្ញា ឆ្នាំ៧៧”។ នៅក្នុងលេខ៤២ នៅក្នុងបញ្ជីនោះគឺឈ្មោះ ម៉ែន ជុន ហៅ ហ៊ីង្ស ដែលត្រូវបានគេរាយរាប់ថាជាលេខាតំបន់១៥។ ហើយភាសាអង់គ្លេស គឺនៅត្រង់ទំព័រដែលមានលេខ 00837611, ភាសាខ្មែរមានលេខ 00086932 និងភាសាបារាំងមានលេខ 00864731។

ឯកសារបន្ទាប់គឺ E3/2285 គឺជាបញ្ជីជាច្រើនអំពីអ្នកទោសដែលត្រូវបានកម្ទេច ប៉ុន្តែមានចំណងជើងថា “បញ្ជីអ្នកទោសដែលបានសម្លាប់នៅថ្ងៃ១៨ តុលា ៧៧” គឺនៅត្រង់ទំព័រមានលេខ 0000 -- 00873645 និងខ្មែរមានលេខ 00009307 ជាភាសាខ្មែរ។ នៅលេខ១៣៤ នៅក្នុងបញ្ជីនេះ គឺឈ្មោះ អន ម៉ោង មកពីភូមិភាគពាយ័ព្យ ដែលគេរាយរាប់ថាជាអនុលេខាស្រុកព្រះនេត្រព្រះ។

ឯកសារបន្តទៀតគឺ E3/2254 គឺជាបញ្ជីអ្នកទោស ស-២១ មួយទៀត។ ហើយនៅក្នុងនេះគឺ

នៅតំបន់ភូមិភាគពាយ័ព្យបានរៀបរាប់អំពីឈ្មោះ ហេង រិន ហៅ ម៉ី ដែលគេចាត់ទុកថាជាលេខាតំបន់៥ ហើយបញ្ជាក់ថាគាត់ត្រូវបានគេចាប់ខ្លួននៅថ្ងៃ១៦ វិច្ឆិកា ឆ្នាំ៧៨។ ហើយឯកសារនេះ ក៏បានបញ្ជាក់ថា ប្រពន្ធរបស់គាត់ត្រូវបានគេចាប់ខ្លួនភ្លាមៗនៅពេលក្រោយបន្តិច ព្រមទាំងកូនរបស់ -- ក្មួយរបស់គាត់ត្រូវបានគេចាប់នៅខែធ្នូ ឆ្នាំ ៧៨។ ឯកសារនេះជាភាសាអង់គ្លេសមានលេខ 00789707, ខ្មែរមានលេខ 00086766 និងបារាំងមានលេខ 00834853។

[១៥:១០:២៧]

ឯកសារបន្តដែលខ្ញុំចង់លើកយកមកបង្ហាញផងដែរ គឺជាបញ្ជីអ្នកទោស ស-២១ ដែលបានកែសម្រួលដោយ ក.ស.ព គឺឯកសារមានលេខ E3/342។ ហើយខ្ញុំចង់បញ្ជាក់ថា មានចំនួនកម្មាភិបាលមួយចំនួនត្រូវបានគេលើកយកមកពិភាក្សានៅក្នុងឯកសារនេះ គឺមាន ឧទាហរណ៍ដូចជានៅលេខ ៥១០០ គឺឈ្មោះ ម៉ែន ជុន ហៅ ហ៊ីង្ស ដែលគេរៀបរាប់ថាជាលេខាតំបន់១៥។ លេខ ២៤៣១ គឺឈ្មោះ ហេង រិន ហៅ ម៉ី ក៏ត្រូវបានគេសរសេរថាជាលេខាតំបន់៥ គាត់គឺជាអ្នកបន្តតំណែង តាហ៊ីង្ស។ ហើយលេខ៨១គឺ អោក ហ៊ន ហៅ វ៉ាល់ គឺជាប្រធានកងចល័តតំបន់៥។ លេខ ៦១៤៦ ឈ្មោះ ង៉ាន យ៉ែម ហៅ ហាត់ ដែលជាលេខាស្រុកភ្នំស្រុកនៅតំបន់៥ នៃភូមិភាគពាយ័ព្យ។ ហើយលេខ៥៧គឺ អន ម៉ោង ដែលត្រូវបានគេរៀបរាប់ថាជាលេខាស្រុកព្រះនេត្រព្រះក្នុងតំបន់៥។

ឯកសារបន្តទៀតដែលខ្ញុំចង់បញ្ជាក់ គឺជាឯកសារចម្លើយសារភាព ស-២១។ ហើយខ្ញុំដឹងថា យើងកំពុងតែពិភាក្សា និងសម្រេចថាតើយើងប្រើប្រាស់ឯកសារនេះដោយរបៀបណា។ ដូច្នេះខ្ញុំគ្រាន់តែលើកយកនូវលេខដើម្បីជាឯកសារ ដើម្បីជាការសម្រួលដល់អង្គជំនុំជម្រះតែប៉ុណ្ណោះ គឺចម្លើយសារភាពរបស់ ម៉ែន ជុន – របស់ តាហ៊ីង្ស E3/2474, តារិន គឺ -- D159/5.61 និង តាម៉ោង គឺ E3/7395។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងឯកសារមួយដែលបានលើកឡើងអម្បាញ់មិញនេះ គឺឯកសារ D159/5.61 ដែលមិនមែនជាឯកសារដាក់បញ្ចូលទៅសំណុំរឿងនោះទេ។ អ៊ីចឹងសុំឲ្យ -- យើងជំទាស់មិនឲ្យប្រើឯកសារនេះទេ លោកប្រធាន គឺឯកសារ D159/5.61។

[១៥:១៣:២៣]

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន និយាយដោយត្រង់ទៅ ខ្ញុំផ្តល់ឯកសារនេះគ្រាន់តែដើម្បីជួយសម្រួលដល់អង្គជំនុំជម្រះតែប៉ុណ្ណោះ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំអាចដកចេញនូវឯកសារនេះមកវិញបាន។

ឯកសារពីរបន្តទៀតដែលខ្ញុំចង់ទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះផងដែរ គឺឯកសារដែលយើងប្រើប្រាស់នៅក្នុងពេលសួរដេញដោលសាក្សី។ ហើយខ្ញុំចង់បង្ហាញអំពីខ្លឹមសារនៃឯកសារដែលដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។ ឯកសារទី១គឺ E3/8991 គឺនៅត្រង់ភាសាអង់គ្លេសមានលេខ 00969903, ខ្មែរមានលេខ 00730232 ហើយមិនទាន់មានឯកសារបកប្រែជាភាសាបារាំងនោះឡើយ។ ហើយខ្ញុំសូមរំឭកថា -- "សំណួរ៖ ចុះអំពី តាម៉ោង និង តាវ៉ាល់ តើគេធ្លាប់ធ្វើបាបលោកអត់? ឆ្លើយ៖ ខ្ញុំកម្រជួបពួកគេណាស់ ព្រោះខ្ញុំនៅកម្រិតកងវរៈ គឺទាបជាងពួកគាត់ ប៉ុន្តែ ពួកគាត់ទាំងពីរនាក់នេះគឺ កាចៗណាស់ កាចជាង យាយថែម ឆ្ងាយណាស់។ ពួអ្នកមកពីនោះនិយាយ គេហៅតែ តាចង្កូមមាស។"

ហើយសាក្សីដែលនិយាយបែបនេះ ក្រោយមកត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតសួរ ហើយឱ្យគាត់ពន្យល់។ ហើយគាត់ពន្យល់នៅក្នុងឯកសារ E319/19.3.46 ហើយផ្នែកដែលពាក់ព័ន្ធគឺសំណួរចម្លើយ៤២ និង៤៣។ សំណួរ៤២ សូមដកស្រង់៖ "នៅទំព័រ១៦ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា តាម៉ោង ហើយនិង តាវ៉ាល់ កាចជាង យាយថែម ខ្លាំងណាស់។ តើលោកអាចប្រាប់បានទេ ថាតើ តាម៉ោង ជាអ្នកណា? ឆ្លើយ៤២៖ តាម៉ោង គឺជាគណៈស្រុកព្រះនេត្រព្រះ។ នៅពេលដែល យាយថែម មកស្រុកព្រះនេត្រព្រះ គាត់ជំនួសកន្លែង តាម៉ោង។ ហេតុផលដែលខ្ញុំនិយាយថា តាម៉ោង និង តាវ៉ាល់ កាចជាង យាយថែម ព្រោះពីមុនមក តាម៉ោង គាត់គ្រប់គ្រងឃោធា ហើយ តាម៉ោង និង តាវ៉ាល់ តែងតែនិយាយខ្លាំងៗ។ ដូច្នេះគេគ្រប់ៗគ្នា តែងតែខ្លាចគាត់។ សំណួរ៖ ក្រោមការគ្រប់គ្រងរបស់ តាម៉ោង និង យាយថែម តើលោកដឹងថា តើការគ្រប់គ្រងមួយណា ដែលមានមនុស្សបាត់ខ្លួនច្រើនជាង? ឆ្លើយ៖ មនុស្សបាត់ខ្លួនច្រើន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ យាយថែម។"

[១៥:១៦:១៦]

ឯកសារបន្តដែលខ្ញុំចង់លើកយកមកបង្ហាញគឺ E3/7805 គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហើយផ្នែកដែលខ្ញុំចង់ដកស្រង់ គឺនៅត្រង់ទំព័រ 0027

7815 ជាភាសាអង់គ្លេស, 00267443 ជាភាសាខ្មែរ និងទំព័រ 00315174 ជាភាសាបារាំង។ ហើយនៅត្រង់ផ្នែកនេះគឺនិយាយអំពី តាវ៉ាល់ ហើយបាននិយាយថា៖ "គាត់ត្រូវបានគេសម្លាប់ក្នុងរបបខ្មែរក្រហម ព្រោះគាត់ក៏ជាឃាតករផងដែរ។" សូមបញ្ចប់ការដកស្រង់។

ហើយផ្នែកដែលខ្ញុំចង់បង្ហាញបន្តទៀត គឺនៅពីរទំព័រក្រោយអង់គ្លេស មានលេខ 00277817, ខ្មែរមានលេខ 00267746 និងបារាំងមានលេខ 00315177។ ហើយនៅត្រង់ផ្នែកនេះនិយាយអំពីតាយន់ ដែលជាអ្នកមកជំនួស តាវ៉ាល់។ ហើយវាបាននិយាយដូចតទៅនេះ៖ "តាយន់ មកពីខាងភូមិភាគនិរតីមកគ្រប់គ្រងទំនប់ត្រពាំងថ្ម។ គាត់បានចាប់ខ្លួន ហើយសម្លាប់មនុស្សជាច្រើន។" សូមបញ្ចប់ការដកស្រង់។

ឥឡូវនេះខ្ញុំចង់បង្ហាញអង្គជំនុំជម្រះផងដែរ អំពីឯកសារដែលត្រូវបានជំទាស់ E3/7366។ លោកប្រធាន ដូច្នេះឥឡូវនេះសូមបញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំ ហើយខ្ញុំសូមអនុញ្ញាតប្រគល់វេទិកាជូនទៅសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមលោកប្រធាន អនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីដើមបណ្តឹងរដ្ឋប្បវេណី សូមគោរពសាជាថ្មី។ ជាបន្តពីតំណាងសហព្រះរាជអាជ្ញា យើងខ្ញុំនឹងលើកអំពីព័ត៌មានដែលចេញអំពីបែបបទសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលពាក់ព័ន្ធទៅនឹងការដ្ឋានត្រពាំងថ្ម។ ទាំងនេះ គឺជាសម្រង់ដែលមានខ្លីៗ អំពីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូប។

[១៥:១៩:១៩]

ទី១ គឺឯកសារលេខ E3/6453 ដែលជាបែបបទព័ត៌មានជនរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ភេទស្រី (សូមទោស) គឺលោកស្រី ស៊ុន សាលៀម។ ខ្ញុំសូមស្រង់យកព័ត៌មានរបស់គាត់ដែលនៅក្នុង ERN ជាភាសាខ្មែរគឺលេខ 00553167 ហើយមិនមាន ERN ជាភាសាបារាំង និងអង់គ្លេស ដោយសារយើងពុំទាន់បានទទួលអត្ថបទបកប្រែនៅឡើយ តែយើងបានស្នើសុំឲ្យមានការបកប្រែរួចទៅហើយ។ ខ្ញុំសូមស្រង់នូវអ្វីដែលគាត់បានសរសេរដូចតទៅ៖ "ពួក ប៉ុល ពត ឲ្យខ្ញុំទៅរែកដី លើកទំនប់នៅ

អាងត្រពាំងថ្មទាំងយប់ទាំងថ្ងៃ សម្រាកតែពេលមួយ -- សម្រាកតែពេលម៉ោង១១ថ្ងៃត្រង់ទេ។ ខ្ញុំក្រោកមិនទាន់ម៉ោង ឬធ្វើការងារយឺត គេក៏វាយខ្ញុំ។ ពួកវាយករំពាត់ឈើ ប៉ុនមេជើងវាយខ្ញុំចំឆ្អឹងខ្នង វាយល្មមឈឺ គេឲ្យក្រោកទៅធ្វើការទៀត។ គេវាយខ្ញុំមួយខែ បីឬបួនដង។ បន្ទាប់មកគេឲ្យខ្ញុំទៅភូមិកូនខ្លែង នៅទីនោះគេរាស់ទឹកឲ្យហូបមួយស្លាបព្រាម្នាក់ ក្នុងមួយពេល ហើយមួយថ្ងៃហូបពីរពេល។"

ឯកសារទី២ គឺរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានឈ្មោះថា លៀម ពេញ (ប្រុស) ដែលមានលេខឯកសារ E3/6382។ សម្រង់ដែលខ្ញុំស្រង់ជូននាពេលនេះមាន ERN ជាភាសាខ្មែរ 00540480 ពុំមាន ERN ជាភាសាបារាំង និងអង់គ្លេសទេ។ ហើយខ្ញុំសូមដកស្រង់ដូចតទៅ៖ "បន្ទាប់ពីច្រូតស្រូវរួច ពួកយើងត្រូវបាន មិត្តវ៉ាល់ (ស្លាប់) ជាប្រធានកងធំនៅអាងត្រពាំងថ្ម បញ្ជាឲ្យទៅលើកទំនប់អាងត្រពាំងថ្មម្ដង។ នៅពេលលើកទំនប់អាងត្រពាំងថ្ម មិត្តវ៉ាល់ បានបញ្ជាឲ្យខ្ញុំជាមួយ មិត្តពាត (នៅរស់) មិត្តធួក (នៅរស់) មិត្តស៊ុន (ស្លាប់) និងអ្នកផ្សេងទៀត(មិនចាំឈ្មោះ) ត្រូវជីករណ្ដៅឲ្យបាន៣ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយមាន មិត្តសឿន (ស្លាប់) ជាមេក្រុមដឹកនាំធ្វើការ។ ពេលនោះពួកយើងខិតខំធ្វើការគ្មានពេលស្រាកស្រាន្តទេ ជួនកាលពួកយើងត្រូវធ្វើការនៅពេលយប់ថែមទៀត បើពេលថ្ងៃធ្វើមិនរួច។ រាល់ថ្ងៃពួកយើងធ្វើការធ្ងន់ធ្ងរ ប៉ុន្តែពួកវាបែរជាមិនឲ្យពួកយើងហូបឆ្អែតទៅវិញ។ ដោយសារហូបមិនឆ្អែត ពេលសម្រាកពីធ្វើការ ខ្ញុំបានឆ្លៀតពេល លួចបេះផ្សិត ចាប់ក្ដាម ចាប់ត្រីបន្ថែមទុកសម្រាប់ចម្អិនហូប។ ខ្ញុំចាំថា ថ្ងៃមួយមិត្តរួមការងារម្នាក់ (មិនចាំឈ្មោះ) ជីករណ្ដៅប្រឡាយមិនបានសម្រេច ក៏ត្រូវយោធាខ្មែរក្រហម (មិនចាំឈ្មោះ) ចាប់ចងស្លាបសេក រួចវាយនឹងត្បូងចបសម្លាប់ចោលតែម្ដង ធ្វើឲ្យខ្ញុំមានអារម្មណ៍ភ័យខ្លាចជាខ្លាំង។ ដូច្នេះរាល់ថ្ងៃខ្ញុំបានប្រឹងប្រែងធ្វើការណាស់ ព្រោះបើមិនបានគ្រប់តាមផែនការកំណត់ទេនោះ ខ្ញុំនឹងអាចត្រូវពួកវាយកទៅសម្លាប់ដែរ។ ទោះបីជារាល់ថ្ងៃហូបមិនឆ្អែតដោយទទួលបានបបររាវៗមួយកូនចានចង្កឹះប៉ុណ្ណោះក្នុងមួយពេលក៏ដោយ ក៏មិនហ៊ានតវ៉ា ឬត្អូញត្អែរអ្វីទេ។"

[១៥:២៥:៥៦]

ឯកសារទី៣ ដែលខ្ញុំលើកមកជម្រាបជូនលោក លោកស្រីចៅក្រមពេលនេះគឺឯកសាររបស់លោកស្រី ប្លែក សាឡឹត ដែលមានលេខ E3/6391 ERN មានតែភាសាខ្មែរតែប៉ុណ្ណោះលេខ 00540623។ លោកស្រីបាននិយាយអំពីស្ថានភាពធ្វើការរបស់គាត់ដូចតទៅ ខ្ញុំសូមដកស្រង់៖ "១៩៧៦ មិត្តអេត, មិត្តពួយ បានបញ្ជាឲ្យកងខ្ញុំមាន មិត្តម៉ុប(នៅរស់), មិត្តមាល់ (នៅរស់), មិត្តតើស (នៅរស់), មិត្តអឿប (នៅរស់) និងអ្នកថ្មីដែលជម្លៀសមកពីទីក្រុងភ្នំពេញជាច្រើននាក់ (មិនចាំឈ្មោះ) ចល័តទៅ

លើកទំនប់អាងត្រពាំងថ្ម។ នៅការដ្ឋានអាងត្រពាំងថ្មមាន មិត្តវ៉ាល់ (ស្លាប់) ជាប្រធានកងធំ បន្ទាប់មកមានមិត្ត រួន (មិនដឹងស្លាប់ឬរស់), មិត្តក្រុង (មិនដឹងស្លាប់ឬរស់), មិត្តកៀយ (ស្លាប់) ជាមេកងចល័តបានបញ្ជាឲ្យពួកយើងជីកទំនប់លើកប្រឡាយ ម្នាក់ៗចំនួន៣ម៉ែត្រគូបក្នុងមួយថ្ងៃ។ ពេលនោះមានការលំបាកខ្លាំងណាស់ ព្រោះត្រូវបង្ខំធ្វើការធ្ងន់ហើយ ហូបមិនឆ្អែត។ ម៉្យាងទៀតបើសិនជានរណាម្នាក់ជីកបាន៣ម៉ែត្រគូបហើយ មិនទាន់យប់នោះ គឺពួកវាឲ្យជីកបន្ថែម៣ម៉ែត្រគូបទៀតរហូតទាល់តែយប់ទើបអាចសម្រាកបាន។ នៅអាងត្រពាំងថ្មនេះ មានមនុស្សស្លាប់ជាច្រើន ខ្លះស្លាប់អត់បាយ ខ្លះស្លាប់ដោយសារជំងឺ ខ្លះទៀតស្លាប់ដោយសារពួកឈ្លបយកទៅសម្លាប់ដោយមិនដឹងពីមូលហេតុ។"

[១៥:២៨:៤០]

ឯកសារទី៤ ជាឯកសារបែបបទពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាឯកសារចុងក្រោយ គឺឯកសាររបស់លោកស្រី ធន់ ហាម ដែលមានលេខE3/6630 ERNជាភាសាខ្មែរ 00558119, ERN ជាភាសាអង់គ្លេស 01069323, មិនមាន ERN ជាភាសាបារាំងទេ។ ខ្ញុំសូមដកស្រង់សម្រង់នៃព័ត៌មានដែលលោកស្រី ធន់ ហាម បានផ្តល់នៅក្នុងពាក្យសុំរបស់គាត់ដូចតទៅ៖ "១៩៧៦ មិត្តរ៉ុត ជាប្រធានកងបានបញ្ជាឲ្យខ្ញុំជាមួយ មិត្តពេជ្រ (នៅរស់), មិត្តវណ្ណា (នៅរស់), មិត្តហួយ (នៅរស់), មិត្តភួង (នៅរស់) ធ្វើជាកងចល័តលើកទំនប់ជីកប្រឡាយអាងត្រពាំងថ្ម។ នៅការដ្ឋានអាងត្រពាំងថ្មមាន មិត្តវ៉ាល់ (ស្លាប់) ជាប្រធានកងធំ បានបញ្ជាឲ្យម្នាក់ៗជីកប្រឡាយលើកទំនប់៣ម៉ែត្រគូបក្នុងមួយថ្ងៃ។ ពេលនោះខ្ញុំក៏ដូចជាអ្នកផ្សេងទៀត ជីករណ្តៅ រួចត្រូវសែងអាចម៍ដីមកចាក់ធ្វើទំនប់ទៀត បើធ្វើមិនរួចវិញ អង្គការនឹងយកទៅរៀនសូត្រ (សម័យនោះគឺសម្លាប់)។ ដូច្នេះរាល់ថ្ងៃ ពួកយើងប្រឹងប្រែងធ្វើការណាស់ ទោះបីជាភ្លៀង ខ្យល់ក្តៅ រងារយ៉ាងណា ក៏មិនប៉ានសម្រាកឡើយ។ ចំណែកការស្នាក់នៅគ្មានជម្រកត្រឹមត្រូវទេ គឺក្រោយពីធ្វើការរួច ដេកនៅទីនោះតែម្តង គ្មានអ្វីបិទបាំងទេ គឺដេកតាមខ្នងទំនប់ ហាលខ្យល់ ហាលភ្លៀង ត្រូវមូសខាំទៀត។ បើនិយាយពីការហូបចុកវិញ រឹតតែពិបាក ទោះបីជាពួកយើងខិតខំធ្វើការយ៉ាងណា ក៏ពួកវាឲ្យហូបតែបាយមួយកូនចានប៉ុណ្ណោះក្នុងមួយពេល។ លុះធ្វើការបានប្រហែល៥ខែ មិត្តវ៉ាល់ បានដាក់បញ្ជាថ្មី គឺម្នាក់ៗត្រូវជីកឲ្យបាន៥ម៉ែត្រគូប បើធ្វើមិនរួច អង្គការនឹងយកទៅរៀនសូត្រ។ ពេលនោះហើយដែលខ្ញុំខំប្រឹងធ្វើការគ្មានស្គាល់ថ្ងៃយប់ឡើយ ព្រោះខ្លាចគេសម្លាប់ចោល។"

ខ្ញុំបញ្ចប់ត្រឹមនេះ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ឡើងវិញប្រហែលជាមានការបកប្រែខុសចំពោះលេខ

ឯកសារទី១របស់ខ្ញុំ មិនមែនជាឯកសារ E3/6453 ទេគឺឯកសារ E3/6543។ ខ្ញុំលើកអំពីស្ថានភាពនៃការរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនជូនលោកប្រធាន និងលោក លោកស្រីសម្រាប់ពិចារណាត្រឹមនេះ។ ហើយខ្ញុំសូមអរគុណលោកប្រធានដែលផ្តល់ឱកាសឲ្យខ្ញុំលើកអំពីឯកសារទាំងនេះ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

[១៥:៣៣:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៦:៣៩]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅសហព្រះរាជអាជ្ញារងអន្តរជាតិ?

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

បាទសូមអរគុណលោកប្រធាន។ អម្បាញ់ខ្ញុំបានដកស្រង់ឯកសារ E3/5287 ដោយមិនបានផ្តល់លេខ ERN ពាក់ព័ន្ធទេ ពីផ្នែកដែលខ្ញុំបានដកស្រង់អម្បាញ់មិញនោះ។ ជាភាសាបារាំងគឺ ERN លេខ 00404191, ហើយជាភាសាអង់គ្លេសគឺ 00330776, ជាភាសាខ្មែរគឺ 00321783 នេះគឺជាកំណត់ហេតុស្តាប់ចម្លើយដែលខ្ញុំបានដកស្រង់ទាក់ទងនឹងទំនប់១មករា លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះបានទទួលព័ត៌មានមួយមិនទាន់ច្បាស់លាស់ទេ ប៉ុន្តែថាតាមរយៈមន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងថា ខាងមេធាវីការពារក្តីលោក ខៀវ សំផន មានជំហរជំទាស់ជាមួយនឹងការកោះហៅសាក្សីមួយរូប មកស្តាប់សក្ខីកម្មនៅនាពេលខាងមុខ ពាក់ព័ន្ធជាមួយនឹងអង្គហេតុការប្រព្រឹត្តទៅលើគោលដៅជាក់លាក់ចំពោះចំពោះជនជាតិចាម។ ហើយបើសិនជាដូច្នោះមែន សូមបង្ហាញនូវសំណើជាក់លាក់ និងមូលហេតុនៃការដែលជំទាស់ក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ ដើម្បីអង្គជំនុំជម្រះមានលទ្ធភាពស្តាប់នូវភាគីពាក់ព័ន្ធដទៃទៀត និងឈានដល់ការពិនិត្យសម្រេចឲ្យបានឆាប់ៗ ពីព្រោះថា បញ្ហាយើងមិនអាចបណ្តែតបណ្តោយបានទេ វាពាក់ព័ន្ធជាមួយនឹងការទៅនាំយកសាក្សីមកកាន់ អ.វ.ត.ក ដែលមានរយៈពេល រយៈផ្លូវចម្ងាយឆ្ងាយ ហើយការពាក់ព័ន្ធ

រហូតដល់ការរៀបចំដំណើរការសវនាការរបស់អង្គជំនុំជម្រះផង។ តើមានដែរទេ? បើមានសូមអញ្ជើញបាទ!

[១៥:៣៨:៥៣]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំគិតថាលោកប្រធានកំពុងតែនិយាយពីសំណើមួយដែលយើងកំពុងតែជូនដំណឹងដែលមានចំណងជើងថា ការជំទាស់របស់ក្រុម ខៀវ សំផន ក្នុងការកោះហៅសាក្សី TCW-987។ ពីសប្តាហ៍មុននោះយើងបានផ្ញើរអ៊ីម៉ែល ខ្ញុំមិនចាំទេ អំពីលទ្ធភាពដែលមិនអាចអញ្ជើញសាក្សីហ្នឹងមកបាន។ ហើយអង្គជំនុំជម្រះបានសម្រេចកោះហៅសាក្សីថ្មីរូបនេះគឺ 2-TCW-987 អ៊ីចឹងបើសិនជាមានកោះហៅសាក្សីផ្សេងមកជំនួសនោះ មិនបញ្ហាអ្វីទេក៏ប៉ុន្តែបញ្ហាត្រង់ថា ពីព្រោះថា វាជាសាក្សីដែលមិននៅក្នុងបញ្ជីសាក្សីដែលត្រូវកោះហៅមកទេ ហើយសាក្សីនេះក៏មិនត្រូវបានស្តាប់ដោយចៅក្រមស៊ើបអង្កេតផងដែរនៅក្នុងសំណុំរឿង០០២ យើងនេះ។ ហើយគឺជាសាក្សីដែលជាកម្មវត្ថុនៃការស៊ើបអង្កេតក្នុងសំណុំរឿងមួយទៀតទៅវិញទេ។ ហើយអង្គជំនុំជម្រះបានសម្រេចកោះហៅសាក្សីនេះមកជំនុំជម្រះយើងនេះ។ អ៊ីចឹងបញ្ហាពីរលើកឡើង ពីព្រោះថាវាទាក់ទងទៅនឹងបញ្ហាដែលយើងបានលើកមកហើយហើយយើងដឹងថា នឹងកើតមានបញ្ហានេះឡើង ពីព្រោះថាបើក្រោយពីមានការជូនដំណឹងជាច្រើន -- ការផ្ទេរឯកសារភស្តុតាងជាច្រើនមកពីសំណុំរឿងផ្សេងទៀតនោះ គឺថាទោះបីពេលព្រះរាជអាជ្ញាមិនបានសុំឲ្យដាក់ឯកសារថ្មីក៏ដោយ ទោះបីជាឯកសារនោះ មិនបានសុំឲ្យសាក្សីផ្សេងទៀតមកបង្ហាញខ្លួននៅទីនេះក៏ដោយ។ ក៏ប៉ុន្តែយើងដឹងថា អង្គជំនុំជម្រះខ្លួនឯងផ្ទាល់ ដោយខ្លួនឯងនោះ អាចសម្រេចថាកោះហៅសាក្សីដែលនៅក្នុងសំណុំរឿងផ្សេងទៀតនុ៎ង មកឆ្លើយនៅទីនេះ។ ដូច្នេះយើងជំទាស់ក្នុងការកោះហៅសាក្សី 2-TCW-987 នេះពីព្រោះយើងយល់ឃើញថា ការដែលគាត់មកទីនេះ គឺថាប៉ុន្មានថ្ងៃមុននោះ យើងបានទទួលដំណឹង ហើយមុនប៉ុន្មានថ្ងៃនេះ យើងមិនដឹងថា កោះសាក្សីមួយណាទៀតមកទីនេះទេ។ ហើយបើទាក់ទងនឹងសិទ្ធិលោក ខៀវ សំផន នោះ ក៏គាត់ត្រូវតែការពារខ្លួនគាត់ឲ្យសមស្រប គឺថា គាត់ត្រូវដឹងពីការចោទរបស់គាត់ឲ្យច្បាស់លាស់ សាក្សីណាត្រូវកោះហៅមក។ អ៊ីចឹងគាត់ត្រូវតែទទួលបានការជូនដំណឹងអំពីសាក្សី ដែលនឹងមកផ្តល់សក្ខីកម្មនៅទីនេះ ហើយនិងដើម្បីឲ្យគាត់អាចត្រៀមខ្លួនបាន។

[១៥:៤១:៤៨]

ហើយនេះជាខ្លឹមសារសង្ខេបនៃសំណើរបស់យើង យើងនឹងសរសេរក្នុងន័យនេះឯង។ ខ្ញុំមិនដឹងថា ភាគីផ្សេងទៀតបានទទួលការជូនដំណឹងពីអង្គជំនុំជម្រះដែរឬអត់ទេ ទាក់ទងនឹងសាក្សីនេះនោះ។ ពីព្រោះថា ពីដើមមកសាក្សីរូបនេះ មិនត្រូវបានស្តាប់ដោយសហចៅក្រមស៊ើបអង្កេតនោះទេ។ អ៊ីចឹងយើងត្រូវច្បាស់ទាំងអស់គ្នា គឺថាដើម្បីឲ្យទឡ្ហីករណ៍របស់យើងនោះ ត្រូវបានយល់ឲ្យច្បាស់គ្រប់ភាគី។ គឺថានេះគឺជាសំណើដែលសំណើពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយ ដែលចេញមកពីសំណុំរឿង ០៣, ០៤ ហើយសំណើនេះ កំពុងតែទន្ទឹងរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ អ៊ីចឹងដើម្បីបំភ្លឺការជំទាស់របស់យើងនោះ គឺថាយើងជំទាស់ទៅនឹងការកោះហៅសាក្សីរូបនេះឯង។ ពីព្រោះថា លោក ខៀវ សំផន គាត់ស្ថិតនៅក្នុងចំពោះមុខនីតិវិធីច្បាប់បារាំង ដែលត្រូវមានដីកាដំណោះស្រាយ មានបញ្ចើដាក់ដោយភាគីច្បាស់លាស់ ហើយដឹងថាសាក្សីណាដែលខ្លួនចង់ស្តាប់ជាដើមនោះ។ ហើយដូច្នេះអង្គជំនុំជម្រះមានសិទ្ធិថា បញ្ជាឲ្យស៊ើបអង្កេតតាមករណី ក៏ប៉ុន្តែក្នុងករណីនេះ ខ្ញុំមិនមានព័ត៌មានលម្អិតនោះទេ គឺថាប៉ុន្តែទោះយ៉ាងក្តី យើងដឹងថា ក្រោយពីពេលដែលយើងផ្ទេរព័ត៌មាន ឬក៏ភស្តុតាងមកពីសំណុំរឿងផ្សេងៗទៀតមកនោះ ដែលអង្គជំនុំជម្រះគាំទ្រ ហើយស្នើដោយព្រះរាជអាជ្ញាហ្នឹង គឺយើងជំទាស់នឹងការអនុវត្តដូចនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:៤៣:៥០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំយល់មិនច្រឡំទេ មេធាវី ខៀវ សំផន អាចកែខ្ញុំបាន បើសិនខ្ញុំនិយាយខុស។ ខ្ញុំយល់អម្បាញ់មិញនេះ គឺថាអំណះអំណាងផ្លូវច្បាប់នោះ គឺថាត្រូវគោរពសិទ្ធិការពារខ្លួនរបស់លោក ខៀវ សំផន។ អ៊ីចឹងក្រៅពីការលើកពីគោលការណ៍ជាទូទៅនេះ ខ្ញុំក៏ឮផងដែរថា លោកស្រីយោងទៅនឹងច្បាប់ស៊ីវិលឡូ ដោយមិនមានការបញ្ជាក់បំភ្លឺទេ។ តើលោកស្រីមានបទប្បញ្ញត្តិច្បាប់ជាក់លាក់ណាមួយទេ ដែលលោកស្រីចង់លើកឡើង ដើម្បីគាំទ្រការជំទាស់របស់លោកស្រីនេះ? ធម្មតានៅក្នុងវិធានផ្ទៃក្នុងរបស់យើងនេះ គឺថាមានបទប្បញ្ញត្តិមួយ គឺវិធាន៨៧(៤) ដែលអនុញ្ញាតឲ្យ ថាប្រកាសទទួលយកបាននូវភស្តុតាងដែលយើងចាប់ផ្តើមជំនុំជម្រះហើយ។ ហើយអង្គជំនុំជម្រះនោះ មានសិទ្ធិធ្វើយ៉ាងនេះ ដោយចិត្តឯង មិនចាំបាច់មានការស្នើទេ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំយល់ហើយ ប៉ុន្តែអម្បាញ់មិញនេះ ខ្ញុំលើកឡើងថា នេះវាចោទបញ្ហាដល់ក្រុម ខៀវ សំផន ពីព្រោះថាយើងឃើញសេចក្តីសម្រេចនេះហ្នឹង គឺថាការបើកវិសាលភាពធំទៀត គឺថារាល់ការស៊ើបអង្កេតក្នុងសំណុំរឿង០៣, ០៤អីនោះ ទៅតាមព្រឹត្តិន័យនោះបង្កើតឲ្យមានបញ្ហា ទោះបីថាមានវិធាន ៨៧(៤) ហ្នឹងក៏ដោយ។ ខ្ញុំដឹងថា អង្គជំនុំជម្រះមានសិទ្ធិធ្វើយ៉ាងដូច្នេះ ក៏ប៉ុន្តែឥឡូវនេះមានការស៊ើបអង្កេតកំពុងតែស៊ើបអង្កេតហើយ។ រាប់ឆ្នាំមកហើយមានដីកាបញ្ជូនរឿងឲ្យស៊ើបសួរ មានដីកាដំណោះស្រាយ ហើយឥឡូវនេះដល់២០១៥ទៅហើយ យើងត្រូវទៅយកភស្តុតាងនៅក្នុងសំណុំរឿងផ្សេងទៀតដែលកំពុងតែស៊ើបអង្កេតនេះ ដើម្បីមកដាក់បន្ទុកលើកូនក្តីខ្ញុំ។ ខ្ញុំមើលទៅឃើញថា នេះជាបញ្ហាធ្ងន់ធ្ងរណាស់។ ខ្ញុំមិននិយាយថា មិនមានវិធានដែលចែងនៅក្នុងវិធានផ្ទៃក្នុងយើងនោះទេ ក៏ប៉ុន្តែខ្ញុំគិតថា ត្រង់ចំណុចនេះវិធីសាស្ត្រនៃធ្វើការដូច្នេះ ហើយនិងចេះតែបញ្ជូនឯកសារមករហូត ព្រះរាជអាជ្ញាចេះតែបញ្ជូនមកអ៊ីចឹង នេះវាជាកម្មវត្ថុនៃសំណើយើង ដែលរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនេះហើយ ហើយវាធ្វើឲ្យប៉ះពាល់ដល់សិទ្ធិការពារ។

[១៥:៤៦:២២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ជាព័ត៌មាន កំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះបានដាក់ឲ្យភាគីទាំងអស់ប្រើប្រាស់ហើយ ចាប់ពីថ្ងៃទី២០ ខែ៣ ឆ្នាំ២០១៥។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំមិនសង្ស័យទេ ខ្ញុំដឹងហើយ បើសិនជាលោកចៅក្រមយោងទៅនឹងសំណើដែលចេញមកពីអង្គជំនុំជម្រះនោះ គឺថាយើងដឹងការងារយើងច្រើន ថាការងារច្រើនណាស់ ព្រោះឯកសារដែលផ្តល់មកនោះច្រើនមែនទែន ហើយសាក្សីដែលយើងកំពុងនិយាយនេះ មិនមានសំណើអីទេ។ ហើយកាលពីសប្តាហ៍មុននេះ ឬក៏ដើមសប្តាហ៍នេះ ដែលអង្គជំនុំជម្រះថា គ្រោងស្តាប់ចម្លើយសាក្សីនេះហ្នឹង យើងមិនបានឃើញថាសាក្សីហ្នឹងស្ថិតនៅក្នុងបញ្ជីសាក្សី ដែលពិសេសត្រូវស្តាប់នោះទេ។ យើងមិនបានទៅវិភាគទៅលើបញ្ជីហ្នឹងទេ ដោយសារឈ្មោះនេះអត់មានសំណើដាក់ មានសំណើចេញពីដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ព្រះរាជអាជ្ញានោះទេ។ អ៊ីចឹងខ្ញុំជម្រាបជូនថា មានឯកសាររាប់រយដែលយើងមិនស្គាល់ច្បាស់នោះទេ មិនដឹងច្បាស់នោះទេ យើងមិនបានពិចារណាឲ្យបានលើសឯកសារផ្សេងទៀតនោះទេ ពីព្រោះថា

យើងកំពុងតែចាប់ដំណើរការនីតិវិធី កំពុងតែជំនុំជម្រះក្តី ហើយកំណត់ហេតុស្តាប់ចម្លើយទាំងអស់នោះ សុទ្ធតែនៅក្នុងសំណុំរឿងផ្សេងនោះទេ។ ដល់អ៊ីចឹង ឯកសារទាំងឡាយដែលមកពីសំណុំរឿងផ្សេងទៀតនោះ មិនមែនជាអាទិភាពនៃការការពារក្តីរបស់លោក ខៀវ សំផន ទេ ព្រោះមិនមែននៅក្នុងសំណុំរឿង ០០២/២ នេះទេ។

[១៥:៤៨:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ អំមិញនេះខ្ញុំក្រោកឡើង ដើម្បីរំឭកដល់ភាគីការពារក្តីថា ឯកសារនេះត្រូវបានបញ្ជូនមកនៅខែមីនា ឥឡូវនេះខែ៩ហើយ អ៊ីចឹងថាមានសំណើមួយរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះ។ អ៊ីចឹងរយៈពេលច្រើនកន្លងផុតមកហើយ ហើយខាងការពារក្តីក៏មិនដែលមានប្រតិកម្មអីដែរ។ យើងទាំងអស់នេះ ភាគីទាំងអស់សុទ្ធតែក្នុងស្ថានភាពដូចគ្នា គឺថាមានសាក្សីមួយដែលមកផ្តល់សក្ខីកម្មនៅថ្ងៃពុធនេះ ហើយមានកំណត់ហេតុស្តាប់ចម្លើយពីរ ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងហើយ ហើយទាំងអស់នោះមានតែ១៥ទំព័រយ៉ាងច្រើនបំផុត។ ខ្ញុំគិតថា ដូចជាមិនមែនជាឧបសគ្គនោះទេ យើងទាំងអស់គ្នាអាចសិក្សាឯកសារនេះបាន ទៅថ្ងៃពុធឯណោះបានសវនាការស្តាប់គាត់។ អ៊ីចឹង ក៏ប៉ុន្តែទោះយ៉ាងណាក្តី អង្គជំនុំជម្រះមានអភ័យឯកសិទ្ធិក្នុងការសម្រេចថា តើត្រូវស្តាប់សក្ខីកម្មសាក្សីនេះដែរ ឬក៏អត់នៅថ្ងៃពុធក្រោយ។

**ប្រធានអង្គជំនុំ៖**

ភាគីដទៃទៀត មានមតិយោបល់អ្វីផ្សេងទេ មុននឹងផ្តល់វេទិកាជូនទៅម្ចាស់សំណើដើម្បីតបចុងក្រោយ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ដោយហេតុថា យើងមិនបានអានសំណើរបស់លោក ខៀវ សំផន នោះ អ៊ីចឹងយើងសុំរក្សាសិទ្ធិធ្វើការកត់សម្គាល់នៅថ្ងៃចន្ទ ដើម្បីឲ្យយល់ពីខ្លឹមសារជាក់លាក់នៃសំណើរបស់ក្រុម ខៀវ សំផន នេះលោកប្រធាន។ ចំពោះពួកយើងខ្ញុំ យើងមិនមានការជំទាស់ទេ បើពេលឥឡូវនេះ បើថាកោះហៅសាក្សីនេះ យើងមិនជំទាស់ទេ យើងមិនមានគោលជំហរដូចក្រុម ខៀវ សំផន

ទេ ក្នុងការផ្ទេរឯកសារមកនេះ។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី យើងក៏ចង់សុំអាន យកពេលវេលាអានសំណើរបស់ក្រុម ខៀវ សំផន សិនមុននឹងមានលទ្ធភាពអាចធ្វើការកត់សម្គាល់ជាផ្ទាល់មាត់នៅថ្ងៃចន្ទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អំមិញយើងបានប្រាប់រួចហើយថា ជាបន្ទាន់នេះវាពាក់ព័ន្ធជាមួយនឹងលទ្ធភាពរៀបចំដំណើរការសវនាការ កាលវិភាគសវនាការសម្រាប់សប្តាហ៍ក្រោយ។ នៅក្នុងនោះអង្គជំនុំជម្រះត្រូវសម្របសម្រួលជាមួយនឹងខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការទៅទទួលយកសាក្សីពីទីឆ្ងាយមកកាន់កន្លែង អ.វ.ត.ក នេះ ហើយមិនមែនមកតែថ្ងៃណា មកថ្ងៃហ្នឹងទេ យើងត្រៀមមុន។ អ៊ីចឹងហើយបានយើងយកចង់ស្តាប់មតិយោបល់ក្នុងបំណង ដើម្បីសម្រេចពីបញ្ហានេះឲ្យបានជ្រះស្រឡះ ដើម្បីអាចមានលទ្ធភាពក្នុងការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញថាគួរចាត់ការដូចម្តេច នៅក្នុងសប្តាហ៍ក្រោយ ដើម្បីឲ្យដំណើរការនៃការរៀបចំរបស់អង្គជំនុំជម្រះប្រព្រឹត្តទៅបានល្អ។ នេះជាគោលបំណងដែលយើងឆ្លៀតឱកាសក្នុងការស្តាប់មតិយោបល់នៅពេលនេះ ហើយគាត់បានបញ្ជាក់ហើយថា អំមិញមតិយោបល់ សំណើនេះគឺខ្លឹមសារមិនខុសគ្នាអីទេ គឺខ្លឹមសាររបស់គាត់ គឺចេញខ្លួនគាត់អ្នករៀបចំ។

សូមអញ្ជើញលោកស្រីមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ អំមិញយើងឃើញលោកស្រីមានបំណងក្រោកឈរ ហើយយើងអនុញ្ញាតឲ្យភាគីមួយទៀតនិយាយឲ្យចប់សិន ដើម្បីកុំឲ្យពេលវេលាវាអូសវែងឆ្ងាយ គឺទុកលទ្ធភាពឲ្យលោកស្រីហ្នឹងមានឱកាសចុងក្រោយក្នុងការឆ្លើយតបទៅភាគីដែលពាក់ព័ន្ធលើបញ្ហានេះ។

[១៥:៥២:០៦]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ខ្ញុំនិយាយខ្លីទេ។ ខ្ញុំត្រូវបង្ខំចិត្តរំឮកទៅព្រះរាជអាជ្ញាវិញថា យើងសូមឲ្យឈប់និយាយពីចំនួនទំព័រហ្នឹងទៀតទៅ ព្រោះថានេះ យើងត្រូវដឹងថាមានចំនួនប៉ុន្មានទំព័រហើយថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយនោះ ហើយកុំឲ្យយកមកនិយាយយើងថា យើងហ្នឹងគ្រាន់តែត្រៀមលក្ខណៈគ្រាន់តែអានចម្លើយសាក្សីនោះ ព្រោះថា យើងត្រូវតែធ្វើការផ្ទួរផ្ទងឯកសារផ្សេងៗធៀបគ្នា បានយើងអាចធ្វើការបាន។ ពេលស៊ើបអង្កេតយើងត្រូវធ្វើយ៉ាងម៉េច ពេលដែលយើងកំពុងដំណើរ

ការនីតិវិធីយើងត្រូវធ្វើយ៉ាងម៉េច ហើយសាក្សីដែលពីមុនមកត្រូវបានសម្ភាសដោយចៅក្រមស៊ើបអង្កេតនោះ ពេលធ្វើស៊ើបអង្កេតនោះយ៉ាងណា ហើយឥឡូវនេះតើពេលសួរយ៉ាងណា។ មិនមែនត្រឹមតែចំនួនទំព័រថា ១០ទំព័រ ២០ទំព័រនោះទេ គឺថានៅក្នុងសំណុំរឿង០០២/០២នេះ យើងមើលទៅឃើញថាកិច្ចដំណើរការនីតិវិធីទោះបីលើត្រពាំងថ្មក៏ដោយ ការដ្ឋានផ្សេងទៀតក៏ដោយ ហើយការស៊ើបអង្កេតនោះបានធ្វើទៅហើយ ការជម្រះសេចក្ដីនោះបានចេញបន្តមកហើយ ហើយស្រាប់តែមានការស៊ើបអង្កេតនៅក្នុងសំណុំរឿងផ្សេងៗទៀតហ្នឹង ស្រាប់យើងយកឯកសារហ្នឹងមកដាក់ចូលក្នុងសំណុំរឿងនេះរហូត។ អ៊ីចឹងហើយបានខ្ញុំថានេះ វាជាកើតជាបញ្ហាហើយ កាលណាដាក់មកយ៉ាងដូច្នេះ។ អ៊ីចឹងកុំឱ្យខាងព្រះរាជអាជ្ញាហ្នឹងមកនិយាយថា គ្រាន់តែ១០ទំព័រ ២០ទំព័រហ្នឹងធ្វើទៅ។ អ៊ីចឹង ខ្ញុំគិតថាក្រុម ខៀវ សំផន យើងចង់បានដឹងថាតើភ័ស្តុតាងនោះមានប៉ុន្មានទំព័រទាំងអស់ ឱ្យច្បាស់លាស់ដើម្បីស្រួលការពារក្ដី ហើយឱ្យយើងដឹងថា តើមានសាក្សីប៉ុន្មានអាចមកផ្ដល់សក្ខីកម្មនៅទីនេះ មានប៉ុន្មានដែលមិនអាចមកបាន។ ហើយអ៊ីចឹងយើងត្រូវឱ្យដឹងច្បាស់ ថាដំណើរការនីតិវិធីហ្នឹងយ៉ាងម៉េចឱ្យជាក់លាក់ ហើយភាគីក៏ស្រួលធ្វើការដែរ។ ហើយក្រុម ខៀវ សំផន យើងជាមេធាវីការពារ យើងត្រូវការបំពេញការងារយើងឱ្យបានល្អ។ នេះជាបញ្ហាជាមូលដ្ឋាន យើងដើម្បីការពារកូនក្ដីយើងឱ្យបានច្បាស់យើងត្រូវដឹងថា មានឯកសារណាខ្លះ សាក្សីណាខ្លះដែលយើងត្រូវស្ដាប់ វិភាគ។ បើសិនជាខ្ញុំនិយាយដូច្នេះ ធ្វើឱ្យអ្នកខ្លះមិនសប្បាយចិត្ត ខ្ញុំមិនដឹងថានិយាយយ៉ាងម៉េចទេ។

[១៥:៥៤:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិនិត្យពិចារណា និងសម្រេច ហើយនិងជូនដំណឹងឆាប់ៗជូនភាគី ដើម្បីជាប្រយោជន៍សម្រាប់អង្គជំនុំជម្រះ ហើយសម្រាប់ភាគី និងអង្គជំនុំជម្រះរៀបចំនូវកាលវិភាគសវនាការជាបន្តបន្ទាប់នាសប្ដាហ៍ក្រោយ។

ហើយមុននឹងឈប់សម្រាកនៅរសៀលនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ លោក ស្មីត ដែលលើកឡើងកាលពីរសៀលនេះដែលគាត់បានស្នើសុំឱ្យអង្គជំនុំជម្រះបញ្ជាក់ អំពីថាតើខាងសហព្រះរាជអាជ្ញាមានលទ្ធភាពក្នុងការធ្វើការអត្ថាធិប្បាយ ឬក៏ធ្វើការកត់សម្គាល់តបទៅនឹងសេចក្ដីតបរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែរឬទេ? អង្គជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះមិនផ្ដល់ឱ្យលទ្ធភាពនេះទេ ដូចអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីរួច

ហើយកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ គឺបញ្ជាក់ហើយថា ការផ្តល់ឱកាស គឺឆ្លើយតបទៅនឹងការដាក់បង្ហាញឯកសាររបស់ភាគីម្ខាងទៀត មិនមែនឆ្លើយតបទៅលើសេចក្តីអត្ថាធិប្បាយ ឬក៏ការកត់សម្គាល់របស់ភាគីម្ខាងទៀតទេ សូមជ្រាប។

[១៥:៥៦:១៣]

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយៗអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការបង្ហាញឯកសារគន្លឹះដោយស្តាប់សហមេធាវីការពារក្តី ខៀវ សំផន ធ្វើអត្ថាធិប្បាយកត់សម្គាល់តបទៅនឹងបណ្តាឯកសារគន្លឹះដែលបានដាក់បង្ហាញដោយតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធជាមួយនឹងអង្គហេតុការដ្ឋានការងារចំនួនបី។ ការដ្ឋានការងារទំនប់១មករា ការដ្ឋានការងារព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានការងារទំនប់ត្រពាំងថ្ម ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-813 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការប្រព្រឹត្តលើក្រុមមនុស្សជាក់លាក់ចំពោះជនជាតិចាម។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៦ នាទី)*